3

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ភាតព្វកិច្ច និងសិទ្ធិជនបរទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លីន សំខុត្តា**

**លាង ប៊ុនឡុង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

សាស្ត្រាចារ្យណែនាំ

លោក **ជុំ អ៊ីម**

ឆ្នាំចូលរៀន ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ លីន សំវុត្ថា លាង ប៊ុនឡុង ជានិស្សិតជំនាន់ទី២២នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅអស់ពីដួងចិត្តជូនចំពោះ

លោកឪពុក និងអ្នកម្តាយ  ដែលជាអ្នកមានគុណវិសេសលន់ធ្ងន់ជាងព្រះធរណី ដែលកន្លងមកនេះ លោកទាំងពីរបានផ្តល់មកឲ្យកូននូវការថ្នាក់ថ្នមបីបាច់ថែរក្សា តាំងពីបាតជើងក្រហមរហូតមកដល់កូនចម្រើនជាមនុស្សធំពេញវ័យ ទាំងកំលាំងកាយ កំលាំងចិត្ត និងចំណាយប្រាក់កាសមកឲ្យកូនគ្រប់យ៉ាង ជាពិសេសមកលើការសិក្សា ដែលធ្វើឲ្យកូនមានលក្ខណៈងាយស្រួលក្នុងការស្រូបយកចំណេះដឹង និងទទួលបាននូវការបង្រៀន ការប្រៀនប្រដៅ អប់រំទូន្មាន ដ៏ឧត្តុង្គឧត្តមពីសំណាក់សាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

លោកសាស្ត្រាចារ្យទាំងអស់ ដែលបានផ្តល់ចំណេះដឹងឲ្យតាំងពីថ្នាក់បឋមរហូតមកដល់ថ្នាក់មហាវិទ្យាល័យ ជាពិសេសសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រទាំងអស់ ដែលបានយកអស់កម្លាំងកាយចិត្ត បង្ហាត់បង្រៀនដល់យើងខ្ញុំឲ្យយល់ដឹងផ្នែកច្បាប់(នីតិសាស្ត្រ)អស់រយះពេល៤ឆ្នាំកន្លងមក។

លោកសាស្ត្រាចារ្យ ដុំ  អ៊ុម ជាសាស្ត្រាចារ្យដឹកនាំ និងណែនាំដល់ពួកយើងខ្ញុំ ក្នុងការសរសេរសារណាមួយត្រូវបានចងក្រងប្រកបទៅជោគជ័យ មានខ្លឹមសារអត្ថន័យល្អ ដែលជាស្នាដៃនៃការខិតខំប្រឹងប្រែងរបស់យើងខ្ញុំ។

លើសពីនេះទៀត យើងខ្ញុំទាំងពីរសូមថ្លែងអំណារអរគុណ ចំពោះថ្នាក់គ្រប់គ្រងសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ឆ្លៀតក្នុងឱកាស នេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាង ជ្រាលជ្រៅចំពោះ មិត្តភ័ក្ត ដែលបានធ្វើការសហការគ្នាផ្តល់នូវឯកសារមួយចំនួនដែលពាក់ព័ន្ធ និងបទពិសោធន៍មួយចំនួនទាក់ទង និងការធ្វើសារណា។

គុណបំណាច់ដ៏ធំធេងព្រមទាំងសណ្តានចិត្តដ៏ឥតខ្ចោះរបស់អ្នកទាំងអស់គ្នាដែលបានរៀបរាប់ខាងលើ  នេះបានដក់ជាប់នៅក្នុងក្រអៅបេះដូង និងគ្មានអ្វីមកលុបលាងបានទាំងពេលនេះ និងជានិច្ចនិរន្តតរៀងទៅ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរ និងប្រសិទ្ធិពរជ័យ សិរីសួស្តី ជ័យមង្គល ជូនចំពោះលោកអ្នកមានគុណលោកគ្រូ អ្នកគ្រូ លោកសាស្ត្រាចារ្យ និងលោកជាសប្បុរស សូមប្រកបដោយ ពុទ្ធពរទាំងបួនប្រការ និងទទួលបានជ័យជំនះថ្មីៗថែមទៀតក្នុងបុព្វហេតុជាតិមាតុភូមិដ៏រុងរឿង។

# អារម្ភកថា

ខ្ញុំបាទឈ្មោះ លីន សំរុត្ថា និងលាង ប៊ុនឡុង ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ ដែលបានធ្វើការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចាប់តាំងពីឆ្នាំ២០១៨ រហូតមកដល់ឆ្នាំ២០២២។ បន្ទាប់ពីបានសិក្សាអស់រយៈពេល៤ឆ្នាំមកនេះយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនផ្នែកនីតិសាស្ត្រ អំពីសាស្ត្រាចារ្យទាំងឡាយនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនដល់រូបយើងខ្ញុំទាំងពីរ។ ដូច្នេះដើម្បីធ្វើការវាយតម្លៃទៅលើចំណេះដឹងរបស់យើងខ្ញុំ ដែលបានសិក្សាកន្លងមក យើងខ្ញុំសូមលើកយកប្រធានបទស្តីពីកាតព្វកិច្ច និងសិទ្ធិរបស់ជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា មកធ្វើការសិក្សាស្រាវជ្រាវ ដើម្បីសរសេរជាសារណាបញ្ចប់ការសិក្សា។

មូលហេតុដែលយើងខ្ញុំជ្រើសរើសយកប្រធានបទសរសេរនេះ ដោយសារតែឃើញថា ពុំទាន់មាននិស្សិតរូបណាមួយបានសរសេរពីប្រធានបទនេះនៅឡើយ ហើយយើងខ្ញុំយល់ឃើញថា នេះគឺជាប្រធានបទថ្មីដែលសមស្របនឹងស្ថានភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងពេលបច្ចុប្បន្ន។ ម្យ៉ាងវិញទៀតព្រះរាជាណាចក្រកម្ពុជាបានបង្កើតនូវលិខិតបទដ្ឋានគតិយុត្តិជាច្រើនមានដូចជា ច្បាប់ អនុក្រឹត្យ ប្រកាស និងសារាចរណែនាំជាច្រើនសម្រាប់អនុវត្ត និងគ្រប់គ្រងជនបរទេសគ្រប់ប្រភេទនៅកម្ពុជា ជាពិសេសនៅថ្មីៗនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ប្រកាសឲ្យប្រើប្រាស់នូវច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធលើចំណែកឯកជននៃអគារសហកម្មដល់ជនបរទេស ដែលជាប្រភពមួយថ្មីដ៏កាន់តែបើកទូលាយ មួយទៀត សម្រាប់ឲ្យជនបរទេសកាន់តែមានភាពងាយស្រួល និងចង់ធ្វើដំណើរចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយសារតែឃើញពីលំហូរនៃជនបរទេសចូលមកកាន់ព្រះរាជាណាចក្រកម្ពុជាយើងកាន់តែច្រើនឡើងៗ តាមរយៈ ការធ្វើជំនួញ វិនិយោគ ពាណិជ្ជកម្ម ការងារ និងទេសចរណ៍ ដោយសារកត្តាទាំងនេះ ទើបយើងខ្ញុំទាំងពីរបានកើតមានគំនិតចង់ចងក្រងនូវប្រធានបទស្តីពីកាតព្វកិច្ច និងសិទ្ធិរបស់ជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាការយល់ដឹងអំពី កាតព្វកិច្ច និងសិទ្ធិរបស់ជនបរទេស ឲ្យបានច្បាស់លាស់ និងដើម្បីបង្កភាពងាយស្រួលក្នុងការគ្រប់គ្រងដល់ជនបរទេសដែលបានចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា និងសម្រាប់ជាជំនួយដល់ការផ្សព្វផ្សាយ ឲ្យមានការយល់ដឹង និងជ្រួតជ្រាបអំពីពត៌មានចំពោះជនបរទេសឲ្យកាន់តែមានកម្រិតខ្ពស់ និងទូលំទូលាយនៅទូទាំងប្រទេសកម្ពុជា។

យើងខ្ញុំទាំងពីរសង្ឃឹមថា ស្នាដៃមួយនេះ នឹងផ្តល់នូវផលប្រយោជន៍ដល់អ្នកអាន និងអ្នកស្រាវជ្រាវ យល់ដឹងអំពីជនបរទេស ហើយជាពិសេស កាតព្វកិច្ច និងសិទ្ធិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍ដល់អ្នកសិក្សា អ្នកស្រាវជ្រាវ និងដល់សង្គមជាតិជាក់ជាមិនខាន។ បន្ថែមពីនេះទៅទៀត យើងខ្ញុំទាំងពីរសូមទទួលនូវការផ្តល់យោបល់ក្នុងន័យស្ថាបនា ដើម្បីកែលំអនូវរាល់កំហុសឆ្គង ដែលតែងតែកើតមានជាយថាហេតុ ពីសំណាក់មិត្តអ្នកអាន ដោយក្តីសោមនស្សរីករាយ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១ : និន្នាការឆ្ពោះទៅជនបរទេស** ........................................ ៣

**ផ្នែកទី១ : ប្រភពនីត្យានុកូលនៃបទដ្ឋានគតិយុត្ត** ........................................ ៣

**កថាខណ្ឌទី១ : ប្រភពច្បាប់អន្តរជាតិ** ........................................ ៣

ក. សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្ស ........................................ ៣

ខ. អនុសញ្ញាអន្តរជាតិស្តីពីឋានៈជនភៀសខ្លួន ........................................ ៤

គ. សន្ធិសញ្ញាក្នុងតំបន់ និង ក្រៅតំបន់ ........................................ ៥

**កថាខណ្ឌទី២ : ប្រភពច្បាប់ជាតិ** ........................................ **៦**

ក. ច្បាប់ស្តីពីអន្តោប្រវេសន៍ ........................................ ៦

ក.១. អនុក្រឹត្យលេខ ៧៥ ស្តីពី បែបបទសម្រាប់អនុវត្តន៍ចំពោះការអនុញ្ញាតឲ្យជនបរទេសមិនមែនអន្តោប្រវេសន៍ចេញ-ចូលនិងស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ........................................ ៦

ក.២. អនុក្រឹត្យលេខ ៣០ ស្តីពី បែបបទសម្រាប់ការអនុវត្តន៍ចំពោះការអនុញ្ញាតឲ្យជនបរទេសមិនមែនអន្តោប្រវេសន៍ចេញ-ចូល និង ស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ........................................ ៧

ក.៣. អនុក្រឹត្យលេខ ៣៧ ស្តីពីបែបបទសម្រាប់ការអនុវត្តន៍ចំពោះការអនុញ្ញាតឲ្យជនបរទេស អន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជនចេញ-ចូល និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ........................................ ៧

ក.៤. អនុក្រឹត្យលេខ ២៩ ស្តីពីការសុំទារកកំព្រា ឬ កុមារយកទៅចិញ្ចឹមជាកូននៅឯបរទេស ........................................ ៧

ក.៥. ប្រកាសលេខ ៥៥៥ ស្តីពីគ្រប់គ្រងលើការផ្ទេកប័ណ្ណស្នាក់នៅសម្រាប់ជនបរទេស ........................................ ៧

ខ. ច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ........................................ ៧

គ. ច្បាប់ស្តីពីការផ្តល់សិទ្ធកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស.......... ៨

ឃ. ច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ........................................ ៨

**កថាខណ្ឌទី៣ :ប្រភេទជនបរទេសដែលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា** ................ **៨**

ក. ជនបរទេសមិនមែនអន្តោប្រវេសន៍ ........................................ ៩

ក.១. ប្រភេទនៃជនបរទេសមិនមែនអន្តោប្រវេសន៍ ........................................ ៩

ក.២. លក្ខខណ្ឌនៃការស្នាក់នៅ ........................................................................ .......៩
ខ. ជនបរទេសអន្តោប្រវេសន៍ ........................................................................១០
គ. ជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន ........................................................................១១
គ១. ជនបរទេសដែលចូលមកកម្ពុជាដើម្បីត្រួតពិនិត្យលទ្ធភាពនៃការធ្វើវិនិយោគ....................១១
គ២. ជនបរទេសដែលទទួលលិខិតអនុញ្ញាតឲ្យវិនិយោគ........................................................................១២
**ផ្នែកទី២** : **បទដ្ឋានគតិយុត្តទាក់ទងនឹង ជនបរទេស**........................................................................**១២**
**កថាខណ្ឌទី១** : **លិខិតឆ្លងដែន និង ទិដ្ឋាការ**........................................................................**១២**
ក. និយមន័យ ........................................................................១២
ខ. ប្រភេទអាករ និង ការពន្យាទិដ្ឋាការ .. ........................................................................១៣
ខ.១. ប្រភេទ ........................................................................១៣
ខ.២. អាករទិដ្ឋាការ . ........................................................................១៤
ខ.៣. ការពន្យាពេលទិដ្ឋាការ ........................................................................១៥
**កថាខណ្ឌទី២** : **ការចេញ-ចូលនិងការស្នាក់នៅស្របច្បាប់របស់ជនបរទេស**..............**១៦**
ក. បែបបទនៃការសុំចូល . ........................................................................១៦
ខ. ប្រភេទប័ណ្ណស្នាក់នៅបណ្តោះអាសន្ន........................................................................១៨
ខ.១. ប័ណ្ណស្នាក់នៅបណ្តោះអាសន្ន ........................................................................១៨
ខ.២. ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍........................................................................១៨
គ. ការដកហូតលក្ខណៈសម្បត្តិជាជនបរទេសអន្តោប្រវេសន៍ និងប័ណ្ណស្នាក់នៅ.......................១៩
ឃ. ការហាមឃាត់មិនឲ្យចូល និង ការមិនអនុញ្ញាតឲ្យស្នាក់នៅ ........................................................................១៩
**ជំពូកទី ២**: **អានុភាពគតិយុត្តនៃសិទ្ធិ និងភារកិច្ចរបស់ជនបរទេស**
**នៅក្នុងព្រះរាជាណាចក្រកម្ពុជា** ........................................................................**២១**
**ផ្នែកទី១** : **អានុភាពដោយផ្ទាល់យោងតាមទ្រឹស្តី** ........................................................................**២១**
**កថាខណ្ឌទី១** : **អានុភាពទាក់ទងនឹងបណ្តាសិទ្ធិនានាចំពោះលក្ខន្តិកៈសាមញ្ញ**
**នៃជនបរទេស** ........................................................................**២២**
ក. សិទ្ធិទទួលបានសញ្ជាតិខ្មែរតាមរយៈកំណើត........................................................................២២
ក១. សិទ្ធិទទួលបានសញ្ជាតិខ្មែរតាមរយៈខ្សែលោហិត ........................................................................២២
ក២. សិទ្ធិទទួលបានសញ្ជាតិខ្មែរតាមរយៈទីកន្លែងកំណើត ........................................................................២២
ខ. ការទទួលបានសញ្ជាតិខ្មែរតាមរយៈការសុំកូនពេញលេញ........................................................................២៣
គ. ការទទួលបានសញ្ជាតិខ្មែរតាមរយៈចំណងអាពាហ៍ពិពាហ៍........................................................................២៣
ឃ.ការទទួលបានសញ្ជាតិខ្មែរតាមរយៈសញ្ជាតូបនីយកម្ម ........................................................................២៥
ឃ១. ការស្នើសុំសញ្ជាតូបនីយកម្មតាមលក្ខខណ្ឌធម្មតា........................................................................២៥

ឃ២. ការស្នើសុំសញ្ញាតូបនីយកម្មតាមលក្ខខណ្ឌពិសេស..........២៦

ង. សិទ្ធិក្នុងវិស័យការងារ ..........២៨

ច. សិទ្ធិលើវិស័យវិនិយោគ ..........២៨

ឆ. សិទ្ធលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ..........២៩

**កថាខណ្ឌទី២ : អានុភាពពាក់ព័ន្ធនឹង បណ្តាសិទ្ធិនានាចំពោះលក្ខន្តិកៈពិសេសនៃជនបរទេស..........២៩**

ក. ភ្នាក់ងារបម្រើការនៅស្ថានទូត..........៣០

ខ. អង្គការអន្តរជាតិ ឬស្ថាប័នអន្តរជាតិ ..........៣០

គ. គ្រូពេទ្យគ្មានព្រំដែន ..........៣១

**ផ្នែកទី២ : ផលវិបាក និងទណ្ឌកម្មពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិជនបរទេស ..........៣១**

**កថាខណ្ឌទី១ : ដែលកំណត់នៃសិទ្ធិរបស់ជនបរទេស ..........៣១**

ក. ចំពោះជនបរទេសសាមញ្ញ..........៣១

ក.១. មូលហេតុនៃការឃាត់ខ្លួន..........៣១

ក.២. ស្ថានភាពនៃការឃាត់ខ្លួនបណ្តោះអាសន្ន ..........៣២

ក.៣. ការពិន័យ និងការដាក់ទោសព្រហ្មទណ្ឌ ..........៣៣

ខ. អញ្ញត្រកម្ម ..........៣៦

**កថាខណ្ឌទី២:ដែនកំណត់នៃសិទ្ធិចំពោះអង្គការអន្តរជាតិ ឬស្ថាប័នអន្តរជាតិ ..........៣៧**

ក. គោលការណ៍ទូទៅ ..........៣៧

ខ. អញ្ញត្រកម្ម ..........៣៧

**សេចក្តីសន្និដ្ឋាន..........៣៩**

**អនុសាសន៍ ..........៤០**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅក្នុងពិភពលោកប្រទេសនីមួយៗតែងតែមានល្បាយជាតិសាសន៍ចម្រុះគ្នា ហើយតិច ឬច្រើន គឺអាស្រ័យទៅតាមស្ថានភាពនៃប្រទេសនោះមានន័យថាក្នុងប្រទេសនោះនីមួយៗមានប្រជាពលរដ្ឋរស់នៅចម្រុះជាតិសាសសន៍ មិនមែនមានតែប្រជាពលរដ្ឋរបស់ខ្លួន(ម្ចាស់ប្រទេស)ប៉ុណ្ណោះទេ ប៉ុន្តែក៏មានប្រជាពលរដ្ឋដ៏ច្រើននៃប្រទេសដទៃ គឺរស់នៅលាយលំគ្នាដែរ។ ហេតុនេះហើយបានជាការតាក់តែងលិខិតបទដ្ឋានគតិយុត្តនានា គឺមានការវិវត្តន៍យ៉ាងខ្លាំងក្លា និងបត់បែនទៅតាមស្ថានភាពនៃសង្គមដើម្បីមានភាពងាយស្រួលក្នុងការគ្រប់គ្រង និងកំណត់ប្រភេទនៃជនបរទេសទាំងនោះ ជាពិសេស ដើម្បីកំណត់ថា ជនណាខ្លះជាជនអន្តោប្រវេសន៍ដែលស្របច្បាប់ហើយជនណាខ្លះដែលជាជនអន្តោប្រវេសន៍មិនស្របច្បាប់ក្នុងគោលបំណងធានាបាននូវ សណ្តាប់ធ្នាប់ និងភាពថ្លៃថ្នូរនៅក្នុងសង្គមជាតិ។

នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងវិញ គឺមានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលមានដូចជា រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដែលត្រូវបានបង្កើតឡើង ក្នុងការរៀបចំ និងប្រព្រឹត្តទៅនៃច្បាប់ ដើម្បីកំណត់ជនអន្តោប្រវេសន៍ ដើម្បីញែកជនបរទេសទាំងនោះឲ្យបានច្បាស់ ងាយស្រួលក្នុងការអនុវត្តច្បាប់ទៅលើជនទាំងនោះ។ ការកំណត់របស់ច្បាប់ខ្មែរមានដូចខាងក្រោម ៖

ជនបរទេស គឺសំដៅដល់ជនដែលបានមករស់នៅ ឬស្នាក់នៅក្នុងប្រទេសណាមួយ ហើយដោយគ្មានបានទទួលនូវសញ្ជាតិពីប្រទេសដែលខ្លួនកំពុងរស់នៅនោះទេ។ ជនប្រភេទនេះ បានធ្វើដំណើរចាកចេញពីស្រុកកំណើតរបស់ខ្លួន ឬពីប្រទេសដែលខ្លួនកាន់សញ្ជាតិ ហើយដែលបានចូលមករស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងផ្សេងៗដូចជាការបំពេញបេសកកម្មការទូត ឬក៏បេសកម្មនៅក្នុងក្របខណ្ឌរដ្ឋ ឬអង្គការអន្តរជាតិនានា ឬការធ្វើទេសចរណ៍ ឬការធ្វើដំណើរឆ្លងកាត់ក្នុងគោលបំណងឆ្លងកាត់ទៅកាន់ប្រទេសទីបីជាដើម។

ជនអន្តោប្រវេសន៍ គឺជាជនដែលបានចាកចេញពីស្រុកកំណើត ឬប្រទេសរបស់ខ្លួន ហើយបានមករស់នៅក្នុងប្រទេសដទៃផ្សេងទៀតក្នុងរយៈពេលណាមួយ ដើម្បីប្រកបរបរចិញ្ចឹមជីវិតៈ ឬការធ្វើវិនិយោគទុន ឬការធ្វើពាណិជ្ជកម្ម ឬធ្វើសកម្មភាពផ្សេងៗទាក់ទងផ្នែកពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម ជាដើម។

ដូចនេះ តាមការសង្កេតឃើញថា ជនអន្តោប្រវេសន៍ក៏ជាជនបរទេសដែរ ប៉ុន្តែគ្រប់ជនបរទេសមិនមែនសុទ្ធតែជាជនអន្តោប្រវេសន៍នោះឡើយ។

ម៉្យាងវិញទៀត នៅក្នុងប្រទេសនីមួយៗ គឺតែងតែមាន ម្ចាស់ស្រុក ជនជាតិដើម ជនជាតិភាគតិច និងជនបរទេស។ តើជនបរទេសអាចជាជនជាតិដើមភាគតិចដែរទេ? ឬផ្ទុយមកវិញតើជនបរទេស និងជនជាតិដើមភាគតិចមានលក្ខណៈសម្បត្តិដូចគ្នាដែរទេ?

ជនជាតិដើម ឬជនជាតិភាគតិច គឺសំដៅដល់មនុស្សមួយក្រុម ដែលបានរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិ

របៀបរស់នៅតាមទំនៀមទម្លាប់ប្រពៃណី និងការដាំដុះ ដែលខ្លួនបានប្រកាន់ខ្ជាប់ទៅតាមក្បួនខ្នាត តាមទំនៀម ទំលាប់នៃការប្រើប្រាស់ជាសមូហភាព។

បើយោងតាមនិយមន័យ ដែលបានលើកឡើងខាងលើនេះ យើងឃើញថា ចំណុចរួមរបស់ជនបរទេស និងជនជាតិដើមភាគតិចគឺមានភាសាកំណើតផ្ទាល់ខ្លួន និងប្រពៃណី វប្បធម៌ខុសពីម្ចាស់ប្រទេស មិនតែប៉ុណ្ណោះ ក៏មានចំណុចប្លែកពីគ្នាផងដែរត្រង់ថាជនបរទេសមិនមានសញ្ជាតិខ្មែរ ពោលគឺមានសញ្ជាតិនៃប្រទេសកំណើត របស់ខ្លួន។ រីឯជនជាតិដើមភាគតិចមានសញ្ជាតិនៃប្រទេសខ្មែរ និងជាជនជាតិដើមរបស់ខ្មែរ។

ដោយយោងតាមលិខិតបទដ្ឋានគតិយុត្ត ដែលមានជាធរមាននៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា គឺ បានទទួលស្គាល់ថា ជនជាតិដើមភាគតិចមានសិទ្ធិ និងកាតព្វកិច្ច ក្នុងនាមជាពលរដ្ឋខ្មែរពេញសិទ្ធិ។ រីឯជន បរទេសគឺជាជនអន្តោប្រវេសន៍។

នៅក្នុងការសិក្សាទាក់ទងទៅនឹងប្រធានបទនេះ យើងខ្ញុំត្រូវបានបែងចែកចេញជាពីរជំពូកគឺជំពូកទី១ សិក្សាអំពី ទិដ្ឋភាពទូទៅនៃជនបរទេស និងជំពូកទី២ សិក្សាអំពីអានុភាពគតិយុត្តនៃសិទ្ធិ កាតព្វកិច្ច និងផល វិបាក ។

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃជនបរទេស

វត្តមាននៃជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺបានកើតមានឡើង តាមរយៈប្រភពច្បាប់ជាធរមាន ដែលចំណុចនេះ នៅក្នុងសម័យរបបប្រល័យពូជសាសន៍ពុំមានទាល់តែសោះ ប៉ុន្តែជនបរទេសដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន មានចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ និងពោរពេញទៅដោយចម្រុះជាតិសាសន៍។

ហេតុដូច្នេះ នៅក្នុងជំពូកនេះ យើងខ្ញុំនឹងធ្វើការវិភាគយ៉ាងលំអិតទៅលើប្រភពនីត្យានុកូល ឬប្រភពច្បាប់ដែលនៅជាធរមាន ហើយកំពុងអនុវត្ត និងបន្តការអនុវត្តនៅក្នុងប្រទេសទៅថ្ងៃអនាគត។

## ផ្នែកទី១ : ប្រភពនីត្យានុកូលនៃបទដ្ឋានគតិយុត្ត

មហិច្ឆតារបស់មនុស្ស តែងតែកើតមាននូវតម្រូវការឥតឈប់ឈរ ក៏ប៉ុន្តែ តម្រូវការដំបូងដែលចាំបាច់បំផុតសម្រាប់ជីវិតនោះគឺអាហារ។ អាហារជាវត្ថុដ៏សំខាន់សម្រាប់ទ្រទ្រង់ជីវិតមនុស្សគ្រប់ៗរូប ដើម្បីបានអាហារគ្រប់គ្រាន់តាមតម្រូវការ មនុស្សត្រូវតែខិតខំស្វែងរកគ្រប់វិធី និងទីកន្លែង ដែលអំណោយផលសម្រាប់ការចិញ្ចឹមជីវិត។ ក្រៅពីអាហារមនុស្សនៅត្រូវការសិទ្ធិ សេរីភាព និងធាតុសម្ភារនិយម(ទ្រព្យសម្បត្តិ)ផ្សេងៗទៀត។ កត្តាទាំងនេះហើយដែលជំរុញឲ្យមនុស្សនៅលើពិភពលោក ធ្វើការផ្លាស់ប្តូរកន្លែងរស់នៅរបស់ពួកគេ ដើម្បីស្វែងរកកន្លែងណាដែលអាចផ្តល់ ឬបំពេញតម្រូវការរបស់ពួកគេ។

ដោយសារតែការបំលាស់ទីរបស់ពួកគេពីកន្លែងមួយទៅកន្លែងមួយ និងពីប្រទេសមួយទៅប្រទេសមួយទៀត ទើបបានជាបទដ្ឋានគតិយុត្តមួយចំនួនត្រូវបានបង្កើតដើម្បីគ្រប់គ្រង និងគាំពារទៅលើមនុស្សទាំងនោះ។

បច្ចុប្បន្នភាព សិទ្ធិ សេរីភាព របស់ជនចំណូលស្រុកមានលក្ខណៈល្អប្រសើរ ហើយដោយសារប្រទេសជាម្ចាស់ស្រុកទាំងឡាយនៅលើពិភពលោក បានផ្តល់សិទ្ធិមួយចំនួនធំដល់ជនចំណាកស្រុក ដោយចាត់ទុកថាអ្នកទាំងនោះជាជនបរទេស និងដោយសារតែពិភពលោកទាំងមូល ទទួលយកនូវសន្ធិសញ្ញាអន្តរជាតិមួយចំនួនដែលអាចការពារដល់ជនទាំងនោះ។

### កថាខណ្ឌទី១: ប្រភពច្បាប់អន្តរជាតិ

#### ក. សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស

សេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្សដែលត្រូវបានអនុម័ត និងបានប្រកាស ដោយសេចក្តីសម្រេចនៃមហាសន្និបាទរបស់អង្គការសហប្រជាជាតិ លេខ២១៧ ចុះនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ដែលសេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្សរួមមានចំនួន៣០មាត្រា។

សេចក្តីប្រកាសនេះបានកំណត់យ៉ាងច្បាស់ស្តីពីសិទ្ធិមនុស្សដែលត្រូវបានគាំពារ និងទទួលយកដោយរដ្ឋ ដែលជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញានេះ។

សិទ្ធិមនុស្សគឺជាអំណាចរបស់ប្រជាពលរដ្ឋតាំងពីចាប់កំណើតមកម្លេះ។ សិទ្ធិនេះ គឺត្រូវបានឪពុកម្តាយជាអ្នកផ្តល់ឲ្យយើងមនុស្សគ្រប់រូបគឺមានសិទ្ធិធ្វើដំណើរដោយសេរី និងមានសិទ្ធិជ្រើសរើស និងវេសនដ្ឋានក្នុងរដ្ឋមួយ។

មនុស្សគ្រប់រូបមានសិទ្ធិចាកចេញ ពីប្រទេសណាមួយរួមទាំងប្រទេសរបស់ខ្លួនផង និងមានសិទ្ធិវិលត្រឡប់មកប្រទេសរបស់ខ្លួនវិញ។[1]

សិទ្ធិដើរដោយសេរីនេះហើយ ដែលជាហេតុនាំឲ្យមានការលំហូរចូលនៃជនបរទេស។ ដោយសារជនទាំងនោះមានសិទ្ធិទាំងនេះ ទើបពួកគេមិនខ្លាចញញើតចំពោះបញ្ហាអសន្តិសុខ ឬក៏ត្រូវបានអាជ្ញាធរនៃប្រទេសដែលខ្លួនកំពុងស្នាក់នៅធ្វើទារុណកម្ម ឬចាប់ចងដោយសារការរើសអើងជាតិសាសន៍ ពណ៌សម្បុរផ្សេងៗជាដើម។

## ខ. អនុសញ្ញាអន្តរជាតិស្តីពីឋានៈជនភៀសខ្លួន

អនុសញ្ញាអន្តរជាតិស្តីពីឋានៈជនភៀសខ្លួន ត្រូវបានអនុម័តនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥១ និងបានចូលជាធរមាននៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៥៤ ក៏ជាប្រភពមួយដ៏សំខាន់ដែរ ក្នុងការនាំយក ឬលំហូរចូលនៃជនបរទេសចូលមកក្នុងប្រទេសដោយសារតែ ការគេចវេសពីសំណាក់ ការធ្វើទុកបុកម្នេញខាងផ្នែកនយោបាយ សាសនា ជម្លោះដោយប្រដាប់អាវុធ ឬសង្គ្រាម ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ រើសអើង និងការចោទប្រកាន់ផ្សេងៗ។ ទាំងអស់នេះហើយដែលបង្កើតឲ្យមានឋានៈនៃជនភៀសខ្លួន។

ជនភៀសខ្លួន គឺជាជនដែលបានបង្ខំចិត្តចាកចេញពីស្រុកកំណើត ឬចេញពីប្រទេសមួយ ទៅជ្រកកោននៅក្នុងប្រទេសមួយផ្សេងទៀត ដែលមានស្ថានភាពល្អ និងប្រសើរជាង ដើម្បីគេចវេសពីសង្គ្រាម បញ្ហានយោបាយ ជំនឿសាសនា និងសាសនាជាដើម។

ជនភៀសខ្លួនទាំងនោះ មិនត្រូវបានគេចាត់ទុកថា ជាជនអន្តោប្រវេសន៍នោះទេ ក៏ប៉ុន្តែពួកគេត្រូវការការពារដោយបញ្ញត្តិច្បាប់របស់អង្គការសហប្រជាជាតិ ហើយស្ថាប័នទាំងនេះបានធ្វើអន្តរាគមន៍យ៉ាងសកម្ម។ ហើយគោលការណ៍គ្រឹះនៃអនុសញ្ញានេះ គឺកិច្ចគាំពារតាមផ្លូវច្បាប់ចំពោះរូបវន្តបុគ្គល និងនីតិបុគ្គល។

**ឧទាហរណ៍:**

ជនភៀសខ្លួនខ្មែរ ដែលបានចាកចេញពីប្រទេសកម្ពុជា នៅក្នុងកាលពីអំឡុងទសវត្សរ៍ឆ្នាំទី១៩៧០ទៅស្នាក់នៅតាមជំរុំព្រំដែនប្រទេសកម្ពុជាថៃត្រូវបានទទួលការឧបត្ថម្ភ និងការគាំពារពីសំណាក់អង្គការសហប្រជាជាតិ រហូតមកដល់ឆ្នាំ១៩៩៣ ។ អង្គការកាកបាទក្រហមអន្តរជាតិ ក៏បានជួយយ៉ាងសកម្មដល់ជនភៀសខ្លួននេះផងដែរ ។

[1] មាត្រា១៣នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

**ឧទាហរណ៍** មួយទៀត ដែលព្រះរាជាណាចក្រកម្ពុជា ព្រមទទួលយកអតីតនាយករដ្ឋមន្ត្រីថៃ ថាក់ស៊ុន ឲ្យចូលមកស្នាក់នៅក្នុងទឹកដីកម្ពុជាក្នុងនាមជាជនភៀសខ្លួនផ្នែកនយោបាយ ។

**គ.សន្ធិសញ្ញាក្នុងតំបន់(អាស៊ាន) និងក្រៅតំបន់**

ចំពោះប្រទេសមួយចំនួនទៀត ក៏ត្រូវបានលើកលែងនូវទិដ្ឋាការចូលក្នុងប្រទេសកម្ពុជា ហើយកំណត់កាលបរិច្ឆេទនៃរយៈពេលស្នាក់នៅខ្លី ឬស្នាក់នៅរយៈពេលវែង រហូតដល់បញ្ជប់បេសកកម្មទៅតាមប្រភេទនីមួយៗនៃការព្រមព្រៀង រវាងប្រទេសជាហត្ថលេខី ហើយក៏មានបណ្តាប្រទេសខ្លះ ត្រូវសុំទិដ្ឋាការចូលក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ ។

បណ្តាប្រទេស ដែលជាប្រទេសហត្ថលេខីនៃការលើកលែងទិដ្ឋាការចូលក្នុងព្រះរាជាណាចក្រកម្ពុជា:

| ល.រ | ប្រទេស | លិខិតឆ្លងដែន | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ការទូត | ផ្លូវការ | ធម្មតា | |
| ប្រទេសជាសមាជិកអាស៊ាន : | | | | | |
| ១ | ព្រុយណេ | ១៤ថ្ងៃ | ១៤ថ្ងៃ | 0 | |
| ២ | ឥណ្ឌូណេស៊ី | ១៤ថ្ងៃ | ១៤ថ្ងៃ | 0 | ដោយឡែកអ្នកបំពេញបេសកកម្មការទូតគឺត្រូវស្នើសុំទិដ្ឋាការជាមុន |
| ៣ | ឡាវ | ៣០ថ្ងៃ | ៣០ថ្ងៃ | ៣០ថ្ងៃ | |
| ៤ | ម៉ាឡេស៊ី | ៣០ថ្ងៃ | ៣០ថ្ងៃ | ៣០ថ្ងៃ | |
| ៥ | មីយ៉ាន់ម៉ា | ៣០ថ្ងៃ | ៣០ថ្ងៃ | 0 | |
| ៦ | ភីលីពីន | ៣០ថ្ងៃ | ៣០ថ្ងៃ | ២១ថ្ងៃ | |
| ៧ | សិង្ហបូរី | ៣០ថ្ងៃ | ៣០ថ្ងៃ | ៣០ថ្ងៃ | ចាប់អនុវត្ត ០១-០១-២០០៦ |
| ៨ | ថៃ | ៣០ថ្ងៃ | ៣០ថ្ងៃ | 0 | |
| ៩ | វៀតណាម | ៩០ថ្ងៃ | ៩០ថ្ងៃ | 0 | |
| បណ្តាលប្រទេសផ្សេងៗ : | | | | | |
| ១ | ប៊ុលហ្គារី | ៩០ថ្ងៃ | ៩០ថ្ងៃ | 0 | |
| ២ | ហុងគ្រី | ៩០ថ្ងៃ | ៩០ថ្ងៃ | 0 | |
| ៣ | ចិន | ៣០ថ្ងៃ | ៣០ថ្ងៃ | 0 | លេខ៦០០០កបទ.សអ.ច្បក១ ០៤-០៩-០៦ អនុវត្ត ១៤-៩-០៦ |

| | | | | | |
|---|---|---|---|---|---|
| ៤ | ឥណ្ឌា | ៦០ថ្ងៃ | ៦០ថ្ងៃ | 0 | |
| ៥ | កូរ៉េខាងត្បូង | ៦០ថ្ងៃ | ៦០ថ្ងៃ | 0 | |
| | | | | | ០៦អនុវត្ត ២១-១២-០៦ |
| ៦ | គូបា | ក្នុងរយះពេលបំពេញបេសកកម្ម | | | |
| ៧ | រុស្សី | ក្នុងរយះពេលបំពេញបេសកកម្ម | | | |
| ៨ | ស្លូវ៉ាគី | ក្នុងរយះពេលបំពេញបេសកកម្ម | | | |

**កថាខណ្ឌទី២: ប្រភពច្បាប់ជាតិ**

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជា បានខិតខំយកចិត្តទុកដាក់លើបញ្ហាអន្តោប្រវេសន៍ត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីអន្តោប្រវេសន៍ ចុះនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤ និងដោយលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត ដូចជា អនុក្រឹត្យ ប្រកាស និងសារាចរណែនាំជាដើម ។

**ក.ច្បាប់ពីអន្តោប្រវេសន៍**

ច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤ ត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងលើជនបរទេសដែលរស់នៅលើទឹកដីព្រះរាជាណាចក្រកម្ពុជាយើង។ ច្បាប់នេះ បានបែងចែកជនបរទេសជាបីប្រភេទគឺ ជនបរទេសមិនមែនអន្តោប្រវេសន៍ ជនបរទេសជាជនអន្តោប្រវេសន៍ និងជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន។

ច្បាប់នេះបានបញ្ញត្តិផងដែរ ចំពោះជនបរទេសដែលបានប្រព្រឹត្តល្មើសច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង អំពីនីតិវិធីនៃការបណ្តេញចេញជនបរទេសខុសច្បាប់។

ចំពោះលិខិតបទដ្ឋានគតិយុត្តខាងក្រោមរួមមាន :

**ក.១.អនុក្រឹត្យលេខ៧៥ស្តីពីបែបបទសម្រាប់ការអនុវត្តចំពោះការអនុញ្ញាតឲ្យជនបរទេសមិនមែនអន្តោប្រវេសន៍ចេញ-ចូល និងការស្នាក់អាស្រ័យក្នុងប្រទេសកម្ពុជា**

អនុក្រឹត្យលេខ៧៥អ.ន.ក្រ.ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៩ ដែលស្តីពីបែបបទសម្រាប់ការអនុវត្តចំពោះការ អនុញ្ញាតឲ្យជនបរទេសមិនមែនជាជនអន្តោប្រវេសន៍ចេញ ឬចូល និងការស្នាក់អាស្រ័យក្នុងប្រទេសកម្ពុជា។

អនុក្រឹត្យនេះ បានបញ្ញតិអំពីបែបបទសម្រាប់ការចេញ-ចូល និងការស្នាក់អាស្រ័យនៃជនបរទេស ដែលជាជនមិនមែនអន្តោប្រវេសន៍ ក្នុងព្រះរាជាណាចក្រកម្ពុជាអំពីប្រភេទនៃទិដ្ឋាការ រយះពេលទិដ្ឋាការ អាករទិដ្ឋាការ

អំពីការចេញ ការពន្យាពេល ការបដិសេធទិដ្ឋាការ និងការស្នាក់នៅបណ្តោះអាសន្ន និងអំពីការហាមឃាត់មិនឲ្យចូល មិនឲ្យស្នាក់នៅបណ្តោះអាសន្ន និងអំពីទោសបញ្ញត្តិ ។

**ក.២.អនុក្រឹត្យលេខ៣០ស្តីពីបែបបទសម្រាប់ការអនុវត្តចំពោះការអនុញ្ញាតឲ្យជនបរទេស អន្តោប្រវេសន៍ចេញ-ចូល និងស្នាក់អាស្រ័យក្នុងព្រះរាជាណាចក្រកម្ពុជា**

ចំពោះជនបរទេសជាជនអន្តោប្រវេសន៍ យើងឃើញមានអនុក្រឹត្យលេខ៣០ អ.ន.ក្របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៦ស្តីពីបែបបទសម្រាប់ការអនុវត្តចំពោះការអនុញ្ញាតឲ្យជនបរទេស ដែលជាជនអន្តោប្រវេសន៍ចេញ-ចូល និងស្នាក់អាស្រ័យក្នុងព្រះរាជណាចក្រកម្ពុជា។

អនុក្រឹត្យនេះ បញ្ញតិអំពីបែបបទក្នុងការសុំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ការស្នាក់នៅ ឬការបំពេញការងារ ការចេញ-ចូល ការដកហូតលក្ខណៈសម្បត្តិជាជនបរទេសអន្តោប្រវេសន្ត។

**ក.៣.អនុក្រឹត្យលេខ៣៧ស្តីពីបែបបទសម្រាប់ការអនុវត្តចំពោះការអនុញ្ញាតឲ្យជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជនចេញ-ចូល និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា**

ចំពោះជនបរទេសអន្តោប្រវេសន៍ ជាអ្នកវិនិយោគឯកជន យើងឃើញមាន អនុក្រិត្យលេខ ៣៧ អ.ន.ក្រ. ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៦ ស្តីពីបែបបទសម្រាប់ការអនុវត្តចំពោះការអនុញ្ញាតិឲ្យជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជនចេញ-ចូល និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះ គឺបានបញ្ញតិអំពីការសុំចូលមកស្នាក់អាស្រ័យ នៅក្នុងព្រះរាជាណាក្រកម្ពុជា និងការដកហូតលក្ខណៈសម្បត្តិជនអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន។

**ក.៤.អនុក្រឹត្យលេខ២៩ស្តីពីការសុំទារកកំព្រា ឬកុមារយកទៅចិញ្ចឹមជាកូននៅបរទេស**

ចំពោះជនបរទេសណាដែលមានបំណងស្នើសុំទារកកំព្រា ឬកុមារកំព្រានៅក្នុងព្រះរាជាណាចក្រកម្ពុជាយកទៅចិញ្ចឹមនៅឯបរទេស ដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្ត ជាពិសេសអនុក្រឹត្យលេខ២៩អនក្រ.បក ចុះថ្ងៃទី១៤ខែមីនា ឆ្នាំ២០០១ បានបញ្ញត្តិអំពីសមត្ថកិច្ច លក្ខខណ្ឌ និងនីតិវិធីនៃការសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមនៅឯបរទេស និងការកំណត់អំពីបន្ទុករបស់សាមីជនដែលស្នើសុំ។

**ក.៥. ប្រកាសលេខ៥៥៥ស្តីពីការគ្រប់គ្រងលើការធ្វើប័ណ្ណស្នាក់នៅ**

ចំណែក ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចេញប្រកាសលេខ ៥៥៥ ប្រ.ក ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលើការធ្វើប័ណ្ណស្នាក់នៅសម្រាប់ជនបរទេស។

ប្រកាសនេះ បានបញ្ញតិអំពីប្រភេទប័ណ្ណស្នាក់នៅបណ្តោះអាសន្ន និងប័ណ្ណស្នាក់នៅជាអចិន្ត្រៃយ៍ និងអំពីទម្រង់បែបបទពីការសុំប័ណ្ណស្នាក់នៅ និងអំពីសុពលភាព និងការដកហូតប័ណ្ណស្នាក់នៅ។

**ខ. ច្បាប់ស្តីពីការវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា**

ច្បាប់ស្តីពីវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា គឺចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៤ ត្រូវបានបង្កើតឡើង

ក្នុងគោលបំណងដើម្បីគ្រប់គ្រងទៅលើបញ្ហាវិនិយោគទុននៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអ្នកវិនិយោគជនជាតិបរទេស និងអ្នកវិនិយោគជនជាតិខ្មែរផងដែរ។

នៅក្នុងច្បាប់នេះបានបញ្ញត្តិនៅក្នុងមាត្រាមួយចំនួនផងដែរ អំពីលក្ខខណ្ឌដែលត្រូវតម្រូវឲ្យបំពេញនៅពេលដែលជនបរទេសមានបំណងចង់មកធ្វើការវិនិយោគទុន នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងអ្នកវិនិយោគទុន ដែលបានចូលមកវិនិយោគទុនរួចមកហើយ ។

**គ.ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិដល់ជនបរទេស**

ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើកម្មសិទ្ធិ ចំណែកឯកជននៃអាគារសហកម្មសិទ្ធិដល់ជនបរទេស ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ គឺរួមមាន២៤មាត្រា ដែលទើបតែប្រកាសឲ្យប្រើប្រាស់ក្នុងពេលថ្មីៗនេះ គឺបានរួមចំណែកយ៉ាងសំខាន់ដល់វិស័យសេដ្ឋកិច្ច វិស័យវិនិយោគ និងធ្វើឲ្យទីផ្សារអចលទ្រព្យនៅក្នុងប្រទេសកម្ពុជា គឺមានភាពល្អប្រសើរឡើងវិញ មិនតែប៉ុណ្ណោះ គឺបានលើកទឹកចិត្តដល់ជនបរទេសនានាមានទឹកចិត្តសប្បាយរីករាយ ហើយមានបំណងចង់ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ឃ. ច្បាប់ស្តីពីការងារនៅព្រះរាជាណាចក្រកម្ពុជា**

ច្បាប់ស្តីអំពីការងារនៅព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧ រួមមាន៣៩៦មាត្រា ហើយច្បាប់នេះត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងលើបញ្ហាការងារ ដែលមាននៅលើទឹកដីកម្ពុជា។ ដោយយោងតាមជំពូកទី១០ ផ្នែកទី២នៃច្បាប់ស្តីពីការងារ ឃើញមានបញ្ញតិពីជនបរទេសដែរត្រង់ចំនុច" ការប្រើប្រាស់ហត្ថកម្មបរទេស " ។ នេះគឺសបញ្ជាក់ឲ្យឃើញថា សូម្បីតែច្បាប់ការងាររបស់ប្រទេសកម្ពុជាយើង ក៏បានបើកផ្លូវមួយចំនួនដល់ជនបរទេស អាចចូលមកស្នាក់នៅ ក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនាមជាកម្មករ និយោជិក ឬបុគ្គលិក នៅតាមបណ្តារោងចក្រសហគ្រាសនីមួយៗជាដើម។

ទោះបីជាលក្ខខណ្ឌច្បាប់ ត្រូវបានកំណត់ច្បាស់លាស់ទាំងប្រភពច្បាប់ជាតិ និងប្រភពច្បាប់អន្តរជាតិយ៉ាងណាក៏ដោយ ក៏លំហូរចូលជនបរទេសទាំងនោះ នៅមានកម្រិតនៅឡើយ ប៉ុន្តែមូលហេតុចម្បងនៃលំហូរចូលនៃជនបរទេសទាំងនោះចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាគឺបានស្វែងចេញពីផលប្រយោជន៍ច្រើនយ៉ាង និងមានប្រភេទបរទេសខុសៗគ្នា។ការបកស្រាយលើចំណុចនេះ និងបន្តក្នុងកថាខណ្ឌបន្ទាប់ ។

**កថាខណ្ឌទី៣: ប្រភេទជនបរទេសដែលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា**

បើយោងតាមច្បាប់ស្តីអំពីអន្តោប្រវេសន៍ ដោយអនុលោមតាមលក្ខខណ្ឌនៃជនអន្តោប្រវេសន៍ និងការស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជាជនបរទេសត្រូវបានបែងចែកជា៣ប្រភេទគឺ:

-ជនបរទេសមិនមែនអន្តោប្រវេសន៍

-ជនបរទេសអន្តោប្រវេសន៍

-ជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន។[2]

**គ. ជនបរទេសមិនមែនជាជនអន្តោប្រវេសន៍**

**គ.១. ប្រភេទនៃជនបរទេសមិនមែនអន្តោប្រវេសន៍**

ត្រូវបានចាត់ទុកជាជនបរទេសមិនមែនអន្តោប្រវេសន៍ ៈ

- ភ្នាក់ងារដែលបានបម្រើការនៅស្ថានទូតបរទេស ឬស្ថានកុងស៊ុល ឬស្ថានតំណាងបេសកកម្មបរទេសអ្នកជំនាញការអន្តរជាតិ និងជនផ្សេងៗទៀត ដែលចូលមកព្រះរាជាណាចក្រកម្ពុជា តាមការស្នើសុំ ឬតាមកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលកម្ពុជាដោយរាប់ទាំងគ្រួសារ និងបុគ្គលិករបស់គេផងត្រូវបាន អនុញ្ញាតឲ្យស្នាក់នៅរយៈពេលដែលគេស្នាក់នៅតាមការចាំបាច់។
- ទាហ៊ាន មន្ត្រី អ្នករដ្ឋការ និយោជិត ភ្នាក់ងារបរទេស និស្សិត ព្រមទាំងក្រុមគ្រួសារ ដែលបានចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ។
- អ្នកធ្វើដំណើរឆ្លងកាត់ ឬអ្នករង់ចាំមធ្យោបាយធ្វើដំណើរ មុនពេលចេញដំណើរឆ្ពោះទៅកាន់ទិសដៅចុងក្រោយរបស់ខ្លួន។ នៅក្នុងករណីនេះ ការស្នាក់អាស្រ័យមិនត្រូវឲ្យលើសពីមួយសប្តាហ៍ឡើយលើកលែងតែករណីប្រធានសក្តិ។
- អ្នកទេសចរណ៍ដែលមានសំបុត្រត្រឡប់ទៅវិញ ហើយរយៈពេលស្នាក់នៅត្រូវកំណត់ដោយអនុក្រឹត្យ ។
- អ្នកតំណាងធនាគារពាណិជ្ជកម្ម អ្នកប្រកបមុខរបរផ្សេងៗទៀត ដែលចូលមកប្រទេសកម្ពុជា ក្នុងគោលបំណងបង្កើតទំនាក់ទំនងអំពីកិច្ចការខាងលើ។ ក្នុងករណីនេះ ការស្នាក់នៅអាស្រ័យ គឺមិនត្រូវលើសរយៈពេលពី៣ខែនោះទេ។ បើមានហេតុផលចាំបាច់ ការស្នាក់អាស្រ័យអាចបន្តទៀតបាន រយៈពេល៣ខែជាអតិបរមា តាមការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា។
- ជនបរទេស ដែលរស់នៅតាមព្រំដែនជាប់នឹងខេត្តនានារបស់ព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានការអនុញ្ញាតឲ្យឆ្លងកាត់ព្រំប្រទល់ច្រើនដង ឬមួយដងមួយកាល។
- អ្នកដំណើរ កងនាវិក និង អាកាសយានិក ដែលបានមកសំចត ដើម្បីទិញស្បៀងអាហារ នៅតាមកំពង់ផែ សមុទ្រ ឬតាមព្រលានយន្តហោះ។
- ជនបរទេសនានា ដែលមកធ្វើការនេសាទនៅតាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា ហើយដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា។

**គ.២.លក្ខខណ្ឌនៃការស្នាក់នៅ**

ជនបរទេសមិនមែនជាជនអន្តោប្រវេសន៍អាចស្នាក់នៅព្រះរាជាណាចក្រកម្ពុជាបានលុះត្រាតែ :

[2] មាត្រា៤នៃច្បាប់ស្តីពីអន្តោប្រវេសន្តចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤។

- ដោយមានការអនុញ្ញាតឲ្យចូលជាមុនពីរាជរដ្ឋាភិបាលប្រទេសកម្ពុជា គឺតាមរយៈស្ថានទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ឬតាមរយៈអាជ្ញាធរបរទេសណាមួយ ដែលតំណាងឲ្យផលប្រយោជន៍របស់កម្ពុជានៅក្រៅប្រទេស។ ចំពោះអ្នកធ្វើដំណើរឆ្លងកាត់ កងនាវិក អាកាសយានិក ការអនុញ្ញាតនេះនឹងត្រូវផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចរបស់កម្ពុជានៅពេលដែលពួកគេបានចាកចេញពីនាវា ឬព្រលានយន្តហោះ។
- ត្រូវនាំមកជាមួយនូវលិខិតឆ្លងដែន ឬឯកសារណាមួយដែលមានតម្លៃស្មើ ដែលមានចុះទិដ្ឋាការឲ្យចូលដោយអាជ្ញាធរមានសមត្ថកិច្ច។
- ត្រូវបង់ថ្លៃទិដ្ឋាការ ឬអាករនៅតាមព្រលានយន្តហោះ ឬកំពង់ផែ។

**ខ.ជនបរទេសជាអន្តោប្រវេសន៍**

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជនបរទេសប្រភេទនេះ គឺមានចំនួនច្រើនជាងគេ ដែលពួកគេបានចូលមកក្នុងប្រទេសកម្ពុជាដោយស្របច្បាប់ ដើម្បីស្នាក់នៅរយៈពេលយូរ ក្នុងគោលបំណងប្រកបរបរវិជ្ជាជីវៈ ឬធ្វើសកម្មភាពផ្សេងៗ ទាក់ទងនឹងឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្មផ្សេងៗ។

ការទទួលស្គាល់គុណសម្បត្តិជនអន្តោប្រវេសន៍របស់ជនបរទេសទាំងនោះ ត្រូវបានសម្រេច ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ជនអន្តោប្រវេសន្តទាំងនេះ គឺត្រូវបង្ហាញខ្លួននៅបុស្តិ៍ត្រួតពិនិត្យអន្តោប្រវេសន្តទាំងពេលមកដល់ និងទាំងពេលត្រឡប់ទៅវិញ។ ការទទួលឲ្យជនបរទេសមកធ្វើការងារនៅក្នុងប្រទេសកម្ពុជាយើងគឺត្រូវអនុវត្តតាមច្បាប់ការងារ នៃព្រះរាជាណាចក្រកម្ពុជា។ ភ្នាក់ងារសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ មានសិទ្ធិត្រួតពិនិត្យលើប័ណ្ណការងាររបស់ជនអន្តោប្រវេសន៍ នៅតាមបណ្តារោងចក្រ សហគ្រាស ក្រុមហ៊ុន និងនៅតាមគ្រឹះស្ថានសិក្សានានាដោយសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ជនអន្តោប្រវេសន៍អាចស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែបានបំពេញលក្ខខណ្ឌដូចជនបរទេសមិនមែនអន្តោប្រវេសន៍ និងកាតព្វកិច្ចមួយចំនួនទៀតដូចជា :

- បង្ហាញនូវសម្បទាមានប្រយោជន៍ដល់សេដ្ឋកិច្ច ឬសង្គមកិច្ច ឬវិទ្យាសាស្ត្រ ឬបច្ចេកទេស ឬវប្បធម៌សម្រាប់ព្រះរាជាណាចក្រកម្ពុជា។
- តំកល់ប្រាក់ធានាតាមចំនួនសមស្របសម្រាប់បង់ថ្លៃសោហ៊ុយក្នុងការធ្វើដំណើរត្រឡប់ទៅវិញមាតុភូមិនីវត្តន៍ជាយថាហេតុ និងមានប្រាក់ធានា ដែលអះអាងថា អាចរស់នៅបានដោយសារទ្រព្យសម្បត្តិផ្ទាល់ខ្លួន។
- មានកាយសម្បទា រឹងមាំល្អដែលអាចបំពេញវិជ្ជាជីវៈ ដោយមានការបញ្ជាក់ពីក្រុមគ្រូពេទ្យនៃប្រទេស ដែលជននោះបានចាកចេញមក និងមានកិច្ចសន្យាការងារជាលាយលក្ខ័អក្សរ។

- មានលិខិតថ្កោលទោសដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើមគេ។

បើទោះបីជាជនបរទេសអន្តោប្រវេសន៍បានបំពេញនូវលក្ខខណ្ឌដូចមានរៀបរាប់ខាងលើនេះហើយដោយ ក៏ជនទាំងនោះត្រូវបំពេញឲ្យបាននូវលក្ខខណ្ឌសន្តិសុខដែលព្រះរាជាណាចក្រកម្ពុជាបានតម្រូវឲ្យមាន។

**គ.ជនបរទេសជាជនអន្តោប្រវេសន៍ដែលជាអ្នកវិនិយោគឯកជន**

ជនបរទេសជាជនអន្តោប្រវេសន៍ ដែលជាអ្នកវិនិយោគទុនឯកជន ជាជនបរទេសដែលបានចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីធ្វើការវិនិយោគក្នុងក្របខណ្ឌនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។[3]

យោងតាមច្បាប់ស្តីពីជនអន្តោប្រវេសន្តជនបរទេសជាជនអន្តោប្រវេសន្ត ដែលជាអ្នកវិនិយោគឯកជនចែកចេញជា២ប្រភេទគឺ:

-ជនបរទេសដែលចូលកម្ពុជាដើម្បីត្រួតពិនិត្យលទ្ធភាពនៃការធ្វើវិនិយោគ

-ជនបរទេសដែលទទួលលិខិតអនុញ្ញាតឲ្យវិនិយោគពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជារួចហើយ។[4]

**គ១.ជនបរទេសដែលចូលមកកម្ពុជាដើម្បីត្រួតពិនិត្យលទ្ធភាពនៃការធ្វើវិនិយោគ**

ជនបរទេសដែលចូលក្នុងប្រទេសកម្ពុជា ដើម្បីត្រួតពិនិត្យលទ្ធភាពនៃការធ្វើវិនិយោគទុន(ប្រភេទ១) ចាំបាច់ត្រូវបំពេញលក្ខខណ្ឌទាំងឡាយ ដូចដែលមានចែងក្នុងជំពូកទី៣នៃច្បាប់ស្តីពីអន្តោប្រវេសន៍ មានន័យថាដូចគ្នាទៅនឹងលក្ខខណ្ឌ ដែលបានអនុវត្តចំពោះជនបរទេសអន្តោប្រវេសន៍។ ក៏ប៉ុន្តែ សុពលភាពសម្រាប់រយៈពេលស្នាក់នៅជាបណ្តោះអាសន្នរបស់ពួកគេ គឺមានត្រឹមតែមួយឆ្នាំតែប៉ុណ្ណោះ។ ក្រោយរយៈពេលមួយឆ្នាំនៃការស្នាក់នៅ ក្នុងករណី ដែលជនបរទេសអន្តោប្រវេសន៍ មិនអាចមានលទ្ធភាពធ្វើការវិនិយោគលើវិស័យណាមួយបាន ជនបរទេសនោះ អាចដកប្រាក់តម្កល់នានាវិញបាន ប៉ុន្តែជនបរទេសទាំងនោះពុំអាចបន្តការស្នាក់នៅបានទៀតឡើយ។[5]

**គ២.ជនបរទេសដែលទទួលលិខិតអនុញ្ញាតឲ្យវិនិយោគ**

ចំណែកឯ ជនបរទេសដែលទទួលបាននូវលិខិតអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រួមទាំងគ្រួសារផ្ទាល់ខ្លួន និងបានទទួលការអនុញ្ញាតឲ្យស្នាក់នៅ ក្នុងព្រះរាជាណាចក្រកម្ពុជាជាអចិន្ត្រៃយ៍ ឬតាមការកំណត់រយៈពេលដែលក្នុងលិខិតអនុញ្ញាតឲ្យធ្វើវិនិយោគ និងមានសិទ្ធិសុំកាន់កាប់ឯកសារ ក្នុងការធ្វើដំណើររបស់ព្រះរាជាណាចក្រកម្ពុជាបាន។[6]

ត្រូវបានចាត់ទុកជាសមាជិកគ្រួសារផ្ទាល់ខ្លួនរបស់ជនបរទេសប្រភេទនេះគឺរួមមាន ឪពុក ម្តាយ

[3] មាត្រា២៥នៃច្បាប់ស្តីពីអន្តោប្រវេសន្តចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤។

[4] មាត្រា២៦នៃច្បាប់ស្តីពីអន្តោប្រវេសន្តចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤។

[5] មាត្រា២៧នៃច្បាប់ស្តីពីអន្តោប្រវេសន្តចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤។

[6] មាត្រា២៨នៃច្បាប់ស្តីពីអន្តោប្រវេសន្តចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤។

បង្កើត ឬឪពុកម្តាយក្មេក ដែលស្ថិតនៅក្នុងបន្ទុក និងកូននៅលីវស្ថិតក្នុងបន្ទុកគ្រប់គ្រង។ កុមារដែលមានអាយុតិចជាង១២ឆ្នាំ មិនចាំបាច់ឲ្យបំពេញសំណុំបែបបទទិដ្ឋាការដោយឡែកទេ តែត្រូវបង់អាករទិដ្ឋាការចំនួន ១២៥០០០រៀល (មួយរយម្ភៃប្រាំពាន់រៀលគត់)ក្នុងម្នាក់ៗ ។

ជនបរទេសដែលជាជនអន្តោប្រវេសន៍ និងជាអ្នកវិនិយោគដែលទទួលបានលិខិតអនុញ្ញាតឲ្យវិនិយោគ ហើយមានបំណងចូលមកស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យស្នើសុំទិដ្ឋាការ ដោយផ្ទាល់នៅក្នុងក្រសួងមហាផ្ទៃ ឬតាមរយៈស្ថានទូត ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ឬអាជ្ញាធរបរទេសណាមួយ ដែលតំណាងឲ្យផលប្រយោជន៍ខ្មែរនៅក្រៅប្រទេសដោយតម្រូវៈ

-បំពេញសំណុំបែបបទទិដ្ឋាការ

- បង្ហាញលិខិតឆ្លងដែនរបស់ខ្លួន ឬឯកសារធ្វើដំណើរណាមួយ ដែលមានតម្លៃស្មើ ឬសមមូល ហើយដែលមានសុពលភាពយ៉ាងតិច៦ខែមុនចូលព្រះរាជាណាចក្រកម្ពុជា។

- ផ្តល់រូបថត ៣ គុណ ៤ ចំនួន៣សន្លឹក (ថតចំពីមុខគ្មានពាក់វ៉ែនតាពណ៌) ដែលទើបថតក្នុងពេលថ្មីៗដែលមិនឲ្យលើសរយៈពេល៦ខែ។

- ផ្តល់វិញ្ញាបនប័ត្របញ្ជាក់អំពីសុខភាពចំនួន១ច្បាប់ ដែលចេញដោយវេជ្ជបណ្ឌិត ឬក្រុមគ្រូពេទ្យ មានការទទួលស្គាល់ជាផ្លូវការ ហើយវិញ្ញាបនប័ត្រនេះត្រូវមានកាលបរិច្ឆេទមិនលើសពីរយៈពេល៣ខែ។

- បញ្ជាក់លិខិតថ្កោលទោស ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសាមីខ្លួន ឬលិខិតបញ្ជាក់ណាដែលមានតម្លៃស្មើ ។

- បង់អាករទិដ្ឋាការមានចំនួន ២៥០ ០០០ រៀល(ពីររយហាសិបពាន់រៀលគត់)។

## ផ្នែកទី២: បទដ្ឋានគតិយុត្តទាក់ទងនឹងជនបរទេស

### កថាខណ្ឌទី១: លិខិតឆ្លងដែន និងទិដ្ឋាការ

#### ក. និយមន័យ

លិខិតឆ្លងដែន គឺជាលិខិតផ្លូវការដែលប្រទេសមួយបានផ្តល់ឲ្យប្រជាពលរដ្ឋរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋទាំងនោះ អាចចាកចេញពីប្រទេសរបស់ខ្លួនបាន។

នៅព្រះរាជាណាចក្រកម្ពុជា អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ ជាអ្នកទទួលបន្ទុកលើការធ្វើលិខិតឆ្លងដែន ដែលមានសុពលភាពក្នុងរយៈពេល១០ឆ្នាំ ហើយអាចប្តូរថ្មីបាន។

ទិដ្ឋាការមានន័យថា"ការផ្ទៀងផ្ទាត់ ការអនុញ្ញាតឲ្យចូលក្នុងប្រទេស" ដោយប្រទេសមួយទៀត ដែល អនុម័តលើការចូលរបស់ជនបរទេសទៅក្នុងប្រទេសនេះ ឬ"សេចក្តីស្នើសុំការផ្តល់អនុសាសន៍របស់កុងស៊ុលអំពីការចូលទៅក្នុងប្រទេស" ដែលទាក់ទងនឹងការដាក់ពាក្យសុំរបស់ជនបរទេសសម្រាប់ អនុញ្ញាតឲ្យចូល ប្រទេស។

ទិដ្ឋាការ គឺជាលិខិតសម្រាប់បញ្ជាក់ថា ជនបរទេសណាម្នាក់ គឺមានសិទ្ធិរស់នៅលើទឹកដីប្រទេសណាមួយក្នុងរយៈពេលកំណត់ច្បាស់លាស់។

ទិដ្ឋាការ ត្រូវបានផ្តល់ឲ្យស្ថានទូតនៃប្រទេសដែលជនបរទេសចង់ស្នាក់នៅ បើជនបរទេសទាំងឡាយណាមានបំណងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចមានលទ្ធភាពពីរក្នុងការសុំទិដ្ឋាការគឺអាចសុំនៅស្ថានទូតខ្មែរប្រចាំនៅបរទេស ឬក៏សុំទៅអាជ្ញាធរសមត្ថកិច្ចប្រចាំនៅតាមច្រកទ្វារអន្តរជាតិសំខាន់ៗ។

### ខ. ប្រភេទ អាករ និងការពន្យាទិដ្ឋាការ

#### ខ.១ ប្រភេទ

ទិដ្ឋាការអាចជាទិដ្ឋាការប្រើប្រាស់សម្រាប់ចេញ-ចូលមួយដង ឬច្រើនដង។ ទិដ្ឋាការ ត្រូវបានបែងចែកចេញជា៧ប្រភេទគឺទិដ្ឋាការការទូត ទិដ្ឋាការផ្លូវការ ទិដ្ឋាការបោរីភាព ទិដ្ឋាការទេសចរណ៍ ទិដ្ឋាការឆ្លងកាត់ ទិដ្ឋាការធម្មតា និងទិដ្ឋាការពិសេស។[7]

ទិដ្ឋាការការទូត ត្រូវបានគេកំណត់សម្គាល់ដោយអក្សរឡាតាំង A ទិដ្ឋាការនេះ សម្រាប់ផ្តល់ដល់ជនមិនមែនអន្តោប្រវេសន៍ និងក្រុមគ្រួសាររបស់ពួកគេ ដែលកាន់លិខិតឆ្លងដែនការទូត ហើយមកបំពេញបេសកកម្មការទូត ឬក្នុងលក្ខណៈឯកជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដល់ជនបរទេសដ៏ទៃទៀត ដែលមានការសម្រេចពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

ទិដ្ឋាការផ្លូវការ ត្រូវបានគេកំណត់សម្គាល់ដោយអក្សរឡាតាំង B ដែលទិដ្ឋាការនេះ សម្រាប់ផ្តល់ឲ្យចំពោះជនបរទេសមិនមែនអន្តោប្រវេសន៍ ដែលមកបំពេញបេសកកម្មនៅក្នុងក្របខណ្ឌរដ្ឋ ឬក្នុងក្របខណ្ឌអង្គការអន្តរជាតិដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ ទិដ្ឋាការនេះក៏អាចត្រូវបានជូនជាលក្ខណៈឯកជនដល់ជនបរទេសណាដែលកាន់លិខិតឆ្លងដែនផ្លូវការ ។

ទិដ្ឋាការបោរីភាព ត្រូវបានកំណត់សម្គាល់ដោយអក្សរឡាតាំង C ដែលទិដ្ឋាការនេះ សម្រាប់ផ្តល់ជូនចំពោះជនបរទេសមិនមែនអន្តោប្រវេសន៍ ព្រមទាំងក្រុមគ្រួសាររបស់គេដែលក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ឬ ក្រសួងនានាចាត់ទុកជាការសំដែងនូវការគួរសម ។ ទិដ្ឋាការនេះផ្តល់ជូនចំពោះក្រុមគ្រួសារជនបរទេសមិនមែនអន្តោប្រវេសន៍ ដែលមកបំពេញបេសកកម្មនៅក្នុងក្របខណ្ឌរដ្ឋ ឬក្របខណ្ឌអង្គការអន្តរជាតិនានា ដោយមានការព្រមព្រៀងជាមួយក្រសួងការបរទេស ។

ទិដ្ឋាការទេសចរណ៍ ត្រូវបានកំណត់សម្គាល់ដោយអក្សរឡាតាំងធំ T ទិដ្ឋាការនេះសម្រាប់ផ្តល់ជូនបរទេសមិនមែនអន្តោប្រវេសន៍ដែលចូលមកកម្ពុជា ក្នុងក្របខណ្ឌទេសចរណ៍ ។

ទិដ្ឋាការឆ្លងកាត់ត្រូវបានកំណត់សម្គាល់ដោយអក្សរឡាតាំងធំ D ទិដ្ឋាការសម្រាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន៍ជាអ្នកធ្វើដំណើរឆ្លងកាត់មានដូចជា អ្នកបើកបរ បុគ្គលិក កម្មករនាវា ឬ យន្តហោះ ។

[7] មាត្រា៤នៃអនុក្រិត្យ៧៥ អ.ន.ក្រ.ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩។

ទិដ្ឋាការធម្មតា ត្រូវបានកំណត់សម្គាល់ដោយអក្សរឡាតាំងធំ E ទិដ្ឋាការនេះ សម្រាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន៍ទាំងឡាយណាដែលពុំត្រូវបានគេរៀបរាប់ក្នុងប្រភេទទិដ្ឋាការណាមួយខាងលើ ។

ទិដ្ឋាពិសេស ត្រូវបានកំណត់សម្គាល់ដោយអក្សរឡាតាំងធំ K ទិដ្ឋាការនេះ សម្រាប់ផ្តល់ជូនជនណាដែលមានសញ្ជាតិដើមជាខ្មែរ ហើយកាន់ឯកសារ ឬលិខិតឆ្លងដែនធ្វើដំណើរបរទេស។ ទិដ្ឋាការនេះ ចេញឲ្យដោយពុំមានការបង់ទិដ្ឋាការ ហើយអនុញ្ញាតឲ្យចេញ-ចូលច្រើនដងបាន មានរយៈពេលស្នាក់នៅមិនកំណត់។

### ខ.២. អាករលើទិដ្ឋាការ

យោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា យើងឃើញថា ការបង់អាករលើទិដ្ឋាការ ត្រូវបានកំណត់ឲ្យបង់ថ្លៃ ក៏ប៉ុន្តែមានទិដ្ឋាការមួយចំនួនដែលតម្រូវមិនឲ្យយកអាករដែរ មានដូចជា :[8]

- ទិដ្ឋាការការទូត A
- ទិដ្ឋាការផ្លូវការ B
- ទិដ្ឋាការបោរីភាព C
- ទិដ្ឋាការពិសេស K

ចំពោះទិដ្ឋាការមួយចំនួនទៀត ដែលតម្រូវឲ្យបង់អាករលើទិដ្ឋាការមានដូចជា :

- ទិដ្ឋាការទេសចរណ៏ T : អាករអាចស្មើនឹងម្ភៃដុល្លារអាមេរិច( 20$ )
- ទិដ្ឋាការឆ្លងកាត់ D : អាករអាចស្មើនឹងដប់ប្រាំដុល្លារអាមេរិច( 15$)
- ទិដ្ឋាការធម្មតា E : អាករអាចស្មើនឹងម្ភៃដុល្លារអាមេរិច( 20$ )

**កំណត់សម្គាល់:**

ការបន្តឲ្យស្នាក់នៅជាបណ្តោះអាសន្នគឺតម្រូវឲ្យមានការបង់ថ្លៃស្នាក់នៅបណ្តោះអាសន្នចំពោះទិដ្ឋាការផ្សេងពីទិដ្ឋាការប្រភេទ A B C និងD ដោយយោងលើច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ការបង់ថ្លៃអាករលើការបន្តឲ្យស្នាក់នៅជាបណ្តោះអាសន្នត្រូវបានកំណត់ដូចខាងក្រោម:[9]

-ការបន្តឲ្យស្នាក់នៅជាបណ្តោះអាសន្ន គឺតម្រូវឲ្យបង់អាករបណ្តោះអាសន្នស្មើនឹង៣០ដុល្លារអាមេរិច (៣០ដុល្លារ) សម្រាប់ការអនុញ្ញាតបន្តការស្នាក់នៅជាបណ្តោះអាសន្នដែលមានសម្រាប់រយៈពេលក្រោម ឬស្មើមួយខែ។

-ការបង់ថ្លៃស្នាក់នៅបណ្តោះអាសន្នគឺស្មើនឹងហុកសិបដុល្លារអាមេរិច(៦០ដុល្លារ) សម្រាប់ការអនុញ្ញាតបន្តការស្នាក់នៅជាបណ្តោះអាសន្នដែលមានរយៈពេលបីខែ។

[8] មាត្រា៧នៃអនុក្រិត្យលេខ៧៥ អ.ន.ក្រ. ចុះថ្ងៃទី២០ ខែសីហា ឆ្នំ១៩៩៩។

[9] មាត្រា១១នៃអនុក្រិត្យលេខ៧៥ អ.ន.ក្រ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩។

-ការបង់ថ្លៃស្នាក់នៅបណ្តោះអាសន្នគឺស្មើនឹងមួយរយដុល្លារអាមេរិច(១០០ដុល្លារ)សម្រាប់ការអនុញ្ញាតបន្តការស្នាក់នៅជាបណ្តោះអាសន្នដែលមានរយៈពេលប្រាំមួយខែ ។

-ការបង់ថ្លៃស្នាក់នៅបណ្តោះអាសន្នគឺស្មើនឹងមួយរយប៉ែតសិបដុល្លារសហរដ្ឋអាមេរិច(១៨០ដុល្លារ) សម្រាប់ ការអនុញ្ញាតបន្តឲ្យស្នាក់នៅជាបណ្តោះអាសន្នដែលមានរយៈពេលមួយឆ្នាំ ។

ការបង់ថ្លៃអាករគ្រប់ប្រភេទខាងលើ ត្រូវបង់ចូលថវិកាជាតិ ហើយបែបបទនៃការប្រមូលអាករនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ខ.៣. ការពន្យាពេលទិដ្ឋាការ

ការពន្យាពេលទិដ្ឋាការ តើអង្គការរដ្ឋ ឬស្ថាប័នណាដែលមានសមត្ថកិច្ច?

ការអនុញ្ញាតការបន្តការស្នាក់នៅបណ្តោះអាសន្ន ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និង សហប្រតិបត្តការអន្តរជាតិ គឺអាស្រ័យទៅតាមប្រភេទនៃទិដ្ឋាការ ។[10]

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ គឺមានសមត្ថកិច្ចក្នុងការអនុញ្ញាតឲ្យជនបរទេសបន្តការស្នាក់នៅជាបណ្តោះអាសន្នសម្រាប់ទិដ្ឋាការដែលមានប្រភេទ A B និងC។

ចំណែក ក្រសួងមហាផ្ទៃមានសមត្ថកិច្ចបន្តការស្នាក់នៅបណ្តោះអាសន្នចំពោះទិដ្ឋាការប្រភេទT D និងE

បែបបទ និងនីតិវិធីនៃការស្នើសុំបន្តការស្នាក់នៅជាបណ្តោះអាសន្នរបស់ជនបរទេសដោយយោងលើលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជាបែបបទនៃការស្នើសុំមានដូចតទៅ :[11]

- បំពេញពាក្យសុំបន្តការស្នាក់នៅបណ្តោះអាសន្ន
- ភ្ជាប់មកនូវជាមួយលិខិតឆ្លងដែន ដែលមានសុពលភាពយ៉ាងតិច ៣ ខែ លើរយៈពេលនៃការស្នើសុំបន្តការស្នាក់នៅបណ្តោះអាសន្ន
- រូបថត ៤ គុណ ៦ ចំនួនមួយសន្លឹក
- ត្រូវបង់អាករសម្រាប់ការអនុញ្ញាតឲ្យបន្តក្នុងការស្នាក់នៅបណ្តោះអាសន្នតាមការកំណត់ក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះ។

**<u>សម្គាល់:</u>**

ចំពោះទិដ្ឋាការធម្មតា ដែលបានស្នើសុំការអនុញ្ញាតបន្តការស្នាក់នៅបណ្តោះអាសន្នចាប់ពីប្រាំមួយខែឡើងទៅគឺត្រូវមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័ននានា បញ្ជាក់ថា ពិតជាមានការចាំបាច់ក្នុងការបន្តការស្នាក់នៅបណ្តោះអាសន្ន នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាពិតប្រាកដមែន ឬកិច្ចសន្យាការងារជាមួយរោងចក្រ

[10] មាត្រា១០នៃអនុក្រិត្យលេខ៧៥ អ.ន.ក្រ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩។

[11] មាត្រា៩នៃអនុក្រិត្យលេខ ៧៥ អ.ន.ក្រចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩។

សហគ្រាស ឬក្រុមហ៊ុន ឬសិប្បកម្ម ឬការដ្ឋានដែលមានការទទួលស្គាល់ ដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងការងារ ឬក៏លិខិតបញ្ជាក់ស្ដីពីការចុះបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជាជាដើម។

រយៈពេលនៃការបន្ត ការស្នាក់នៅបណ្ដោះអាសន្នរបស់ជនបរទេស ដោយយោងលើលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានកំណត់ដូចខាងក្រោម :[12]

- ទិដ្ឋាការការទូត A អាចបន្តបានពី ១ ខែ ដល់ ១២ ខែម្តង រហូតដល់ចប់បេសកកម្ម ។
- ទិដ្ឋាការផ្លូវការ B អាចបន្តបានពី ១ ខែ ដល់ ១២ ខែម្តង យ៉ាងយូររហូតដល់ចប់បេសកកម្ម ។
- ទិដ្ឋាការបោរីភាព C អាចបន្តបានពី ១ ខែ ដល់ ១២ ខែម្តងយ៉ាងយូរ ។
- ទិដ្ឋាការទេសចរណ៍ T អាចបន្តបាន ម្តងមិនលើសពី ៣០ថ្ងៃ សម្រាប់ការចេញ-ចូលតែមួយដង ។
- ទិដ្ឋាការឆ្លងកាត់ D មិនអាចបន្តបានទេ លើកលែងក្នុងករណីប្រធានស័ក្ត ។
- ទិដ្ឋាការធម្មតា E អាចបន្តបានពី១ខែ ដល់១២ ខែ ដោយសាមីជន ត្រូវមកបង្ហាញខ្លួនដើម្បីបំពេញបែបបទដោយផ្ទាល់ខ្លួន នៅស្ថាប័នមានសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា គឺចាប់ពី១ឆ្នាំឡើងទៅ សាមីជនត្រូវសុំប័ណ្ណបណ្ដោះអាសន្នពីស្ថាប័នខាងលើ ។
- ទិដ្ឋាការពិសេស K មានរយៈពេលស្នាក់នៅមិនកំណត់ ។

## កថាខណ្ឌទី២ : ការចេញ-ចូល និងការស្នាក់នៅស្របច្បាប់របស់ជនបរទេស

នៅក្នុងសម័យបច្ចុប្បន្ននេះ ដោយសារបច្ចេកទេសវិទ្យាសាស្ត្របានរីកចម្រើនខ្លាំងក្លា ជាសម័យទំនើបកម្ម និងសកលភាវូបនីយកម្ម ហើយជាពិសេសគឺការរីកចម្រើន ក្នុងវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម និងកត្តាផ្សេងៗជាច្រើនដទៃទៀត បានតម្រូវឲ្យមានប្រជាពលរដ្ឋនៃប្រទេសមួយ បានធ្វើការបំលាស់ទីពីប្រទេសមួយ ទៅប្រទេសមួយផ្សេងទៀត និងពីកន្លែងមួយទៅកន្លែងមួយទៀត ។ ដើម្បីគ្រប់គ្រងបញ្ហាបែបនេះ ប្រទេសនីមួយៗបានខិតខំបង្កើតនូវបទដ្ឋានគតិយុត្តជាច្រើន ។ ជាក់ស្តែងច្បាប់ស្តីពីអន្តោប្រវេសន៍ត្រូវបានអនុមត័នៅឆ្នាំ១៩៩៤ ហើយលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដូចជា អនុក្រឹត្យ ប្រកាស និងសារាចរណែនាំជាច្រើនត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ។

ការចេញចូលរបស់ជនបរទេសអន្តោប្រវេសន៍ មកក្នុងព្រះរាជាណាចក្រកម្ពុជា យោងលើអនុក្រឹត្យស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឲ្យជនបរទេសអន្តោប្រវេសន៍ចេញ ចូល និងស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជាលេខ ៣០ អ.ន.ក្រ.បក បានបញ្ញត្តិនូវលក្ខខណ្ឌមួយចំនួនដែលត្រូវបំពេញ ។

### ក. បែបបទនៃការសុំចូល

បែបបទនៃការសុំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា បានផ្តល់លទ្ធភាពឲ្យជនបរទេស ដែលមាន

[12] មាត្រា៨នៃអនុក្រិត្យលេខ ៧៥ អ.ន.ក្រ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩។

បំណងចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យសុំទៅក្រសួងមហាផ្ទៃ តាមរយៈអាជ្ញាធរទូត ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ឬ តាមរយៈអាជ្ញាធរបរទេសណាមួយ ដែលតំណាងឲ្យផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ជនបរទេសទាំងនោះត្រូវបំពេញនូវបែបបទខ្លះដូចខាងក្រោម :

- ត្រូវបំពេញបែបបទទិដ្ឋាការ
- ត្រូវភ្ជាប់ជាមួយនូវសេចក្តីចម្លងលិខិតឆ្លងដែនរបស់សាមីខ្លួន ឬសេចក្តីចម្លងឯកសារការធ្វើដំណើរណាមួយដែលមានតម្លៃស្មើគ្នា សុពលភាពយ៉ាងតិច៦ខែអាចចូលមកក្នុងព្រះរាជាណាចក្រ កម្ពុជា
- ត្រូវមានរូបថត៤គុណ៦ ចំនួន៣សន្លឹក(ថតចំពីមុខ គ្មានពាក់មួក ឬវ៉ែនតា)
- ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់សុខភាព ចំនួនមួយច្បាប់ដែលចេញដោយវិជ្ជបណ្ឌិត នៃប្រទេសដើមរបស់ខ្លួន វិញ្ញាបនប័ត្រនេះត្រូវមានកាលបរិច្ឆេទមិនឲ្យហួសរយៈពេល៣ខែនៅពេលដែលដាក់ពាក្យ
- ត្រូវមានភស្តុតាងបញ្ជាក់អំពីការមានមធ្យោបាយគ្រប់គ្រាន់ សម្រាប់ជីវិតផ្ទាល់ខ្លួន និងសមាជិកនៅក្នុងបន្ទុកបាន និងមានអ្នកធានាក្នុងស្រុកខ្មែរដែលមានសមត្ថភាពនិងលទ្ធភាពទទួលខុសត្រូវខាងជីវភាព និង មធ្យោបាយផ្គត់ផ្គង់ផ្សេងៗទៀត។
- ត្រូវមានលិខិតថ្កោលទោសដែលចេញដោយអជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើមខ្លួន
- ត្រូវមានសេចក្តីចម្លងកិច្ចសន្យា ការងារជាមួយឯកជន ដោយមានការបញ្ជាក់ពីអជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាមួយច្បាប់បើសិនជាមាន
- ត្រូវមានសាលាកប័ត្រស្តីអំពីការតម្កល់ប្រាក់ធានា សម្រាប់ថ្លៃសាហ៊ុយធ្វើដំណើរត្រឡប់ទៅវិញ ឬមាតុភូមិនិវត្តន៍ ជាយថាហេតុណាមួយចំពោះ :
    - ជនបរទេសដែលមកពីប្រទេសមានព្រំប្រទល់ជាប់នឹងព្រះរាជាណាចក្រកម្ពុជា គឺចំនួនប្រាំរយពាន់រៀល(៥០០ ០០០៛)
    - ជនបរទេសដែលមកពីបណ្តាប្រទេសអាស៊ី និងប្រទេសអូសេអានីគឺចំនួនមួយលានពីររយហាសិបពាន់រៀល(១ ២៥០ ០០០៛)
    - ជនបរទេសដែលមកពីមជ្ឈឹមបូព៌ានិងទ្វិបអាហ្វ្រិច ចំនួនពីរលានប្រាំរយពាន់(២ ៥០០ ០០០៛)
    - ជនបរទេសមកពីអឺរ៉ុប និងអាមេរិកចំនួនបីលានប្រាំពីររយហាសិបពាន់រៀល(៣ ៧៥០ ០០០៛)

បច្ចុប្បន្ននេះព្រះរាជាណាចក្រកម្ពុជា បាននឹងកំពុងអភិវឌ្ឍន៍ប្រទេសជាតិ ដើម្បីធានាឲ្យបាននូវនយោបាយសន្តិសុខ សន្តិភាពជូនប្រទេស ដែលជាហេតុធ្វើឲ្យមានការរីកចម្រើនលើគ្រប់វិស័យ និងគ្រប់ផ្នែកមានពាណិជ្ជកម្ម ទេសចរណ៍ ឬទំនាក់ទំនងការទូតជាដើម។

ដូច្នេះមានជនបរទេសជាច្រើន បានចូលមកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពេលមកដល់ពួកគេត្រូវតែមានប័ណ្ណស្នាក់នៅតាមប្រភេទនៃជនបរទេសទាំងនោះ។

**ខ.ប្រភេទប័ណ្ណស្នាក់នៅរបស់ជនបរទេស**

ជនបរទេសដែលចង់ស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានប័ណ្ណស្នាក់នៅ។ ប័ណ្ណស្នាក់នៅមានពីរប្រភេទគឺប័ណ្ណស្នាក់នៅបណ្តោះអាសន្ន និងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍។

**ខ.១.ប័ណ្ណស្នាក់នៅបណ្តោះអាសន្ន**

ប័ណ្ណស្នាក់នៅ ត្រូវបានផ្តល់ឲ្យដល់ជនបរទេសណា ដែលជាបុគ្គល និងអ្នកជំនាញខាងគ្រប់គ្រងបុគ្គលិកបច្ចេកទេស កម្មករជំនាញ អ្នកលក់សេវា ឬពលកម្មផ្សេងទៀត ។ ប័ណ្ណនេះមានសុពលភាពមិនលើសពីសុពលភាពរបស់ទិដ្ឋាការនោះទេ ។

បែបបទនៃការសុំប័ណ្ណស្នាក់នៅបណ្តោះអាសន្ន :

- ពាក្យសុំប័ណ្ណស្នាក់បណ្តោះអាសន្នផ្ញើជូនទៅក្រសួងមហាផ្ទៃ
- សាកលប័ត្រពត៌មានតាមគំរូឯកភាពរបស់ក្រសួងមហាផ្ទៃចំនួន ៣ សន្លឹក
- ភ្ជាប់មកជាមួយនូវលិខិតឆ្លងដែន ឬ ឯកសារណាមួយដែលមានតំលៃស្មើ ដែលមានទិដ្ឋាការត្រឹមត្រូវ(ច្បាប់ចំលង)
- រូបថត ៤គុណ៦ ចំនួន៦សន្លឹក( ថតចំពីមុខ គ្មានពាក់មួក ឬវ៉ែនតា )
- មានកាយសម្បទាល្អ ដែលអាចបំពេញវិជ្ជាជីវៈខ្លួនឯង ដោយមានការបញ្ជាក់ពីគ្រូពេទ្យនៃប្រទេសដែលជនអន្តោប្រវេសន្តចេញមក និងមានកិច្ចសន្យាការងារជាលាយល័ក្ខអក្សរផងដែរ
- ត្រូវមានលិខិតធានារ៉ាប់រងសង្គម ចេញដោយនិយោជក ឬក្រុមហ៊ុនធានារ៉ាប់រងណាមួយ
- មានបង្កាន់ដៃអាករប័ណ្ណស្នាក់នៅបណ្តោះអាសន្ន

**ខ.២.ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍**

ប័ណ្ណស្នាក់នៅជាអចិន្ត្រៃយ៍ គឺសម្រាប់ផ្តល់ជូនជនបរទេសអន្តោប្រវេសន៍ដែលទទួលស្គាល់ ដោយក្រសួងមហាផ្ទៃ និងជនបរទេសជាអ្នកវិនិយោគឯកជន ព្រមទាំងសហព័ទ្ធ និងអ្នកក្នុងបន្ទុកដែលទទួលស្គាល់ដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ ក៏ប៉ុន្តែប័ណ្ណនេះ មិនត្រូវផ្តល់ឲ្យកុមារទាំងពីរភេទដែលមានអាយុក្រោម១៨ឆ្នាំទេ។ កុមារត្រូវចុះឈ្មោះនៅលើប័ណ្ណស្នាក់នៅរបស់អាណាព្យាបាល ឬឳពុកម្តាយរបស់ខ្លួន។

ប័ណ្ណស្នាក់នៅនេះ មានសុពលភាពសម្រាប់រយៈពេល ២ឆ្នាំ ហើយអាចសុំបន្តជាធៀងរាល់ពីរឆ្នាំម្តង។ ក្នុងករណីបានបាត់ប័ណ្ណស្នាក់នៅ ម្ចាស់ប័ណ្ណត្រូវប្តឹងទៅស្នងការដ្ឋាននគរបាលខេត្ត ឬរាជធានី ដោយបង្ហាញអំពីហេតុការណ៍ ហើយត្រូវសុំប័ណ្ណស្នាក់នៅទុតិយតា ។

បែបបទ និងនីតិវិធីនៃការសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ដោយផ្អែកតាមលិខិតបទដ្ឋានគតិយុត្តិរបស់ក្រសួង មហាផ្ទៃ រួមមានៈ

- ពាក្យសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ផ្ញើជូនទៅក្រសួងមហាផ្ទៃ

- សេចក្តីចម្លងប្រកាសទទួលស្គាល់ជនបរទេសជាអន្តោប្រវេសន៍ ឬជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន ។
- ភ្ជាប់មកជាមួយនូវលិខិតឆ្លងដែន ឬឯកសារណាមួយដែលមានតំលៃស្មើ មានទិដ្ឋាការត្រឹមត្រូវ
- រូបថត ៤ គុណ ៦ ចំនួន៦សន្លឹក(ថតចំពីមុខ គ្មានពាក់មួក ឬវ៉ែនតា)
- លិខិតបញ្ជាក់ពីធនាគារណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបានបញ្ជាក់ថា សាម៉ីខ្លួនបានតម្កល់ប្រាក់ធានាត្រឹមត្រូវតាមការកំណត់របស់អនុក្រឹត្យ
- បង្កាន់ដៃបង់អាករប័ណ្ណស្នាក់នៅជាអចិន្ត្រៃយ៍ ។[13]

អ្នកស្នើសុំប័ណ្ណស្នាក់នៅ ឬសុំប័ណ្ណស្នាក់នៅជាទុតិយតា ត្រូវបង់អាករតាមការកំណត់របស់អនុក្រិត្យ។ ប័ណ្ណស្នាក់នៅនេះមានប្រសិទ្ធភាពប្រើប្រាស់ជំនួសអត្តសញ្ញាណប័ណ្ណបាន។ ក្នុងករណីបើមានការផ្លាស់ប្តូរទីលំនៅប័ណ្ណស្នាក់នៅត្រូវសុំការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច នៅលើប័ណ្ណរបស់ខ្លួន នៅការិយាល័យជនបរទេសនៃស្នងការដ្ឋាននគរបាលខេត្ត ឬរាជធានីដែលខ្លួនមានលំនៅដ្ឋានគឺមុនពេលចេញដំណើរ។ អ្នកកាន់ប័ណ្ណស្នាក់នៅគឺត្រូវបង្ហាញខ្លួនក្នុងរយៈពេល៤៨ម៉ោង បន្ទាប់ពីបានទៅដល់ទីលំនៅដ្ឋានថ្មី។[14]

### គ. ការដកហូតលក្ខណៈសម្បត្តិជាជនបរទេសអន្តោប្រវេសន្ត និងប័ណ្ណស្នាក់នៅ

ជនបរទេសអន្តោប្រវេសន៍ ត្រូវបានគេដកហូតលក្ខណៈសម្បត្តិជាជនបរទេសអន្តោប្រវេសន៍ គឺក្នុងករណីដែលពួកគេបានប្រព្រឹត្តល្មើសទៅនឹងបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលត្រូវបានតុលាការនៃព្រះរាជាណាចក្រកម្ពុជា បានផ្តន្ទាទោសដាក់ពន្ធធនាគារចាប់ពី៥ឆ្នាំឡើងទៅ ឬការបង្កភាពរឹករវដល់សន្តិសុខជាតិ និងប៉ះពាល់វប្បធម៌ប្រពៃណីដ៏ល្អប្រសើររបស់ខ្មែរព្រមទាំងជនដែលគ្មានសមត្ថកិច្ចការងារ ។

ចំណែកប័ណ្ណស្នាក់នៅអាចត្រូវបានដកហូត ក្នុងករណីដែលជនបរទេសណាមិនគោរពច្បាប់អន្តោប្រវេសន៍ឬប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ដែលធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ ផលប្រយោជន៍ជាតិ និងសណ្តាប់ធ្នាប់សាធារណៈដែលមិនអាចអនុគ្រោះបាន ។

### ឃ. ការហាមឃាត់មិនឲ្យចូល និងការមិនអនុញ្ញាតឲ្យស្នាក់នៅ

ការហាមឃាត់មិនឲ្យចូល និងការមិនអនុញ្ញាតឲ្យស្នាក់នៅនៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺសំដៅដល់ជនបរទេស ដែលមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេសទាំងឡាយណា ហើយដែលមានលក្ខណៈសម្បត្តិ ដូចខាងក្រោម :

- គ្មានលិខិតឆ្លងដែន ឬឯកសារគ្មានតម្លៃ

[13] ប្រការ២នៃប្រកាសលេខ៥៥៥ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

[14] ប្រការ៥នៃប្រកាសលេខ៥៥៥ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

- គ្មានបោះត្រាបញ្ជាក់អំពីការចូលពីសំណាក់មន្ត្រីអន្តោប្រវេសន៍កម្ពុជា ប្រចាំនៅតាមខ្លោងទ្វារអន្តរជាតិ ឬច្រកទ្វារទេ្វភាគីណាមួយ
- ពាក់ព័ន្ធបញ្ហាគ្រឿងញៀនឆ្លងដែន
- ប្រកបរបរពេស្យាចារ ឬជំនួញពេស្យាកម្មឆ្លងដែន
- ធ្វើប័ណ្ណស្នាក់នៅដោយគ្មានប័ណ្ណការងារ
- ធ្លាប់បានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា (ដោយមានការយល់ព្រម ពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្រសួងមហាផ្ទៃ) ។
- បានលួចលបចូលក្នុងនាវា ឬរថយន្ត ឬយន្តហោះ ដែលមកសំចតនៅព្រះរាជាណាចក្រកម្ពុជា
- ផ្តល់ជំនួយ ឬជួយលាក់បាំងក្នុងការបញ្ជូនជនបរទេសមិនស្របច្បាប់មកកម្ពុជា
- គេចវេសពីការផ្តន្ទាទោស ចំពោះបទឧក្រិដ្ឋ ដែលសាមីខ្លួនបានប្រព្រឹត្ត
- ត្រូវបានជឿដោយក្រសួងមានសមត្ថកិច្ច ដែលមានហេតុផលច្បាស់លាស់គ្រប់គ្រាន់ ថានឹងប្រព្រឹត្ត ឬធ្វើសកម្មភាពដែលនាំឲ្យខូចដល់ប្រយោជន៍សាធារណៈ ឬផលប៉ះពាល់ធ្ងន់ធ្ងរ ក៏ដូចជាការគំរាមកំហែងដោយផ្ទាល់ចំពោះសន្តិសុខសាធារណៈ
- ក្រសួងមានសមត្ថកិច្ចយល់ឃើញថា ពុំមានភាពចំបាច់ ឬហេតុផលស្របច្បាប់ណាមួយសម្រាប់វត្តមានជនបរទេសនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២: អានុភាពគតិយុត្តនៃកាតព្វកិច្ច និងសិទ្ធិ របស់ជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា

អានុភាពគតិយុត្តិនៃកាតព្វកិច្ច និងសិទ្ធិរបស់ជនបរទេស ដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺសំដៅដល់វិធានទាំងឡាយណាដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រម និងវិធានដែលបានបទបញ្ញត្តិ ហើយដែលត្រូវបានផ្តល់សច្ចាប័នដោយអង្គការនីតិបញ្ញត្តិ(សភា និងព្រឹទ្ធសភា)រួចហើយ។

កាតព្វកិច្ច និងសិទ្ធិរបស់ជនបរទេស ដែលស្នាក់នៅក្នុងប្រទេសមួយត្រូវតែគោរព និងប្រព្រឹត្តទៅស្រប ទៅនិងទៅនឹងច្បាប់ប្រទេសនោះ ហើយជនបរទេសនោះ មិនអាចយកសំអាងច្បាប់ក្នុងស្រុករបស់ខ្លួនមកប្រើប្រាស់បានទេលើកលែងតែមានករណីពិសេស។

**ឧទាហរណ៍** ជនបរទេសនៃព្រះរាជាណាចក្រថៃ ដែលធ្លាប់បើកបរប្រកាន់តាមលំនាំច្បាប់ចរាចរណ៍នៅក្នុងប្រទេសខ្លួន(ថៃ) នៅពេលមកស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជនបរទេសថៃនោះមិនអាចយកច្បាប់ថៃមកអនុវត្ត នៅក្នុងប្រទេសសកម្ពុជាបានឡើយ(ច្បាប់ចរាចរនៅប្រទេសថៃត្រូវប្រកាន់ឆ្វេង រីឯប្រទេសកម្ពុជាយើងច្បាប់ចរាចរត្រូវប្រកាន់ស្តាំ) ។ ជាគោលការណ៍បុគ្គលទាំងអស់ទោះជាជនជាតិខ្លួន ជនបរទេសក្តីរស់នៅក្នុងប្រទេស មួយត្រូវតែគោរពច្បាប់នៃប្រទេសនោះជាដាច់ខាត ដែលគេហៅថា " វិសាលភាពនៃដែនអនុវត្តវិធានច្បាប់ក្នុងលំហ " ។

ដោយសារព្រះរាជាណាចក្រកម្ពុជាគឺជាប្រទេសហត្ថលេខីលើសន្ធិសញ្ញាអន្តរជាតិជាច្រើន។ ដូចនេះការទទួលស្គាល់សិទ្ធិរបស់ជនបរទេសនៅលើទឹកដីនេះ ពុំចោទជាបញ្ហាឡើយ ក្នុងនោះរួមមាន សិទ្ធិជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល។

សិទ្ធិទាំងនេះ បានបែងចែកក្នុងអនុសញ្ញា និងឯកសារទូទៅនានា ស្តីអំពីសិទ្ធមនុស្សដូចជា សេចក្តីថ្លែងការជាសកលស្តីពីសិទ្ធិមនុស្សក្នុងឆ្នាំ១៩៤៨ សិទ្ធិពលរដ្ឋ ឆ្នាំ១៩៦៦ និងចែងនៅក្នុងបទដ្ឋានគតិយុត្តនៃច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។[12]

### ផ្នែកទី១: អនុភាពដោយផ្ទាល់យោងតាមទ្រឹស្តី

យោងតាមច្បាប់ធម្មជាតិ សិទ្ធិ គឺជាទស្សនៈដែលកើតចេញពីធម្មជាតិហើយតាមរយៈទស្សនៈនេះមានសិទ្ធិមនុស្សមួយចំនួនដែលមនុស្សគ្រប់រូបទទួលបានពីកំណើត។

យោងតាមច្បាប់ជាតិ សិទ្ធិ គឺជាអ្វីដែលមនុស្សម្នាក់អាចធ្វើទៅបាន ដោយគ្មានការហាមឃាត់ពីច្បាប់និងសង្គម។ ផ្ទុយទៅវិញការប្រើប្រាស់សិទ្ធិហួសព្រំដែនកំណត់ ឬប្រព្រឹត្តខុសច្បាប់ គឺមានន័យថា ជាការរំលោភសិទ្ធិអ្នកដទៃដែលជាចំណុចចាប់ផ្តើមដែលនាំឲ្យមានការដាក់ទោស និងការទទួលខុសត្រូវនៅចំពោះមុខច្បាប់។

[12] មាត្រា៣១រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ទាំងនេះសុទ្ធតែត្រូវបានទទួលស្គាល់ និងបញ្ញត្តិ ដោយអង្គការសហប្រជាជាតិ សម្រាប់មនុស្សគ្រប់រូប ដោយមិនប្រកាន់ពូជសាសន៍ស្របតាមអត្ថន័យទាំងនេះ ជនអន្តោប្រវេសន៍ទាំងអស់ ដែលកំពុងនឹងបន្តស្នាក់នៅ និងមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជាក៏ទទួលបាននូវសិទ្ធិទាំងនេះផងដែរ។

## កថាខណ្ឌទី១: អនុអានុភាពទាក់ទង និងបណ្តាសិទ្ធិនានា ចំពោះលក្ខន្តិកៈសាមញ្ញនៃជនបរទេស

### ក.សិទ្ធិទទួលបានសញ្ជាតិខ្មែរតាមរយៈកំណើត

រូបវន្តបុគ្គលទាំងឡាយណាដែលទទួលបានសញ្ជាតិខ្មែរតាមរយៈកំណើត លុះត្រាតែរូបវន្តបុគ្គល ទាំងនោះ បានបំពេញលក្ខខណ្ឌដែលច្បាប់បានបញ្ញត្តិទុកជាមុន។

លក្ខខណ្ឌនៃសិទ្ធិទទួលបានសញ្ជាតិខ្មែរតាមរយៈកំណើតរបស់រូបវន្តបុគ្គល ដែលរួមមាន សិទ្ធិទទួលបានសញ្ជាតិខ្មែរតាមរយៈខ្សែលោហិត និងសិទ្ធិទទួលបានសញ្ជាតិខ្មែរ តាមរយៈទីកន្លែងកំណើត(កន្លែងកើត)។

#### ក១-សិទ្ធិទទួលបានសញ្ជាតិខ្មែរតាមរយៈខ្សែលោហិត

សិទ្ធិទទួលបានសញ្ជាតិខ្មែរតាមរយៈខ្សែលោហិតគឺសំដៅដល់ការទទួលបានសញ្ជាតិតាមរយៈខ្សែលោហិតរបស់ឪពុកម្តាយ មានន័យថា កូនទាំងឡាយណាដែលបានកើតពីឪពុក ម្តាយ ដែលមានសញ្ជាតិខ្មែរ កូននោះមានសិទ្ធិត្រូវទទួលបានសញ្ជាតិខ្មែរទោះបីជាកូននោះបានកើតនៅទីកន្លែងណាក៏ដោយ។

សិទ្ធិទទួលបានសញ្ជាតិខ្មែរពិតប្រាកដតាមរយៈខ្សែលោហិត គឺទោះបីជាកូននោះបានកើតនៅទីកន្លែងណាក៏ដោយ។

-កូនដែលកើតពីឪពុក ឬម្តាយមានសញ្ជាតិខ្មែរ ឬ

-កូនដែលកើតមកឪពុកម្តាយមិនទទួលស្គាល់ កាលបើតុលាការបានចេញសាលក្រមថាកូននោះ ពិតជាកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ។[15]

**ឧទាហរណ៍** បុគ្គល A បានកើតពីម្តាយឪពុកដែលមានសញ្ជាតិខ្មែរ ដូចនេះ បុគ្គលAនោះនឹងទទួលបានសញ្ជាតិខ្មែរ ដោយផ្អែកលើសិទ្ធិទទួលបានតាមរយៈខ្សែលោហិត(ដោយមិនគិតថាកូននោះបានកើតនៅទីកន្លែងណា ឬទឹកដីនៃប្រទេសណានោះទេ)។

#### ក២-សិទ្ធិទទួលបានសញ្ជាតិខ្មែរតាមរយៈទីកន្លែងកំណើត

សិទ្ធិទទួលបានសញ្ជាតិខ្មែរ តាមរយៈទីកន្លែងកំណើត(កន្លែងកើត)សំដៅដល់សិទ្ធិនៃការទទួលបានសញ្ជាតិខ្មែរ ដោយផ្អែកតាមរយៈទីកន្លែងកំណើតរបស់បុគ្គលនោះ ទោះបីជា កូននោះបានកើតពីម្តាយឪពុកមានសញ្ជាតិអ្វីក៏ដោយ។ បានន័យថា កូនទាំងឡាយណាដែលបានកើតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាឪពុកម្តាយ កូននោះមានសញ្ជាតិអ្វីក៏ដោយ ក៏កូននោះមានសិទ្ធិទទួលបានសញ្ជាតិខ្មែរដែរ គឺដោយផ្អែកលើសិទ្ធិទទួលបានតាមរយៈទីកន្លែងកំណើត។

សិទ្ធិទទួលបានសញ្ជាតិខ្មែរពិតប្រាកដឲ្យតែកូននោះ បានកើតនៅក្នុងទឹកដីនៃព្រះរាជាណាចក្រ កម្ពុជាដូចតទៅ៖

---

[15] មាត្រា៩ វាក្យខ័ណ្ឌ១នៃច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

-កូនដែលកើតពីឪពុក ម្តាយ ដែលជាជនបរទេស ហើយបានកើត និងរស់នៅស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

-កូនណាកើតពីឪពុកម្តាយមិនស្គាល់មុខ និងកូនដែលទើបនឹងកើត ហើយត្រូវគេរើសបាននៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺត្រូវបានចាត់ទុកថា កូននោះបានកើតនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាដែរ។[16]

ចំពោះជនបរទេសណា ដែលបានកើតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីជា ឪពុក ម្តាយមានសញ្ជាតិអ្វីក៏ដោយក៏កូននោះអាចទទួលបានសញ្ជាតិខ្មែរបាន ដោយផ្អែកលើលក្ខខណ្ឌតែមួយគត់គឺកូននោះត្រូវរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាស្របច្បាប់រយៈពេល៣ឆ្នាំសិន។

ជនបរទេសអន្តោប្រវេសន្តណា ដែលបានកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជារយៈពេលស្នាក់នៅរយៈពេល៧ឆ្នាំត្រូវបានកាត់បន្ថយនៅត្រឹម៣ឆ្នាំវិញ។[17]

**កំណត់ចំណាំ**

ចំពោះការទទួលបានសញ្ជាតិខ្មែរ តាមរយៈទីកន្លែងកំណើតនេះដែរ ប្រសិនបើថ្ងៃក្រោយមកគេបានរកឃើញថា ឪពុករបស់កូននោះជាជនបរទេស តែម្តាយមិនទាន់រកឃើញ ឬរកឃើញហើយថា ម្តាយ ជាជនបរទេសក៏ប៉ុន្តែចំណែកឪពុកនៅមិនទាន់រកឃើញ ហេតុដូចនេះ កូននោះ នៅតែមានសញ្ជាតិជាខ្មែរដដែល។

លុះដល់ថ្ងៃក្រោយមកប្រសិនបើមានគេរកឃើញថា ឪពុកម្តាយរបស់កូននោះជាជនបរទេសនោះទើបគេអាចដកហូតសញ្ជាតិខ្មែរពីកូននោះមកវិញបាន។

**ខ-ការទទួលបានសញ្ជាតិខ្មែរតាមរយៈការសុំកូនពេញលេញ**

ការទទួលបានសញ្ជាតិខ្មែរតាមរយៈការសុំកូនត្រូវបានច្បាប់កំណត់ ចំពោះប្រជាពលរដ្ឋខ្មែរដែល បានសុំកូនបរទេសមកធ្វើជាកូនចិញ្ចឹមរបស់ខ្លួនត្រូវបានច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨ បានអនុញ្ញាតឲ្យកូននោះអាចទទួលបានសញ្ជាតិខ្មែរដោយផ្អែកលើលក្ខខណ្ឌនៃការសុំកូនពេញលេញ។

កូនបរទេសណាដែលត្រូវបានសុំជាកូនតាមរយៈការសុំកូនពេញលេញ ដោយសហព័ទ្ធប្រជាពល រដ្ឋខ្មែរត្រូវទទួលបានសញ្ជាតិខ្មែរ នៅពេលណាដែលសុំកូនពេញលេញត្រូវបានបង្កើតឡើង ដោយស្របច្បាប់ជាធរមាន។[18]

**គ-ការទទួលបានសញ្ជាតិខ្មែរតាមរយៈចំណងអាពាហ៍ពិពាហ៍**

ដើម្បីសិក្សាឲ្យបានស៊ីជម្រៅ អំពីការទទួលបានសញ្ជាតិខ្មែរតាមរយៈចំណងអាពាហ៍ពិពាហ៍ ជាដំបូងយើងត្រូវស្វែងយល់ថាតើអ្វីទៅជាអាពាហ៍ពិពាហ៍ជាមុនសិន។

-អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកមួយដែលធ្វើឡើងដោយបុរសម្នាក់ និងស្ត្រី ម្នាក់ដែលបានប្តេជ្ញាថា ខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមប្បញ្ញត្តិច្បាប់ ហើយដែលមិនអាចនឹងរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួនបានឡើយ។

[16]មាត្រា៩វាក្យខ័ណ្ឌ២នៃច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨ និងមាត្រា២២ក្រមរដ្ឋប្បវេណីសង្គមចាស់សម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៦៧។

[17] មាត្រា២០នៃច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

[18] មាត្រា១០នៃច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

-អាពាហ៍ពិពាហ៍ ដែលមានអានុភាពពេញលក្ខណៈច្បាប់លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើង ដោយស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ។ ដោយផ្អែកតាមនិយមន័យរបស់អាពាហ៍ពិពាហ៍ចំពោះបុគ្គលទាំងឡាយណាដែលចង់បានសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍ នោះមានន័យថា ការផ្តល់សញ្ជាតិខ្មែរតាមរយៈចំណង អាពាហ៍ពិពាហ៍ឲ្យទៅបុរស ឬស្ត្រីបរទេសណា លុះត្រាតែបុរស ឬស្ត្រីបរទេសនោះ បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ និងបានរួមរស់ជាមួយសហព័ទ្ធរបស់ខ្លួន (បុរស ឬស្ត្រីសញ្ជាតិខ្មែរ) រហូតដល់ថ្ងៃដែលបានសុំសញ្ជាតិខ្មែរ។

ដោយផ្អែកតាមច្បាប់ស្តីអំពីសញ្ជាតិខ្មែរឆ្នាំ២០១៨ បានកំណត់យ៉ាងច្បាស់ពីលក្ខខណ្ឌនៃការសុំទាមទារសញ្ជាតិខ្មែរ ដោយផ្អែកតាមរយៈចំណងអាពាហ៍ពិពាហ៍នោះគឺបានកំណត់ថា ស្ត្រី ឬបុរសជាជនបរទេសដែលយកប្តី ឬប្រពន្ធដែលមានសញ្ជាតិខ្មែរ ដោយបានរៀបអាពាហ៍ពិពាហ៍ គឺអាចទាមទារសញ្ជាតិខ្មែរបាន លុះត្រាតែស្ត្រី ឬបុរសបរទេសនោះបានរស់នៅជាមួយគ្នារយៈពេល៣ឆ្នាំ ក្រោយពេលបានចុះសំបុត្រអាពាហ៍ពិពាហ៍មក មិនត្រឹមតែប៉ុណ្ណោះ ចំពោះប្រជាពលរដ្ឋខ្មែរ(បុរស ឬស្ត្រី)ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស (បុរស ឬស្ត្រី)មិនត្រូវបានបាត់បង់សញ្ជាតិខ្មែរនោះទេ។[19]

ស្ត្រី ឬបុរសជាជនបរទេសដែលបានប្តី ឬប្រពន្ធជាប្រជាពលរដ្ឋខ្មែរ ដោយបានរៀបអាពាហ៍ពិពាហ៍ ស្របច្បាប់អាចទាមទារសញ្ជាតិខ្មែរបាន លុះត្រាតែស្ត្រី ឬបុរសនោះបានរស់នៅជាមួយគ្នារយៈពេល៣ឆ្នាំ ក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ និងបានស្នាក់នៅយ៉ាងហោចណាស់រយៈពេល១២ខែពេញលេញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ហើយក៏បានអនុញ្ញាតឲ្យមានការសុំទាមទារសញ្ជាតិខ្មែរជាក្រុមនៃគ្រួសារ (ជាចង្កោម) ចំពោះជនបរទេសជា ម្តាយម្តាយ ឬឪពុកដែលមានកូននៅជាអនីតិជនបាន។[20]

ចំពោះជនបរទេសណា ដែលអាចសុំទាមទារសញ្ជាតិខ្មែរ តាមរយៈចំណងអាពាហ៍ពិពាហ៍ ត្រូវបានបំពេញលក្ខខណ្ឌដូចតទៅៈ

១-មានគំនិតមាយាទ និងសីលធម៌ល្អ។

២-ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

៣-មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរតាមរយៈ ចំណងអាពាហ៍ពិពាហ៍។

៤-ចេះនិយាយភាសាខ្មែរ ចេះអក្សរសាស្ត្រខ្មែរ និងយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរខ្លះៗ

៥-មានបញ្ញា និងកាយសម្បទាមិននាំឲ្យមានគ្រោះថ្នាក់ ឬនាំឲ្យមានបន្ទុកដល់រដ្ឋខ្មែរ។[21]

ជនបរទេសដែលសុំទាមទារសញ្ជាតិខ្មែរ ដោយផ្អែកចំណងលើអាពាហ៍ពិពាហ៍ អាចសុំប្តូរឈ្មោះជាខ្មែរបាន ក្នុងករណីនេះ ត្រូវសរសេរបញ្ជាក់ឈ្មោះថ្មីនោះក្នុងពាក្យសុំទាមទារសញ្ជាតិខ្មែររបស់ខ្លួន។[22]

---

[19]មាត្រា១៧នៃច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

[20] មាត្រា១១នៃច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

[21] មាត្រា១២នៃច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

[22] មាត្រា១៣នៃច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

ករណី អាជ្ញាធរមានសមត្ថកិច្ច បានបដិសេធនៃការទាមទារសញ្ជាតិខ្មែរ សាមីខ្លួនមានសិទ្ធិប្ដឹងតវ៉ាបាន។ បែបបទ និងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ និងនីតិវិធីនៃការប្ដឹងតវ៉ាគឺត្រូវកំណត់ដោយអនុក្រឹត្យ។

ជនបរទេសដែលបានអនុញ្ញាតទទួលបានសញ្ជាតិខ្មែរ ដោយផ្អែកតាមរយៈចំណងអាពាហ៍ពិពាហ៍ ត្រូវតែធ្វើសម្បថនៅចំពោះមុខតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា។[23]

ចំណែកឯ ក្រុមរដ្ឋប្បវេណីសង្គមចាស់វិញនោះ បានសម្រេចផ្ដល់សញ្ជាតិខ្មែរឲ្យទៅស្ត្រីបរទេសណាម្នាក់ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយបុរសខ្មែរ ចាប់តាំងពីថ្ងៃបានរៀបអាពាហ៍ពិពាហ៍តទៅ។ ចំណែកស្ត្រីខ្មែរវិញ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយបុរសបរទេសនៅតែមានសញ្ជាតិខ្មែរដដែល។

ហេតុនេះ ស្ត្រីខ្មែរមិនត្រូវបានបាត់បង់សញ្ជាតិខ្មែររបស់ខ្លួន ដោយសារការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនោះទេ។

### ឃ-ការទទួលបានសញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម

សញ្ជាតូបនីយកម្ម (Nationalization) មិនមែនជាសិទ្ធិរបស់អ្នកស្នើសុំទេ ប៉ុន្តែជាសេចក្ដីយោគយល់ ឬជាការអនុគ្រោះរបស់ព្រះរាជាណាចក្រកម្ពុជា ចំពោះតែបុគ្គលជាជនបរទេសណា ដែលបានធ្វើការស្នើសុំសញ្ជាតិខ្មែរតែប៉ុណ្ណោះ។ ទោះបីជា ស្ថិតក្នុងប្រការណា ឬកាលៈទេសៈណាក៏ដោយ ក៏ពាក្យសុំសញ្ជាតិខ្មែរ អាចត្រូវបដិសេធចោលបានតាមអំណាចឆន្ទានុសិទ្ធិរបស់រដ្ឋខ្មែរ ទោះបីជាអ្នកស្នើសុំសញ្ជាតិ មានឋានៈខ្ពង់ខ្ពស់ដល់ថ្នាក់ណាក៏ដោយ។[24]

ការទទួលបានសញ្ជាតិខ្មែររបស់ជនបរទេស ត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាគឺជាអ្នកចេញ សេចក្ដីសម្រេចដោយព្រះរាជក្រឹត្យ។[25]

ការស្នើសុំសញ្ជាតិខ្មែរតាមរយៈសញ្ជាតូបនីយកម្មនេះ ត្រូវបានបែងចែកចេញជាពីរ គឺការស្នើសុំសញ្ជាតូបនីយកម្មតាមលក្ខខណ្ឌច្បាប់ធម្មតា និងការស្នើសុំសញ្ជាតូបនីយកម្មតាមលក្ខខណ្ឌពិសេស។

#### ឃ១-ការស្នើសុំសញ្ជាតូបនីយកម្មតាមលក្ខខណ្ឌធម្មតា

ការទទួលបានសញ្ជាតិខ្មែរតាមរយៈសញ្ជាតូបនីយកម្ម គឺសំដៅដល់ជនបរទេសទាំងឡាយណា ដែលបានមករស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របច្បាប់អន្តោប្រវេសន៍របស់ប្រទេសកម្ពុជា ដើម្បីប្រកបវិជ្ជាជីវៈ ឬការធ្វើសកម្មភាពផ្សេងៗទាក់ទងនឹងឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម ឬកសិកម្មជាដើម ជនបរទេសទាំងនោះ អាចដាក់ពាក្យស្នើសុំចូលសញ្ជាតិខ្មែរបាន។

ចំពោះជនបរទេសទាំងឡាយណាដែលមានបំណងចង់ស្នើសុំសញ្ជាតូបនីយកម្មខ្មែរបាន គឺត្រូវបំពេញតាមលក្ខខណ្ឌដូចតទៅៈ

១- មានគំនិត មាយាទ និងសីលធម៌ល្អ។

២-ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

[23] មាត្រា១៦នៃច្បាប់ស្ដីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

[24] មាត្រា១៨នៃច្បាប់ស្ដីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

[25] មាត្រា១៥នៃច្បាប់ស្ដីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

៣-មានទីលំនៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយបានស្នាក់នៅជាប់ចំនួន៧ឆ្នាំ ដោយគិតចាប់ពីថ្ងៃដែលបានទទួលប័ណ្ណស្នាក់នៅ ហើយបានចេញឲ្យនៅក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ចំពោះជនបរទេសអន្តោប្រវេសន្ត។

៤-ចេះនិយាយភាសាខ្មែរ ចេះអក្សរសាស្ត្រខ្មែរ និងយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយអាចបង្ហាញភស្តុតាងច្បាស់ថា ខ្លួនអាចរួមរស់នៅក្នុងទឹកដីព្រះរាជាណាចក្រកម្ពុជាបានដោយសុខសាន្ត ហើយ ព្រមទាំងទទួលបាននូវទំនៀមទំលាប់ខ្មែរ និងប្រពៃណីដ៏ល្អរបស់ខ្មែរទៀតផង។

៥-មានសតិបញ្ញានិងកាយសម្បទាល្អមិននាំឲ្យមានគ្រោះថ្នាក់ឬនាំឲ្យមានបន្ទុកធ្ងន់ធ្ងរដល់ប្រទេសជាតិ[26]

**ឃ២-ការស្នើសុំសញ្ជាតូបនីយកម្មតាមលក្ខខណ្ឌពិសេស**

ចំពោះជនបរទេសទាំងឡាយណា ដែលបានបំពេញការងារនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយមានបំណងចង់បានសញ្ជាតិខ្មែរនោះ ជនបរទេសទាំងនោះ អាចដាក់ពាក្យស្នើសុំសញ្ជាតូបនីយកម្មតាមលក្ខខណ្ឌពិសេសបានដូចជា តាមរយៈការវិនិយោគ តាមរយៈការធ្វើអំណោយ និងតាមរយៈជំនាញពិសេស ឬថ្វីដៃពិសេសអ្វីមួយ។

-**តាមរយៈការវិនិយោគ**

ការស្នើសុំសញ្ជាតូបនីយកម្មតាមរយៈលក្ខខណ្ឌច្បាប់ពិសេស ដោយការដាក់ទុនធ្វើវិនិយោគនៅ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជនបរទេសនោះត្រូវបំពេញតាមលក្ខខណ្ឌពិសេសដូចខាងក្រោម៖

-ជនបរទេសដែលទទួលបានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ ឲ្យធ្វើវិនិយោគតាមច្បាប់ពីស្ថាប័នមានសមត្ថកិច្ច។

-ជនបរទេសបានចំណាយទុនវិនិយោគជាក់ស្តែង។

-មានគំនិត មាយាទ និងសីលធម៌ល្អ។

-ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

-មានទីលំនៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបណ្ណស្នាក់នៅដែលបានចេញឲ្យក្របខណ្ឌ នៃច្បាប់ស្តីពីអន្តោប្រវេសន៍ចំពោះជនបរទេសអន្តោប្រវេសន្ត។

-ចេះនិយាយភាសាខ្មែរ ចេះអក្សរសាស្ត្រខ្មែរ និងយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយបង្ហាញ ភស្តុតាងច្បាស់ថា ខ្លួនអាចរួមរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ដោយសុខសាន្ត ហើយព្រមទាំងទទួលបាននូវទំនៀមទំលាប់ខ្មែរ និងប្រពៃណីដ៏ល្អរបស់ខ្មែរទៀតផង។

-មានសតិបញ្ញានិងកាយសម្បទាល្អមិននាំឲ្យមានគ្រោះថ្នាក់ឬនាំឲ្យមានបន្ទុកធ្ងន់ធ្ងរដល់ប្រទេសជាតិ[27]

ចំពោះទុនវិនិយោគនៅក្នុងវិស័យអាទិភាព និងប្រភេទគម្រោងធ្វើការវិនិយោគព្រមទាំងលក្ខខណ្ឌផ្សេងៗទៀតត្រូវកំណត់ដោយអនុក្រឹត្យ។

- **តាមរយៈការធ្វើអំណោយ**

ការស្នើសុំសញ្ជាតូបនីយកម្ម តាមរយៈលក្ខខណ្ឌពិសេស តាមរយៈការធ្វើអំណោយសប្បុរសធម៌ ជាការស្នើ

[26] មាត្រា១៩នៃច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

[27] មាត្រា២១នៃច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

សុំសញ្ជាតូបនីយកម្ម តាមរយៈលក្ខខណ្ឌពិសេស តាមរយៈការធ្វើអំណោយសប្បុរសធម៌ ជាសាច់ប្រាក់ដល់ថវិកាជាតិ និងជួយដល់សេដ្ឋកិច្ច នៃព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចស្នើសុំសញ្ជាតូបនីយកម្មខ្មែរបាន ដោយគោរពតាមលក្ខខណ្ឌពិសេសដូចខាងក្រោមៈ

- ជនបរទេសណា ដែលបានធ្វើអំណោយជាទឹកប្រាក់ដល់ថវិកាជាតិខ្មែរ សម្រាប់ជាប្រយោជន៍ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ឬជួយក្នុងវិស័យមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជា។

- មានគំនិត មាយាទ និងសីលធម៌ល្អ។

- ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

- មានទីលំនៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបណ្ណស្នាក់នៅ ដែលបានចេញឲ្យនៅក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីអន្តោប្រវេសន៍ចំពោះជនបរទេសអន្តោប្រវេសន្ត។

- មានសតិបញ្ញា កាយសម្បទាល្អមិននាំឲ្យមានគ្រោះថ្នាក់ ឬនាំឲ្យមានបន្ទុកធ្ងន់ធ្ងរដល់ប្រទេសជាតិ។

- ហើយជនបរទេសនោះ បានស្នាក់នៅដោយស្របច្បាប់យ៉ាងហោចណាស់ក៏មានរយៈពេល៦ខែពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជា។

ចំនួនទឹកប្រាក់ដែលជាអំណោយជាសាច់ប្រាក់សម្រាប់ផ្តល់ដល់ថវិកាជាតិ ឬក៏វិស័យមនុស្សធម៌ត្រូវកំណត់ ដោយអនុក្រឹត្យ។[28]

**-តាមរយៈជំនាញពិសេស ឬថ្វីដៃពិសេស**

ការស្នើសុំសញ្ជាតូបនីយកម្ម តាមរយៈលក្ខខណ្ឌច្បាប់ពិសេស ដោយផ្អែកតាមជំនាញពិសេស ឬក៏ថ្វីដៃពិសេសណាមួយរបស់ជនបរទេសណាម្នាក់ គឺសំដៅដល់ជនបរទេស ដែលមានជំនាញពិសេសលើសគេ ឬមានគុណសម្បត្តិដ៏អស្ចារ្យណាមួយ ដែលជាប្រយោជន៍ដល់សង្គមជាតិរបស់ខ្មែរយើង ជនបរទេសនោះ ក៏អាចដាក់ពាក្យដើម្បីស្នើសុំសញ្ជាតូបនីយកម្មដោយត្រូវគោរពតាមលក្ខខណ្ឌពិសេសដូចខាងក្រោមៈ

-ជនបរទេសណាដែលបានបង្ហាញនូវភស្តុតាងផ្សេងថា ខ្លួនបានផ្តល់នូវគុណសម្បត្តិពិសេស ឬថ្វីដៃពិសេស អ្វីមួយដែលជាប្រយោជន៍ដល់ប្រទេសកម្ពុជា និងបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

-មានគំនិត មាយាទ និងសីលធម៌ល្អ។

-ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

-មានសតិបញ្ញា កាយសម្បទាល្អមិននាំឲ្យមានគ្រោះថ្នាក់ ឬនាំឲ្យមានបន្ទុកធ្ងន់ធ្ងរដល់ ប្រទេសជាតិ។[29]

ជនបរទេសនោះអាចដាក់ពាក្យសុំសញ្ជាតូបនីយកម្មបាន ដោយគោរពលក្ខខណ្ឌខាងលើនេះ ប៉ុណ្ណោះ

ជនបរទេស ដែលបានអនុញ្ញាតឲ្យចូលជាសញ្ជាតិខ្មែរតាមរយៈសញ្ជាតូបនីយកម្ម គឺត្រូវបានធ្វើ សម្បថនៅចំពោះមុខតុលាការកំពូល។[30]

[28] មាត្រា២២នៃច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

[29] មាត្រា២៣នៃច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

[30] មាត្រា២៧នៃច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

**ខ.សិទ្ធិក្នុងវិស័យការងារ**

គ្មានជនបរទេសណាម្នាក់ ដែលអាចប្រកបមុខរបរណាមួយ ដោយគ្មានប័ណ្ណការងារ និងសៀវភៅការងារដែលចេញឲ្យដោយក្រសួងទទួលបន្ទុកវិស័យការងារ។ ជនបរទេសនោះត្រូវបំពេញលក្ខខណ្ឌដូចតទៅៈ

-និយោជកត្រូវមាននូវប័ណ្ណការងារត្រឹមត្រូវ ដើម្បីប្រកបមុខរបររបស់ខ្លួននៅព្រះរាជាណាចក្រកម្ពុជា

-ជនបរទេសនោះ ត្រូវបានចូលមកព្រះរាជាណាចក្រកម្ពុជា ដោយត្រឹមត្រូវតាមច្បាប់

-ជនបរទេសនោះ ត្រូវមានលិខិតឆ្លងដែនត្រឹមត្រូវ

-ជនបរទេសនោះ ត្រូវមានប័ណ្ណស្នាក់នៅត្រឹមត្រូវ

-ជនបរទេសនោះ ត្រូវមានសម្បទាសមស្រប និងមុខរបរនោះ ហើយគ្មានជំងឺឆ្លងណាមួយទេ។

ប័ណ្ណការងារមានសុពលភាពត្រឹមរយៈពេលមួយឆ្នាំ ហើយអាចពន្យាពេល ក្នុងករណីដែលសុពលភាពនៃការពន្យាពេលនេះ មិនលើសរយៈពេលកំណត់នៃប័ណ្ណស្នាក់នៅរបស់ជនបរទេសនោះ។[31]

ជាការពិតណាស់សិទ្ធិរបស់ជនបរទេស ក្នុងវិស័យការងារគឺត្រូវផ្តល់ឲ្យតាមរយៈច្បាប់ការងារក៏ដោយ ក៏ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជាក៏មានសិទ្ធិក្នុងការដកហូតប័ណ្ណការងារនោះវិញដែរ ក្នុងករណីប័ណ្ណការងារនេះនៅខ្វះចំណុចណាមួយមិនបានបំពេញលក្ខខ័ណ្ឌនីមួយៗ ដូចបានរៀបរាប់ខាងលើ។ កាលណាមុខរបរដែលត្រូវពន្យារបស់អ្នកកាន់ប័ណ្ណការងារ នៃព្រះរាជាណាចក្រកម្ពុជាមាន ការប្រជែងជាមួយកម្មករ និយោជិតជនជាតិខ្មែរដែលកំពុងរកការងារធ្វើក្នុងស្រុក។ ការដកហូតនេះ អាចអនុវត្តនៅពេលផុតកំណត់នៃប័ណ្ណការងារដែលចេញឲ្យ ឬបានពន្យាដល់ជននោះ។ កាលណាអ្នកកាន់ប័ណ្ណគ្មានការងារធ្វើ លើសពីរយៈពេល ១ខែ ឬជននោះបានចូលទៅធ្វើការជាមួយ និយោជកដទៃទៀត។[32] ដូចនេះជនបរទេសនោះ ត្រូវបាត់បង់សិទ្ធិរបស់ពួកគេជាក់ជាមិនខាន។

**ច.សិទ្ធិក្នុងវិស័យវិនិយោគ**

ជនបរទេសខាងផ្នែកវិនិយោគ ក្រៅតែអំពីការងារសម្រាប់ប្រជាពលរដ្ឋធ្វើនៅក្នុងស្រុក គឺនៅមានប្រយោជន៍ជាច្រើនផ្សេងៗទៀតដូចជាៈ

- ការជំរុញដល់ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គម

- ធនធានមនុស្សដែលមានជំនាញ ឬផ្ទេរជំនាញ

- ភាពសំបូរបែបវប្បធម៌នានា ដែលជនបរទេសទាំងនោះនាំមកជាមួយ នៅក្នុងប្រទេសកម្ពុជាកំពុងអភិវឌ្ឍន៍ និងដំណើរការដើម្បីជំរុញឲ្យមានធនធានមនុស្ស ដែលអាចផ្ទេរជំនាញព្រមទាំងជំរុញឲ្យមានការវិនិយោគទុនបរទេសនៅតាមមូលដ្ឋាន និងនៅទូទាំងប្រទេស។

រាល់ការធ្វើវិនិយោគនៅក្នុងប្រទេសកម្ពុជា អ្នកវិនិយោគ ជាជនជាតិខ្មែរ និងជាជនបរទេស គឺត្រូវបានទទួលការ

[33] មាត្រា២៦១នៃច្បាប់ស្តីពីការងារចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧។

[34] មាត្រា២៦២នៃច្បាប់ស្តីពីការងារចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧។

លើកទឹកចិត្តពីរាជរដ្ឋាភិបាល និងការផ្តល់សិទ្ធិជាច្រើនទៀត។ ចំពោះអ្នកវិនិយោគ ដែលវិនិយោគនៅក្នុងប្រទេសកម្ពុជា ត្រូវបានអនុញ្ញាតិឲ្យយកចូលមកក្នុងព្រះរាជាណាចក្រកម្ពុជានូវជនបរទេសណាដែលជាៈ

- បុគ្គលិក និងអ្នកជំនាញការខាងគ្រប់គ្រង
- បុគ្គលិកបច្ចេកទេស
- កម្មករជំនាញ

និយោជិត ជាជនបរទេសទាំងនោះ ត្រូវតែមានគុណសម្បត្តិ សមត្ថភាព និងជំនាញពិសេសមិនអាចរកបាននៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងចំណោមប្រជាជនខ្មែរ។[33]

**ឆ. សិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ**

យោងតាមច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ២០១០ បានបញ្ញត្តិយ៉ាងច្បាស់អំពីជនបរទេសមានសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិចាប់ពីជាន់ទី១(មួយ)ឡើងទៅ។ ជាន់ផ្ទាល់ដី និងជាន់ក្រោមដី មិនត្រូវបានអនុញ្ញាតឲ្យជនបរទេសមានសិទ្ធិកម្មសិទ្ធិឡើយ។ ម៉្យាងទៀត ជនបរទេសមានសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធដែលស្ថិតនៅក្នុងចំងាយ ៣០(សាមសិប) គីឡូម៉ែតពីព្រំដែនគោកឡើយ។ ក្នុងករណីដែលអគារសហកម្មសិទ្ធិសាងសង់នៅលើដីជួលពីបុគ្គលទី៣ជនបរទេសមាន សិទ្ធិជួលអចិន្ត្រៃយ៍លើចំណែកឯកជនដូចប្រជាពលរដ្ឋខ្មែរដែរ។[34]

យោងតាមទ្រឹស្តីដែលបានរៀបរាប់ខាងលើ បញ្ជាក់ថា ជនបរទេសនៅលើទឹកដីព្រះរាជាណាចក្រកម្ពុជាពិតជាមានសិទ្ធិភាពច្រើន មិនខុសពីប្រជាពលរដ្ឋខ្មែរទូទៅឡើយ មិនតែប៉ុណ្ណោះ អ្នកទាំងអស់នោះទទួលបានការលើកទឹកចិត្ត និងការអនុគ្រោះច្រើន ពីរាជារដ្ឋាភិបាលកម្ពុជាទាំងក្នុងវិស័យការងារ ទាំងវិស័យវិនិយោគ និងការកាន់កាប់អចលនវត្ថុផងដែរ។

សរុបមកទាំងនេះគឺ ជាចំណុចវិជ្ជមានដែលបង្កភាពងាយស្រួល ក្នុងគោលនយោបាយទាក់ទងភ្ញៀវបរទេសក្នុងគោលដៅលុបបំបាត់ភាពក្រីក្រ និងការអភិវឌ្ឍន៍សង្គមរបស់រាជដ្ឋាភិបាលក្នុងពេលបច្ចុប្បន្ន។

**កថាខណ្ឌទី២: អនុភាពទាក់ទង និងបណ្តាសិទ្ធិនានាសម្រាប់ជនបរទេសនៅក្នុងលក្ខន្តិកៈពិសេស**

ជនបរទេសដែលមានលក្ខន្តិកៈពិសេស គឺសំដៅទៅលើភ្នាក់ងារបម្រើការងារនៅក្នុងស្ថានទូតបរទេស ឬនៅ ស្ថានកុងស៊ុលបរទេស ឬស្ថានតំណាងបេសកកម្មបរទេស ឬអ្នកជំនាញការអន្តរជាតិ និងជនផ្សេងៗទៀតដែលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា តាមការស្នើសុំ ឬតាមកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលកម្ពុជា រាប់ទាំងគ្រួសារ និងបុគ្គលិករបស់ខ្លួនក្នុងរយៈពេលស្នាក់នៅអាស្រ័យនៅ ។

[៣៥] មាត្រា១៤នៃច្បាប់ស្តីពីវិនិយោគ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៤។
[៣៦] មាត្រា៦ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០១០។

**ក. ភ្នាក់ងារបម្រើការនៅស្ថានទូត**

ភ្នាក់ងារបម្រើការនៅក្នុងស្ថានទូត ដែលមានលក្ខណៈពិសេស ដោយទទួលបានការស្នាក់អាស្រ័យនៅក្នុងព្រះរាជណាចក្រកម្ពុជា តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី ជាមួយរាជរដ្ឋាភិបាលកម្ពុជា មានន័យថា កិច្ចព្រមព្រៀងនេះគឺបានផ្តល់នូវសិទ្ធិក្នុងការស្នាក់នៅទៅតាមរយៈអាណត្តិ ដែលជនបរទេសនោះនឹងបំពេញបេសកកម្មនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណង បម្រើផលប្រយោជន៍ឲ្យប្រជាពលរដ្ឋ និងប្រទេសកម្ពុជាផង និងផលប្រយោជន៍នៃប្រទេសរបស់ខ្លួនផង។

**ខ. អង្គការ ឬស្ថាប័នពាក់ព័ន្ធ និងអង្គការសហប្រជាជាតិ**

អង្គការសហប្រជាជាតិ ត្រូវបានបង្កើតឡើង នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៤៥ បន្ទាប់ពីបានបញ្ចប់សង្គ្រាមលោកលើកទី២ ។ អង្គការសហប្រជាជាតិបង្កើតឡើង នៅក្នុងគោលបំណងចង់ថែរក្សា សន្តិភាព សន្តិសុខអន្តរជាតិ ដើម្បីរារាំងនូវជំលោះនានាដែលកើតមានឡើងនៅក្នុងពិភពលោក ធ្វើការអភិវឌ្ឍន៍ទំនាក់ទំនងមិត្តភាពក្នុងចំណោមប្រជាជាតិទាំងឡាយឈរលើមូលដ្ឋានគោរពសិទ្ធិស្មើភាពគ្នា និងដើម្បីពង្រឹងសុខសន្តិភាពជាសកល។

ការសហប្រតិបត្តិការអន្តរជាតិក្នុងការដោះស្រាយវិវាទអន្តរជាតិនានាដែលមានចរិតជាមនុស្សធម៌។ អង្គការសហប្រជាជាតិមានអង្គការក្រោមចំណុះ ១១ គឺ UNDP , UNHCR , UNICFF , UNESCO , ILO , IMF , IMO , IBRD , WORLD , BANK , WHO , FAO , GATT ។ ព្រះរាជាណាចក្រកម្ពុជា ក៏ជារដ្ឋហត្ថលេខីមួយដែររបស់អង្គការសហប្រជាជាតិទៅលើសន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងមួយចំនួនទៀតដែលបានអនុម័ត។

ដូច្នេះហើយ ទើបបានជាឃើញមានវត្តមានរបស់អង្គការទាំង១១ខាងលើមានវត្តមាននៅក្នុងប្រទេសកម្ពុជា អង្គការទាំងនេះ បង្កើតឡើងដើម្បីគាំពារប្រជាពលរដ្ឋកម្ពុជា និងជនបរទេសដែលរស់នៅលើទឹកដីនៃប្រទេសកម្ពុជា ហើយអង្គការទាំងនេះមានមុខងារ និងតួនាទីរបស់អង្គការទាំងនោះតាមរូបភាពនិតិបុគ្គល។

ដោយយោងតាមវិធានការបង្កើត អង្គការ ស្ថាប័នដែលពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ បែបនេះហើយទើបមានជនបរទេសអាចមានសិទ្ធិចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈកិច្ចព្រមព្រៀងរបស់រាជរដ្ឋាភិបាលជាមួយនឹងអង្គការសហប្រជាជាតិ ។ ជនបរទេសទាំងនោះក៏បានចូលមកកម្ពុជា ហើយបានបម្រើផលប្រយោជន៍ឲ្យកម្ពុជា ។

**ឧទាហរណ៍** UNHCR (ឧត្តមស្នងការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន) បានជួយជនភៀសខ្លួនខ្មែរ ក្នុងអំឡុងចុងទស្សវត្សរ៍ឆ្នាំ៧០ ដែលបានស្នាក់នៅតាមជំរំព្រំដែនកម្ពុជា-ថៃ ហើយបានផ្តល់ឲ្យជនភៀសខ្លួននូវការឧបត្ថម និងគាំពារយ៉ាងជិតដល់រហូតដល់ឆ្នាំ១៩៩៣ រីឯអង្គការ World Bank ក៏បានជួយផ្តល់ជាជំនួយខាងហិរញ្ញវត្ថុក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជាយើងតាំងពីមុនរហូតមកដល់ពេលបច្ចុប្បន្ននេះ

ដូចនេះ រាល់ការចូលរួមរបស់ជនបរទេសទាំងនោះគឺប្រព្រឹត្តទៅតាមរយៈកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាល និងតាមរយៈកិច្ចសន្យាការងាររបស់ពួកគេទាំងនោះ ។

**គ. គ្រូពេទ្យគ្មានព្រំដែន**

ក្រុមគ្រូពេទ្យគ្មានព្រំដែនគឺជាក្រុមគ្រូពេទ្យដែលបានបញ្ចប់ការសិក្សា និងមានសញ្ញាប័ត្រដែលទទួលស្គាល់ ពីក្រសួងសុខាភិបាលនៃប្រទេសដើមរបស់គេ ហើយមានបំណងចង់ធ្វើដំណើរទៅកាន់ប្រទេសទីបី ដើម្បីជួយពិនិត្យ ជំងឺ ដល់ប្រជាពលរដ្ឋដែលក្រីក្រតាមតំបន់ដាច់ស្រយាល ដែលស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។

ការពិនិត្យសុខភាព គឺមិនត្រូវបានគិតថ្លៃទេ ពីព្រោះនេះគឺជាការងារស្ម័គ្រចិត្តរបស់ក្រុមគ្រូពេទ្យទាំងនោះ ។ មុនពេលចូលមកប្រទេសកម្ពុជា ក្រុមគ្រូពេទ្យទាំងនេះ ត្រូវបានធ្វើកិច្ចព្រមព្រៀង និងសុំការអនុញ្ញាតពីរាជរដ្ឋាភិបាលជាមុនរួចហើយ ដោយប្រាប់ពីហេតុផល និងគោលបំណងរបស់ខ្លួនដែលចង់បំពេញបេសកកម្មនៅប្រទេសកម្ពុជា ។

ក្នុងលក្ខខ័ណ្ឌនេះជនបរទេស ក៏មានសិទ្ធិចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាដែរ គេតែងតែឃើញមានក្រុមគ្រូពេទ្យទាំងនោះចុះទៅតាមខេត្ត ស្រុក ឃុំ ភូមិ នៅក្នុងប្រទេសកម្ពុជា ហើយអមជាមួយដោយអ្នកបកប្រែខ្មែរ ដើម្បីជួយសម្រួលក្នុងការបំពេញបេសកកម្មនេះ។

## ផ្នែកទី២: ផលវិបាក និងទណ្ឌកម្មទំនាក់ទំនងនឹងការអនុវត្តសិទ្ធិរបស់ជនបរទេស

ជនបរទេសដែលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ជាគោលការណ៍ គឺតែងតែទទួលបានសិទ្ធិមួយចំនួនដូចបានបញ្ញត្តិទុករួចជាស្រេចនៅក្នុងច្បាប់ខ្មែរ។ ជាការពិតណាស់ប្រទេសកម្ពុជាបានផ្តល់សិទ្ធិឲ្យជនបរទេស ប៉ុន្តែក៏មានសិទ្ធិដកហូតសិទ្ធិទាំងនោះត្រឡប់មកវិញបានផងដែរ ក្នុងករណីដែល ជនបរទេសនោះប្រព្រឹត្តអំពើណាមួយដែលហួសទៅនឹងព្រំដែននៃសិទ្ធិរបស់ជនបរទេស ជននោះ នឹងត្រូវទទួលទណ្ឌកម្មទាក់ទងទៅនឹងកំហុសរបស់ខ្លួនមិនខុសពីប្រជាពលរដ្ឋនៃប្រទេសសាមីឡើយ។

### កថាខណ្ឌទី១: ដែនកំណត់នៃសិទ្ធិរបស់ជនបរទេស

**ក.ចំពោះជនបរទេសសាមញ្ញ**

ចំពោះជនបរទេសសាមញ្ញ សិទ្ធិអំណាចរបស់ជននោះ មានកំណត់នៅក្នុងច្បាប់ និងទិដ្ឋាការ ។ ហេតុនេះបញ្ហាសំខាន់គឺត្រង់ថា ជនបរទេសទាំងនោះមិនគោរពទៅតាមច្បាប់ ដែលបានបញ្ញត្តិអំពីសិទ្ធិរបស់ខ្លួន និងទិដ្ឋាការ ដែលបានអនុញ្ញាតឲ្យ។

**ក.១. មូលហេតុនៃការឃាត់ខ្លួន**

តាមស្ថានភាពជាក់ស្តែងសមត្ថកិច្ចរបស់មន្ត្រីនគរបាលបានធ្វើការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់តាមតែភារកិច្ចដែលបានកំណត់នៅក្នុងច្បាប់ទៅលើជនបរទេសនៅតាមច្រកទ្វារអន្តរជាតិ និងតាមច្រកទ្វារផ្សេ

ងៗទៀត ជាពិសេសនៅតាមច្រកទ្វារអន្តរជាតិសំខាន់ៗមាន ពោធិ៍ចិនតុង ចាំយាម សៀមរាប ប៉ោយប៉ែត ។ ក្នុងនោះជនបរទេសមុនឆ្លងកាត់ប្រទេសណាមួយដែលមិនមែនជាប្រទេសរបស់ខ្លួន ដូចជាប្រទេសកម្ពុជាជាដើម ត្រូវមានលិខិតឆ្លងដែននិងទិដ្ឋាការដើម្បីបង្ហាញថា ជននោះ ជាជនបរទេសស្របច្បាប់ដល់សមត្ថកិច្ចត្រួតពិនិត្យ។ ក្នុងករណីដែលសុំណុំឯកសាររបស់ពួកគេស្របច្បាប់នោះ គឺត្រូវបានប្រថាប់ត្រា បញ្ជាក់ថា ជនបរទេសរូបនេះ បានឆ្លងកាត់ប្រទេសដោយ
ស្របច្បាប់ហើយគេមានសិទ្ធិចូលមកស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ផ្ទុយទៅវិញ បើជនបរទេសណាដែលធ្វើការកោសលុប ឬសរសេរបន្ថែម ឬក្លែងដោយបករូបថតយកទៅបិទ ឬមួយមានការបន្លំត្រា ហើយត្រូវបានមន្ត្រីនគរបាលមានសមត្ថកិច្ច ត្រួតពិនិត្យឃើញនៅត្រាមច្រកទ្វានានាទាំងនោះសមត្ថកិច្ចធ្វើការឃាត់ខ្លួនជននោះ ហើយបញ្ជូនចេញជាបន្ទាន់ តាមដែលអាចធ្វើទៅបានពីព្រះរាជាណាចក្រកម្ពុជា ឬធ្វើការបញ្ជូនមកការិយាល័យជនបរទេស ដើម្បីផ្អាកមិនឲ្យធ្វើដំណើរ ហើយត្រូវបញ្ជូនចេញពីប្រទេសកម្ពុជាមិនឲ្យលើសពីរយៈពេលប្រាំពីរថ្ងៃឡើយ តាមមធ្យោបាយមួយទៀត គឺសមត្ថកិច្ចត្រូវឃាត់ខ្លួនជននោះ ហើយធ្វើការទំនាក់ទំនងទៅស្ថានទូត ឬកុងស៊ុលនៃប្រទេសនោះនៅក្នុងប្រទេសកម្ពុជាយើង បើគ្មានត្រូវធ្វើការទំនាក់ទំនងស្ថានទូត ឬ កុងស៊ុលណាដែលនៅជិតប្រទេសរបស់យើង។

ម្យ៉ាងទៀតចំពោះជនបរទេសដែលស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយបានរស់នៅដោយហួសរយៈពេលកំណត់ទិដ្ឋាការ ប្រព្រឹត្តបទល្មើសរដ្ឋប្បវេណី ឬបទល្មើសព្រហ្មទណ្ឌ ដោយក្លែងបន្លំលើសំណុំឯកសារឆ្លងដែន សំណុំឯកសារស្នាក់នៅ នោះសមត្ថកិច្ចត្រូវធ្វើការផាកពិន័យ និងឃាត់ខ្លួនដើម្បីចបញ្ជូនចេញជាបន្ទាន់បាន។

### ក.២ ស្ថានភាពនៃការឃាត់ខ្លួនបណ្តោះអាសន្ន

ឆ្លងតាមរយៈនៃការឃាត់ខ្លួនមក នគរបាលដែលមានសមត្ថកិច្ចអាចយកជនបរទេសដែលល្មើសនោះទៅឃុំខ្លួនជាបណ្តោះអាសន្នបាន។ ចំពោះការឃុំខ្លួន ក្នុងករណីដែលជនបរទេសបានប្រព្រឹត្តបទល្មើសនៅក្នុងមូលដ្ឋានណាមួយនោះ សមត្ថកិច្ចមូលដ្ឋាននោះ ជាអ្នកមានសិទ្ធិឃាត់ខ្លួន គឺជាសមត្ថកិច្ចតាមដែនដី ហើយធ្វើការសហការជាមួយនគរបាលអន្តោប្រវេសន្តប្រចាំខេត្ត-ក្រុងនីមួយៗ ហើយបន្ទាប់មកទើបបញ្ជូនខ្លួនទៅកាន់ក្រសួងមហាផ្ទៃផ្នែកនាយកដ្ឋានជនបរទេស ដើម្បីធ្វើការដោះស្រាយទំនាក់ទំនងការទូត ឬកុងស៊ុល ហើយក្រសួងមហាផ្ទៃក៏បានធ្វើការសហការជាមួយក្រសួងការបរទេស ក្នុងករណីដែលទាក់ទងដល់បញ្ហាសំខាន់ៗដូចជា បញ្ហាការធ្វើបត្យាប័ន ឬមួយកិច្ចការនយោបាយជាដើម។

ចំពោះស្ថានភាពនៃជនបរទេស ក្នុងការរស់នៅអំឡុងពេលឃាត់ខ្លួនជាបណ្តោះអាសន្ន គឺកន្លែងដែលឃាត់ខ្លួននោះត្រូវផ្តល់អាហារ មានបន្ទប់ស្នាក់នៅសមរម្យ ព្រមទាំងមានការធានាសមត្ថភាពដោយរក្សាភាពថ្លៃថ្នូរ ។

ចំណែកឯនាយកដ្ឋានបរទេសនៃក្រសួងមហាផ្ទៃ ត្រូវរៀបចំបន្ទប់សមរម្យ មានកង្ហារ មានបន្ទប់ទឹក។

### ក.៣ ការពិន័យ និងការដាក់ទោសព្រហ្មទណ្ឌ

ការផាកពិន័យ និងការដាក់ទោស គឺដើម្បីធ្វើឲ្យមានរបៀបរៀបរយ និងមានការការពារដល់សេចក្តីថ្លៃថ្នូរដល់សង្គមជាតិខ្មែរ។ ដូច្នេះហើយបានជាព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិទោសយ៉ាងជាក់ច្បាស់នូវការពិន័យ និង ទោសបញ្ញត្តិទៅលើជនបរទេសណាដែលល្មើស ។

ចំពោះជនបរទេសដែលមានប័ណ្ណឆ្លងដែន ឬប័ណ្ណស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជានោះគេត្រូវឆ្លងកាត់ការឆែកឆេរ ឬត្រួតពិនិត្យយ៉ាងម៉ត់ចត់ដោយក្រុមនគរបាលមានសមត្ថកិច្ច ដល់តាំងនៅតាមច្រកទ្វារព្រំដែននានា ជាពិសេសច្រកទ្វារអន្តរជាតិទៅលើគ្រប់ជនបរទេស។ ក្នុងនេះដែរមុខសញ្ញានៅពេលបច្ចុប្បន្នដែលកងកម្លាំង សមត្ថកិច្ចគួរយកចិត្តទុកដាក់ស៊ើបអង្កេត ឆែកឆេរនោះគឺមាន ប្រជាជនចិន ឥណ្ឌា ប៉ាគីស្ថាន បង់ក្លាដេស សេរីលង្កា និងរួមទាំងប្រជាពលរដ្ឋអាព្រិចផងដែរ មានដូចជា ប្រជាជនកាមីរូន នីហ្សេរីយ៉ា ហ្គាណា ដែលពួកអ្នកទាំងនេះច្រើនតែប្រព្រឹត្តបទល្មើសជាច្រើនប្រភេទផ្សេងៗគ្នា ។

- **ការពិន័យ**

ការពិន័យ មានអត្ថន័យថាជាការចាប់ជនល្មើសជាជនជាតិខ្លួន ឬជនបរទេសណាក៏ដោយឲ្យតែបានប្រព្រឹត្តបទល្មើសណាមួយ ឬបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដោយចេញសំណងជាប្រាក់ដើម្បីលោះខ្លួន

ជាទូទៅការកំណត់រយៈពេលទៅលើទិដ្ឋាការគឺការប្រព្រឹត្តទៅតាមប្រភេទទិដ្ឋាការនីមួយៗ ហើយអាចពន្យា បានខុសៗគ្នា ប៉ុន្តែបើក្នុងករណី ដែលជនបរទេសរស់នៅដោយគ្មានការពន្យាទិដ្ឋាការ ឬរស់នៅលើសពេលកំណត់នោះ ត្រូវបានគេចាត់ទុកថា ជននោះមានកំហុសដូចមានចែងក្នុងអនុក្រិត្យលេខ៧៥អ.ន.ក្រ.ស្តីអំពីបែបបទ សម្រាប់អនុវត្ត ចំពោះការអនុញ្ញាតឲ្យជនបរទេសមិនមែនអន្តោប្រវេសន្តចេញ-ចូល និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា "ជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលស្នាក់នៅហួសរយៈពេលកំណត់ក្រោម ៣០ថ្ងៃ ត្រូវបង្ខំឲ្យបង់ពិន័យអន្តរកាលចំនួនប្រាំដុល្លារសហរដ្ឋអាមេរិកក្នុងមួយថ្ងៃសម្រាប់ថ្ងៃដែលលើសបូក និងអាករលើការអនុញ្ញាតឲ្យបន្តការស្នាក់នៅបណ្តោះអាសន្នរយៈពេលមួយខែ " ។[35] នេះយើងឃើញថា ការពិន័យ គឺប្រាំដុល្លារសហរដ្ឋអាមេរិកក្នុងមួយថ្ងៃ ចំពោះការរស់នៅលើសការកំណត់ក្នុងទិដ្ឋាការ ហើយករណីដែលរឹងរូស ឬគេចវេសមិនព្រមចេញពីព្រះរាជាណាចក្រកម្ពុជាតាមការកំណត់ គឺមិនឲ្យលើសពីប្រាំពីរថ្ងៃ នោះក្រោមការបណ្តេញចេញត្រូវបង្ខំឲ្យបង់ពិន័យជាអន្តរកាលទ្វេរគុណ ហើយត្រូវឃាត់ខ្លួនដើម្បីរៀបចំសំណុំបែបបទបណ្តេញចេញដោយយោងតាមច្បាប់ស្តីពីអន្តោប្រវេសន៍របស់ប្រទេសកម្ពុជា ។

ចំពោះមូលហេតុនៃការស្នាក់នៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជនបរទេសគ្រប់រូប ត្រូវមានទិដ្ឋាការដែលចេញឲ្យដោយស្ថាប័នមានសមត្ថកិច្ចរបស់ប្រទេសគឺទៅតាមប្រភេទនៃជនបរទេស បើក្នុងករណីគេឃើញ

[៣៧] មាត្រា១៥នៃអនុក្រិត្យលេខ៧៥ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩។

សកម្មភាពប្រើប្រាស់ទិដ្ឋាការខុសពីប្រភេទដែលបានស្នើសុំ នោះមន្ត្រីដែលមានសមត្ថកិច្ចត្រូវធ្វើការពិន័យជាអន្តរកាលជាប្រាក់ស្មើនឹងមួយដុល្លារសហរដ្ឋអាមេរិក ហើយត្រូវបង្ខំឲ្យចាកចេញផុតពីព្រះរាជាណាចក្រកម្ពុជាតាមការកំណត់មិនឲ្យលើសពីប្រាំពីរថ្ងៃយ៉ាងយូរ ក្នុងករណីរឹងរូស ឬគេចវេសមិនព្រមចេញត្រូវផាកពិន័យអន្តរកាលជាទ្វេគុណ ។

- **ទោសព្រហ្មទណ្ឌ**

ចំពោះទោសព្រហ្មទណ្ឌ សម្រាប់អនុវត្តទៅលើជនបរទេសណាំ ដែលបានប្រព្រឹត្តល្មើសទៅនឹងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីបើជនបរទេសណាប្រព្រឹត្តបទល្មើស ទៅលើប្រជាពលរដ្ឋបរទេស ឬទៅលើប្រជាពលរដ្ឋខ្មែរម្យ៉ាងវិញទៀតបើប្រជាពលរដ្ឋខ្មែរប្រព្រឹត្តល្មើសទៅលើជនបរទេសក្តី ឬទៅលើប្រជាពលរដ្ឋខ្មែរដូចគ្នាក្តី គឺគេត្រូវអនុវត្តតាមច្បាប់ព្រហ្មទណ្ឌអន្តរកាលរបស់ព្រះរាជាណាចក្រកម្ពុជា ។

ជាការពិតបន្ទាប់ពីបានចាប់ជនល្មើសជាជនបរទេសរួចមក សមត្ថកិច្ចមូលដ្ឋានត្រូវយកជនល្មើសនោះទៅឃុំខ្លួន ហើយបញ្ជូនសំណុំរឿងបន្តទៅការិយាល័យអន្តោប្រវេសន្ត ស្ថិតនៅតាមខេត្ត និងរាជធានី ទើបមានការសហការដោះស្រាយពីការិយាល័យអន្តោប្រវេសន្តខេត្ត-រាជធានីមកនាយកដ្ឋានជនបរទេស ដែលចំណុះឲ្យក្រសួងមហាផ្ទៃដើម្បីទំនាក់ទំនងជាមួយស្ថានទូត ឬកុងស៊ុលរបស់ជនបរទេសនោះ ដើម្បីដោះស្រាយធ្វើការបញ្ជូនចេញ បើសិនជាស្ថានទូត ឬកុងស៊ុលនោះយល់ព្រម ។ ក្នុងករណីដែលគ្មានដំណោះស្រាយសមស្របខាងភាគីកម្ពុជាត្រូវអនុវត្តតាមច្បាប់កម្ពុជាដោយឃុំខ្លួនរួចធ្វើការបញ្ជូនទៅតុលាការកម្ពុជា ដើម្បីកាត់ក្តី ដោយធ្វើការបំបិទសិទ្ធិដើរហើរ ដោយដាក់គុកទៅតាមការកំណត់របស់ច្បាប់ នៅពេលផុតរយៈពេលកំណត់ គេត្រូវរកមធ្យោបាយដើម្បីបញ្ជូនជនបរទេសនោះចេញពីព្រះរាជាណាចក្រកម្ពុជា ដោយលែងផ្តល់ឲ្យទិដ្ឋាការចូលមកប្រទេសកម្ពុជាយើងទៀត ។

តាមរបាយការណ៍របស់មន្ត្រីនគរបាលដែលមានសមត្ថកិច្ច បទល្មើសជាច្រើនរបស់ជនបរទេស ដែលស្នាក់នៅក្នុងរាជធានីភ្នំពេញបានបង្ហាញថា ជនបរទេសបានប្រព្រឹត្តអំពើឃាតកម្ម ឬការចាប់ជំរិតទារយកប្រាក់ការបង្កជារបួសស្នាម ការវាយតប់គ្នា ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ការប្រើប្រាស់ និងការក្លែងក្លាយលិខិតស្នាម ការឆបោក ការប្រើប្រាស់អាវុធខុសច្បាប់ សេពកាមខុសច្បាប់ និងការរកស៊ីជួញដូរមនុស្ស ដែលសកម្មភាពទាំងអស់នេះ បានធ្វើឲ្យជះឥទ្ធិពលមិនល្អដល់ការអនុវត្តច្បាប់អន្តោប្រវេសន្ត ពិសេសគឺពួកឆ្លងដែនល្មើសច្បាប់ នៅតែមានជាបន្តបន្ទាប់រហូតមកដល់សព្វថ្ងៃ ។

ជាងនេះទៅទៀត ច្បាប់ស្តីពីអន្តោប្រវេសន្តដែលអនុម័តនៅក្នុងឆ្នាំ១៩៩៤ បានចែងថា" ជនបរទេសរូបណាដែលគ្មានការអនុញ្ញាត ហើយចូលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយការលួចលាក់បន្លំ ឬដោយល្បិចផ្សេងៗទៀតដែលផ្ទុយនឹងបញ្ញត្តិច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់គុកពី៣ខែ ដល់៦ខែ មុនពេលការបណ្តេញចេញ " ។

ដែលច្បាប់អន្តោប្រវេសន្តរបស់ព្រះរាជាណាចក្រកម្ពុជា ដែលបញ្ញត្តិទោសទៅលើជនល្មើសបរទេសដែលមករស់នៅកម្ពុជា ។[36] ហើយតាមច្បាប់ដដែលបានចែងថា " ជនណាដែលធ្វើការកោសលុប សរសេរឈ្មោះក្លែងក្លាយ ឬឲ្យគេខ្ចី ឬមួយក៏សរសេរឈ្មោះក្លែងក្លាយនៅក្នុងប័ណ្ណស្នាក់នៅ ប័ណ្ណការងារ កិច្ចសន្យាការងារ ឬមួយក៏ប្រើប្រាស់ឯកសារទាំងនោះដែលមានឈ្មោះរបស់ខ្លួន ឬធ្វើប័ណ្ណក្លែង ឬបន្លំសំណុំឯកសារដូចបានរៀបរាប់ខាងលើ គឺត្រូវផ្តន្ទាទោស ដោយការដាក់គុកពី៥ឆ្នាំ ទៅ១៥ឆ្នាំ ។[37]

- **ការបណ្តេញចេញ**

រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ មានសិទ្ធិបណ្តេញចេញ ចំពោះជនបរទេសឲ្យចេញពីព្រះរាជាណាចក្រកម្ពុជា យើងរាល់ជនបរទេសទាំងឡាយណាមានលក្ខណៈសម្បត្តិ ឬអាកប្បកិរិយាដូចខាងក្រោមៈ

- បង្កសកម្មភាពគ្រោះថ្នាក់ ដល់សន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា ឬក្រសួងមានសមត្ថកិច្ច ដែលមានភស្តុតាងជាក់លាក់ដែលបានបញ្ជាក់ថា ជនបរទេសរូបនោះជាអ្នកប្រឆាំងនឹងផលប្រយោជន៍សាធារណៈ និងសន្តិសុខសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ។
- មកធ្វើការងារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានប័ណ្ណការងារ ឬគ្មានទិដ្ឋាការស្នាក់នៅ ឬគ្មានលិខិតឆ្លងដែន ឬឯកសារធ្វើដំណើរអស់សុពលភាព( ហួសរយះពេលស្នាក់នៅ )។[38]
- ពាក់ព័ន្ធនឹងគ្រឿងញៀន( រកស៊ីលក់ដូរគ្រឿងញៀនឬ ចរាចរគ្រឿងញៀនក្នុងប្រទេស )
- គាំទ្រសកម្មភាពបំផ្លិចបំផ្លាញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ផ្តល់ជំនួយក្នុងការជួញដូរ ឬជួយលាក់បំបាំងក្នុងការបញ្ជូនជនបរទេសមិនស្របច្បាប់ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា
- ពាក់ព័ន្ធនឹងបណ្តឹងពីតុលាការហើយគេចវេសពីការផ្តន្ទាទោស ចំពោះបទល្មើសផ្សេងៗដែលសាមីខ្លួនបានប្រព្រឹត្ត( ដោយរាប់បញ្ចូលទាំងបទល្មើសមជ្ឈឹម និងព្រហ្មទណ្ឌផ្សេងៗទៀត...) ។
- ជាជនវិកលចរិក ឬបាត់បង់ស្មារតី និងសតិបញ្ញា
- ប្រព្រឹត្តនូវអំពើផ្សេងៗ ដែលច្បាប់បានហាមឃាត់ ដូចជា អាណាចារ ពេស្យាចារ...។

សេចក្តីសម្រេចបណ្តេញចេញ ត្រូវបានអនុវត្តភ្លាមៗ គឺចាប់ពីថ្ងៃចុះហត្ថលេខារបស់រដ្ឋមន្រ្តីក្រសួងមហាផ្ទៃហើយសាមីខ្លួនមានសិទ្ធិប្តឹងទៅតុលាការក្នុងរយះពេល០២ខែ ។ ការបណ្តេញចេញត្រូវអនុវត្តក្នុងរយះពេល០៧ថ្ងៃ យ៉ាងយូរ ក្រោយពីសេចក្តីសម្រេចចេញជាផ្លូវការពីរដ្ឋមន្រ្តីក្រសួងមហាផ្ទៃ លើកលែងតែមានសាល

[៣៨] មាត្រា២៩វាក្យខ័ណ្ឌ១ច្បាប់ស្តីពីអន្តោប្រវេសន្តដែលអនុម័តនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤។

[៣៩] មាត្រា៣២ច្បាប់ស្តីពីអន្តោប្រវេសន្តដែលអនុម័តនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤។

[៤០] មាត្រា៣៦ច្បាប់ស្តីពីអន្តោប្រវេសន្តដែលអនុម័តនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤។

ក្រុមបញ្ជាក់ដែលនាំឲ្យមានការផ្អាកការអនុវត្តពីតុលាការ ។[39]

**ខ. អញ្ញត្តិកម្ម**

អញ្ញត្តិកម្មសម្រាប់វិជ្ជាជីវៈសេរីៈ

- **អ្នកវេជ្ជសាស្ត្រ**

ដោយយោងតាមច្បាប់ស្តីពីការគ្រប់គ្រង លើការប្រកបវិជ្ជាជីវៈឯកជនវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ អ្នកវេជ្ជសាស្ត្រជនបរទេស អាចអនុញ្ញាតឲ្យគ្រាន់តែជាអ្នកអមវេជ្ជសាស្ត្រ និងជាអ្នកជំនួយវេជ្ជសាស្ត្រ ដែលមានកម្រិតជំនាញឯកទេសខ្ពស់ប្រកបរបរវិជ្ជាជីវៈក្នុងព្រះរាជាណាចក្រកម្ពុជា។[40]

បើទោះបីជា ជនបរទេសនោះ មានសញ្ញាប័ត្រដែលទទួលស្គាល់ ដោយក្រសួងសុខាភិបាលរបស់ប្រទេសដើមនៃជននោះក៏ដោយ ជនបរទេសនោះ មិនមានសិទ្ធិប្រកបវិជ្ជាជីវៈជាអ្នកវេជ្ជសាស្ត្រដោយផ្ទាល់បានឡើយនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

- **មេធាវីជនបរទេស**

នៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវីចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ក៏បានបញ្ញត្តិដែរអំពីការប្រកបរបរវិជ្ជាជីវៈសេរីមេធាវីជនបរទេស។ យោងតាមច្បាប់ស្តីពីលក្ខនិកៈមេធាវី មេធាវីជនបរទេស ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីប្រទេសក្រៅ ឬដែលប្រទេសដើមរបស់ខ្លួនទទួលស្គាល់ ឲ្យប្រកបវិជ្ជាជីវៈមេធាវី មានសិទ្ធិចូលរួមប្រកបវិជ្ជាជីវៈ ជាមួយមេធាវីខ្មែរ ហើយអមមេធាវីខ្មែរនៅចំពោះមុខតុលាការ ឬស្ថាប័នដ៏ទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា។[41]

មេធាវីបរទេសអាចប្រកបរបរវិជ្ជាជីវៈ នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែមានការយល់ព្រមពីក្រុមប្រឹក្សាគណៈមេធាវីខ្មែរ ផ្អែកលើលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់មេធាវីនោះ ហើយលុះត្រាតែប្រទេសដើមរបស់មេធាវីបរទេសនោះ ផ្តល់លទ្ធភាពដូចគ្នាដល់មេធាវីខ្មែរផងដែរ យោងតាមច្បាប់ដដែល ។[42] មានន័យថា មេធាវីបរទេសអាចមានសិទ្ធិប្រកបរបរវិជ្ជាជីវៈនេះបាន អាស្រ័យទៅតាមលក្ខណៈសម្បត្តិរបស់មេធាវីបរទេសនោះ ម៉្យាងវិញទៀតប្រទេសដើមរបស់មេធាវីនោះ គឺត្រូវតែផ្តល់សិទ្ធិឲ្យដល់មេធាវីខ្មែរដែរ មានន័យថា មិនត្រូវផ្តល់តែម្ខាងៗនោះទេ។ នៅពេលដែលមេធាវីបរទេសត្រូវបានផ្តល់សិទ្ធិឲ្យប្រកបរបរវិជ្ជាជីវៈនេះ ហើយ

---

៤២ មាត្រា៣៩ច្បាប់ស្តីពីអន្តោប្រវេសន្តដែលអនុម័តនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤។

៤៣ មាត្រា៤នៃច្បាប់ស្តីពីការគ្រប់គ្រងលើការប្របករបរវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រអមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រចុះថ្ងៃទី០២ ខែសីហាឆ្នាំ ២០០០។

**៤៤ មាត្រា៥នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥។**

**៤៥ មាត្រា៦នៃច្បាប់ស្តីពិលក្ខន្តិកៈមេធាវីចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥។**

មេធាវីបរទេស ពុំត្រូវធ្វើសកម្មភាពទាក់ទាញកូនក្តី ឬផ្សព្វផ្សាយពាណិជ្ជកម្មបានឡើយដោយយោងតាមច្បាប់ស្តីពីលក្ខនិកៈមេធាវីដដែល ។[43]

## កថាខណ្ឌទី២: ដែនកំណត់នៃសិទ្ធិចំពោះអង្គការ ឬស្ថាប័នអន្តរជាតិ

### ក. គោលការណ៍ទូទៅ

អង្គការ ឬស្ថាប័នអន្តរជាតិជាច្រើន ដែលកំពុងមានវត្តមាននៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អង្គការទាំងនោះបង្កើតឡើងក្នុងគោលបំណងឃ្លាំមើល ការពារ និងលើកកម្ពស់ការគោរពសិទ្ធិមនុស្ស ។

នៅតាមបណ្តាអង្គការអន្តរជាតិទាំងនោះ តែងតែមានអ្នកគ្រប់គ្រង និងបុគ្គលិកមួយចំនួនជាជនបរទេស។ ជនបរទេសប្រភេទនេះគឺមានអភ័យឯកសិទ្ធិសម្រាប់មុខងារ និងតួនាទីនៅក្នុងអង្គការអន្តរជាតិនោះ ។

ក្នុងករណីដែលជនបរទេសនោះ ធ្វើខុស ឬធ្វើផ្ទុយពីច្បាប់ ឬធ្វើហួសពីសិទ្ធិដែលខ្លួនមាន ក៏ត្រូវទទួលទោសទណ្ឌដូចជនបរទេសទូទៅដែរ ប៉ុន្តែមុននឹងអាចដាក់ទោសទៅលើជនបរទេសប្រភេទនេះបាន ទាល់តែដកអភ័យឯកសិទ្ធិជាមុនសិន ។ បន្ទប់ពីដក់អភ័យឯកសិទ្ធិរួចហើយ ជននោះ និងក្លាយទៅជាជនបរទេសសាមញ្ញ ។ ចំពោះការអនុវត្តទោសកំហុសដូចគ្នាទៅនឹងជនបរទេសសាមញ្ញដូចដែលបានរៀបរាប់ខាងលើដែរ។[44]

### ខ. អញ្ញត្តិកម្ម

ការដក ឬបញ្ឈប់ កិច្ចសហប្រតិបត្តការរបស់អង្គការអន្តរជាតិ ឬស្ថានទូត ស្ថានកុងស៊ុលបរទេស គឺអាចទាក់ទងនឹងហេតុផលជាច្រើនដូចជា:

- បញ្ហាបន្ទាន់បង្ខំ ឬស្ថានភាពមានវិបត្តិ

ឧទាហរណ៍ បញ្ហាវាងខ្មែរ និងថៃ ទាក់ទងនឹងការចូលឈ្លានពានទឹកដីខ្មែរ នៅក្បែរប្រាសាទព្រះវិហារ រហូតឈានដល់ការបាញ់ប្រហារគ្នាយ៉ាងខ្លាំងក្លាតាមព្រំដែនកម្ពុជា-ថៃ និងមានការដកស្ថានទូតថៃចេញពីប្រទេសកម្ពុជាទៀតផង ហើយស្ថានទូតខ្មែរប្រចាំនៅក្នុងប្រទេសថៃ ក៏បានដកត្រឡប់មកប្រទេសកម្ពុជាវិញដែរ។

ដូចនេះ បើតាមអណត្តិរបស់បុគ្គលិកនៃស្ថានទូតទាំងនោះគឺមិនទាន់ចប់នៅឡើយទេ ប៉ុន្តែត្រូវបានបង្ខំចិត្តវិលត្រឡប់ទៅកាន់ប្រទេសរៀងៗខ្លួន ដោយសារមានបញ្ហាកើតឡើង ។

- ភារកិច្ចត្រូវបានបញ្ឈប់មុនកិច្ចសន្យា ឬកាលកំណត់ ឬស្ថានភាពល្អ

នៅពេលដែលអង្គការអន្តរជាតិយល់ឃើញថាប្រទេសកម្ពុជាមានស្ថានភាពល្អណាស់ និងមានការអភិវឌ្ឍន៍ហើយអង្គការអាចដកខ្លួនមុនកាលកំណត់បាន ។

- បញ្ហាសង្គ្រាម

ក្នុងករណីដែលប្រទេសមានសង្គ្រាម អង្គការអន្តរជាតិ ឬស្ថាប័នទាំងអស់ និងត្រូវដកចេញ ទៅប្រទេស

---

**៤៦ មាត្រា៧នៃច្បាប់ស្តីពិលក្ខន្តិកៈមេធាវី ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥។**

**៤៧ សូមមើលលំអិតនៅក្នុងផ្នែកទី២ កថាខណ្ឌទី១ទំព័រទី៣១-៣៥។**

ដើមរបស់ខ្លួនវិញ ពីព្រោះពេលមានសង្គ្រាមគ្មានជនបរទេសណាហ៊ានចង់ចូលមកទេ ឬគ្មានការងារឲ្យធ្វើ ដោយសារតែម្នាក់ៗរវល់ជាប់ធ្វើសង្គ្រាម ។

- គ្មានស្ថេរភាព អសន្តិសុខ និងចលាចល

ក្នុងករណីប្រទេសគ្មានស្ថេរភាព និងអសន្តិសុខសង្គមបែបនេះ អង្គការអន្តរជាតិ ឬស្ថានទូតមិនអាចបន្តការធ្វើការតទៅទៀតបានទេ ព្រោះអាចបង្កឲ្យមានគ្រោះថ្នាក់ និងមានបញ្ហាផ្សេងៗកើតឡើងចំពោះកន្លែងទាំងនោះជាក់ជាមិនខាន ។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានបកស្រាយទៅលើប្រធានបទដោយផ្អែកច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលនៅជាធរមានមួយចំនួន បានបង្ហាញឲ្យយើងឃើញមានលិខិតបទដ្ឋានគតិយុត្តិមួយចំនួនទៀត មានដូចជា អនុក្រិត្យ ប្រកាស សារាចរ ណែនាំរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេស ប្រកាសរបស់ក្រសួងមហាផ្ទៃ យើងសង្កេតឃើញថា កាតព្វកិច្ច និងសិទ្ធិរបស់ជនបរទេសនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានលើកកម្ពស់ និងលើកទឹកចិត្ត និងអនុគ្រោះប្រជាពលរដ្ឋមានសិទ្ធិ ដើរហើរដោយសេរី អាចឆ្លងដែនពីប្រទេសមួយទៅប្រទេសមួយផ្សេងទៀត គឺតាមលទ្ធភាព សមត្ថភាពរបស់ប្រជាពលរដ្ឋម្នាក់ៗ។ ជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានដាក់ឈ្មោះអ្នកទាំងនោះថា ជាជនបរទេស។ ជនបរទេសទាំងនោះបានចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈជាភ្នាក់ងារជាអ្នកបម្រើការងារនៅតាមស្ថានទូត ជាសមាជិកមន្ត្រីបុគ្គលិកនៃអង្គការអន្តរជាតិ ឬស្ថាប័នអន្តរជាតិផ្សេងៗទៀត។

ចំពោះជនបរទេសសាមញ្ញ ដែលមានអ្នកទេសចរ អ្នករកគូស្រករ សិស្សនិស្សិត និងអ្នកធ្វើដំណើរឆ្លងកាត់ជាដើមមានអានុភាពនៃសិទ្ធិទទួលបាននូវសិទ្ធិតាមរយៈសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ជាធរមាន។

ចំណែកឯ ការកំណត់សិទ្ធិរបស់ជនបរទេសទាំងអស់នោះ គឺស្ថិតនៅត្រង់ទិដ្ឋាការ ដែលច្បាប់បានកំណត់ ក្នុងករណី ជនបរទេសមិនព្រមអនុវត្តនូវកាតព្វកិច្ច ឬប្រព្រឹត្តទៅល្មើសនឹងច្បាប់ ជនបរទេសនោះត្រូវទទួលនូវទោសទណ្ឌដែលបានបញ្ញត្តិទៅតាមកំហុសដែលជនបរទេសទាំងនោះបានប្រព្រឹត្ត។

ចំពោះជនបរទេសដែលមានលក្ខន្តិកៈពិសេស ដែលបានចូលមកក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈកិច្ចព្រមព្រៀងរបស់រាជរដ្ឋាភិបាល រយៈពេលស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺអាស្រ័យទៅតាមអាណត្តិក្នុងការបំពេញបេសកកម្ម ឬភារកិច្ចផ្សេងៗនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាយើង ជនបរទេសទាំងនោះគឺជាជនបរទេសដែលមានអភ័យឯកសិទ្ធិពិសេសខុសពីជនបរទេសសាមញ្ញ។ ការផ្តល់ឲ្យនូវសិទ្ធិពិសេស ឬអភ័យឯកសិទ្ធិនេះ គឺដើម្បីឲ្យមានភាពងាយស្រួលក្នុងការបំពេញភារកិច្ច ឬបំពេញបេសកកម្មឲ្យបានជោគជ័យ ជៀសវាងការរំខានពីរដ្ឋម្ចាស់ផ្ទះ ក្នុងករណីជនបរទេសទាំងនោះអនុវត្តហួសពីព្រំដែននៃសិទ្ធិដែលផ្តល់ឲ្យដោយច្បាប់ ជនបរទេស ក៏ត្រូវទទួលទោសទណ្ឌ ឬ បណ្តេញចេញពី កម្ពុជាជាបន្ទាន់ផងដែរ។

ជនបរទេសណា ដែលមានបំណងចង់ប្រកបរបរវិជ្ជាជីវៈសេរីណាមួយមានដូចជា មេធាវី វេជ្ជបណ្ឌិត ឬអ្នកបច្ចេកទេសផ្សេងៗទៀតនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ពួកគាត់ទាំងអស់នោះមិនអាចប្រកបរបរដោយសេរី និងធ្វើសកម្មភាពដូចប្រជាពលរដ្ឋនៃប្រទេសសាមីបានទេ គាត់អាចធ្វើបានគឺត្រឹមជាអ្នកនៅអម ជាជំនួយការ ឬអ្នក ប្រឹក្សាតែប៉ុណ្ណោះ ប៉ុន្តែប្រសិនបើមានកិច្ចព្រមព្រៀងរវាងរដ្ឋ និងរដ្ឋដែលបានផ្តល់សិទ្ធិឲ្យអ្នកទាំងនោះអាចប្រកបរបរវិជ្ជាជីវនៅក្នុងព្រះរាជាណាចក្រកម្ពុជា នោះអ្នកជំនាញ ឬអ្នកបច្ចេកទេសរបស់ប្រជាពលរដ្ឋកម្ពុជា ក៏អាចទៅប្រកបរបរវិជ្ជាជីវៈនៅក្នុងប្រទេសទាំងអស់នោះបានផងដែរ។

# អនុសាសន៍

នៅក្នុងអំឡុងពេលនៃការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំទាំងពីរបានសង្កេតឃើញ មានចំណុចគួរកត់សម្គាល់មួយចំនួនផងដែរ។ ដោយសារតែព្រះរាជាណាចក្រកម្ពុជាយើងជាប្រទេសមានសុខសន្តិភាពពិតប្រាកដបានធ្វើឲ្យសេដ្ឋកិច្ចជាតិមានភាពរីកចម្រើនជាលំដាប់ ថ្វីបើសេដ្ឋកិច្ចមានលក្ខណៈវិជ្ជមាន និងមានកំណើនសេដ្ឋកិច្ចជាលំដាប់ក្នុងរយះពេលជាច្រើនឆ្នាំកន្លងមកហើយក៏ដោយ ក៏ប្រទេសកម្ពុជាយើងនៅតែត្រូវការជាចាំបាច់អ្នកបច្ចេកទេស អ្នកវិទ្យាសាស្ត្រ ជាពិសេសអ្នកវិនិយោគទន់ដែលជាជនបរទេសជាច្រើនផ្សេងទៀត ដើម្បីមកធ្វើវិនិយោគនៅក្នុងប្រទេសកម្ពុជាយើង ក្នុងគោលបំណងជំរុញឲ្យមានកំណើនសេដ្ឋកិច្ចកាន់តែខ្ពស់ជាងពេលបច្ចុប្បន្ន។

បើក្រឡេកមើលទៅលើបញ្ហាជនអន្តោប្រវេសន៍ ដែលចូលមកក្នុងប្រទេសកម្ពុជាយើងមានសារសំខាន់ខ្លាំងណាស់ តាមរយះជនបរទេសទាំងអស់នេះ បានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាមានសេដ្ឋកិច្ចរីកចម្រើនជាបន្តបន្ទាប់។ ដើម្បីជម្រុញការអភិវឌ្ឍន៍ប្រទេសឲ្យកាន់តែរីកចម្រើនឲ្យបានខ្លាំងក្លាជាងនេះទៀត យើងខ្ញុំទាំងពីរនាក់សូមចូលរួមជា គំនិតយោបល់មួយចំនួនដូចតទៅនេះ

-ដោយសារប្រទេសកម្ពុជា មានចម្រុះជាតិសាសន៍រស់នៅ និងស្នាក់នៅជាហូរហែ និងមានការផ្លាស់ប្តូរជាបន្តបន្ទាប់នោះ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ ត្រូវសហការល្អជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីគ្រប់គ្រងលើជនបរទេស ដែលបានចូលមកបំពេញការងារ និងការបំពេញបេសកកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានច្បាស់លាស់ និងមានប្រសិទ្ធភាព។

-ត្រួតពិនិត្យជាប្រចាំចំពោះជនបរទេស ជាជនអន្តោប្រវេសន៍ ជនបរទេស ជាជនមិនមែនអន្តោប្រវេសន៍ និងជនបរទេសជាជនអន្តោប្រវេសន៍ដែលជាអ្នកវិនិយោគទន់។

-ពង្រឹងសមត្ថភាពដល់មន្ត្រីនគរបាលនូវជំនាញ និងបច្ចេកទេសឲ្យបានសមស្របដើម្បីគ្រប់គ្រងជនបរទេស ឲ្យបានល្អ និងច្បាស់លាស់នូវស្ថិតិរបស់ជនបរទេសទាំងអស់នៅក្នុងប្រទេសកម្ពុជា។

-ពង្រឹងសកម្មភាពគ្រប់គ្រងដល់មន្ត្រីមូលដ្ឋានឲ្យបានប្រសើរ ដើម្បីឈានទៅរៀបចំសណ្តាប់ធ្នាប់សាធារណៈឲ្យមានប្រសិទ្ធភាពខ្ពស់។

-ពង្រឹងការអនុវត្តច្បាប់ដល់មន្ត្រីគ្រប់ជាន់ថ្នាក់ទូទាំងប្រទេសកម្ពុជា។

-ដាក់ទោសទណ្ឌឲ្យបានធ្ងន់ធ្ងរដល់ជនបរទេសទាំងឡាយណា ដែលចូលមកក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់(ចូលដោយគ្មានការអនុញ្ញាតពីច្បាប់)។

# ឯកសារយោង

## ច្បាប់គ្រឹះ

-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

## ច្បាប់

-ច្បាប់ស្តីពីអន្តោប្រវេសន៍ឆ្នាំ១៩៩៤។

-ច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨។

-ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៤។

-ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧។

-ច្បាប់ស្តីពីការផ្តល់សិទ្ធិ កម្មសិទ្ធិនៃចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេសឆ្នាំ ២០១០

-ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីឆ្នាំ១៩៩៥។

-ច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឆ្នាំ២០០០។

## លិខិតបទដ្ឋានគតិយុត្តិ

- អនុក្រិត្យលេខ៣០ ស្តីពីបែបបទសម្រាប់ការអនុវត្ត ចំពោះការអនុញ្ញាតឲ្យជនបរទេសមិនមែនជាជនអន្តោប្រវេសន៍ចេញ ចូល និងការស្នាក់អាស្រ័យនៅក្នុងប្រទេសកម្ពុជាថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៦។

- អនុក្រិត្យលេខ៧៥ ស្តីពីបែបបទសម្រាប់ការអនុវត្ត ចំពោះការអនុញ្ញាតឲ្យជនបរទេសមិនមែនជាជនអន្តោប្រវេសន៍ចេញ ចូល និងការស្នាក់អាស្រ័យនៅក្នុងប្រទេសកម្ពុជាថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៩។

- អនុក្រិត្យលេខ៣៧ស្តីពីបែបបទសម្រាប់ការអនុវត្តចំពោះការអនុញ្ញាតឲ្យជនបរទេសជាជនអន្តោប្រវេសន៍ជាអ្នកវិនិយោគចេញ ចូលនិងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាថ្ងៃទី២០ ខែសីហា ឆ្នាំ ១៩៩៦។

- អនុក្រិត្យលេខ២៩ ស្តីពីការសុំទារកកំព្រា ឬកុមារយកទៅចិញ្ចឹមជាកូននៅឯបរទេស ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០១។

- ប្រកាសលេខ ៥៥៥ ស្តីពីការគ្រប់គ្រងលើការធ្វើប័ណ្ណស្នាក់នៅសម្រាប់ជនបរទេសថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

## សៀវភៅ

- សាស្ត្រាចារ្យ អ៊ឹង រដ្ឋា នីតិអន្តរជាតិសាធារណៈ បោះពុម្ពឆ្នាំ២០០៧។

- សាស្ត្រាចារ្យ ដុំ អ៊ីម ទំនាក់ទំនងអន្តរជាតិ បោះពុម្ពនៅឆ្នាំ ២០១១។

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

Kingdom of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

# ពាក្យសុំការទទួលស្គាល់ជាជនបរទេសអន្តោប្រវេសន្ត

# APPLICATION OF RECOGNITION AS IMMIGRANT ALIEN

យោងតាមច្បាប់ស្តីពីអន្តោប្រវេសន៍ដែលបានអនុម័តកាលពីថ្ងៃទី២៦ ខែ សីហា ឆ្នាំ ១៩៩៤

Reference to Immigration Law adopted on 26 August 1994

រូបថត
Photograph
4X6

## ទិន្នន័យជីវប្រវត្តិ

## BIOGRAPHICAL DATA

1. នាម-គោត្តនាម: ........................................................................
Full name

ឈ្មោះហៅក្រៅ: .................................... ថ្ងៃ.ខែ.ឆ្នាំកំណើត: ...................... ទីកន្លែងកំណើត ....................................
Alias (If any) Date of birth Place of birth

ស្រុក .................................... ខេត្ត / ក្រុង .................................... ប្រទេស ....................................
District (Town) Province/City Country

| | | |
|---|---|---|
| 2. ភេទ ប្រុស ☐ ស្រី ☐<br>Sex Male Female | 3. ជនជាតិដើម<br>Race<br>.................................... | 4. សញ្ជាតិ<br>Nationality<br>.................................... |

5. កិនភាគបុគ្គល
Personal Particulars

-សក់ពណ៌: .................... -ភ្នែកពណ៌: .................... -កំពស់: .................... -ស្លាកស្នាមសំគាល់: ....................
Color of hair Color of eyes Height Identifying or distinguishing marks

| | |
|---|---|
| 6. អាស័យដ្ឋានបច្ចុប្បន្ន: ....................................<br>Present address<br>លេខទូរស័ព្ទ: .................... ទូរសារ ....................<br>Phone number Fax<br>អ៊ីមែល ....................................<br>Email | 7. មុខរបរ: ....................<br>Occupation |
| 8. ស្ថានភាពគ្រួសារ<br>Marital status<br>-មានគ្រួសារ ☐<br>Married<br>-នៅលីវ ☐<br>Single | 9. បើសិនជាបានរៀបការហើយ:<br>If married<br>ក. នាម.គោត្តនាមរបស់ប្រពន្ធ/ប្តី : ....................................<br>a. Name of spouse<br>ថ្ងៃ.ខែ.ឆ្នាំកំណើត ....................................<br>Date of birth |

ទីកន្លែងកំណើត : ..............................................................

place of birth

អាស័យដ្ឋានបច្ចុប្បន្ន : ..............................................................

Present address

មុខរបរ : ..............................................................

Occupation

ខ. បញ្ជីកូន

b. List of children

| នាម. គោត្តនាម<br>Full name | ភេទ<br>Sex | ថ្ងៃ ខែ ឆ្នាំកំណើត និង ទីកន្លែងកើត<br>Date and place of birth | អាស័យដ្ឋានបច្ចុប្បន្ន<br>Present Address |
|---|---|---|---|
| 1. .............................. | .......... | .............................. | .............................. |
| 2. .............................. | .......... | .............................. | .............................. |
| 3. .............................. | .......... | .............................. | .............................. |
| 4. .............................. | .......... | .............................. | .............................. |
| 5. .............................. | .......... | .............................. | .............................. |
| 6. .............................. | .......... | .............................. | .............................. |
| 7. .............................. | .......... | .............................. | .............................. |
| 8. .............................. | .......... | .............................. | .............................. |

10. ភាសាដែលអ្នកអាចនិយាយ អាន សរសេរ

List of languages you can speak , read and write

| ភាសា<br>Language | និយាយ<br>Speak | អាន<br>Read | សរសេរ<br>Write |
|---|---|---|---|
| .............................. | ☐ | ☐ | ☐ |
| .............................. | ☐ | ☐ | ☐ |
| .............................. | ☐ | ☐ | ☐ |

11. កាលបរិច្ឆេទ និងទីកន្លែងធ្លាប់ស្នាក់នៅកម្ពុជាពីមុន

List of dates and places previously visited in the Kingdom of Cambodia

| ទីកន្លែង<br>Place | គោលបំណង<br>Purpose | កាលបរិច្ឆេទនៃការស្នាក់នៅ<br>From (Date) to (Date) |
|---|---|---|
| .............................. | .............................. | .............................. |
| .............................. | .............................. | .............................. |
| .............................. | .............................. | .............................. |
| .............................. | .............................. | .............................. |
| .............................. | .............................. | .............................. |

12. ឈ្មោះឪពុក: .............................. ថ្ងៃ ខែ ឆ្នាំ កំណើត: .............................. ទីកន្លែងកំណើត: ..............................

Father's name Date of birth Place of birth

..............................................................

អាស័យដ្ឋានបច្ចុប្បន្ន: ..............................................................

Present Address

..............................................................

13. ឈ្មោះម្ដាយ:........................ ..........ថ្ងៃ ខែ ឆ្នាំ កំណើត:......................................ទីកន្លែងកំណើត:..............................
Mother's name Date of birth Place of birth

..........................................................................................................................................

អាសយដ្ឋានបច្ចុប្បន្ន:..........................................................................................................
Present Address

..........................................................................................................................................

14. មូលធនផ្ទាល់ខ្លួន..........................................................................................................
Your personal funds ($)

-មានទ្រព្យសម្បត្តិផ្សេងទៀតដែលមានតំលៃប្រមាណ $..........................................................
Estimated value of other personal property

15 ច្រកចូល :.......................................................ថ្ងៃ ខែ ឆ្នាំ ចូលកម្ពុជា..........................................
Port of entry Date of entry

## ចំណុចសំខាន់ៗ
## IMPORTANT NOTES

16. អ្នកដាក់ពាក្យសុំទាំងអស់ ត្រូវតែអាន និងឆ្លើយអោយបានសមរម្យតាមសំណួរ និមួយៗដូចតទៅ :
All applicants must read and check the appropriate box for each items

| | | |
|---|---|---|
| ក. តើអ្នកអាចជាបន្ទុករបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទេ ?<br>Are you able becoming burden of the Royal Government of Cambodia ? | បាទ ☐<br>Yes | ទេ ☐<br>No |
| ខ. តើអ្នកធ្លាប់មានជំងឺឆ្លង ជំងឺរ៉ាំរ៉ៃ ឬជំងឺខួរក្បាល ដែរឬទេ ?<br>Have you ever suffered from a communicable disease, chronic or mental disorder ? | បាទ ☐<br>Yes | ទេ ☐<br>No |
| គ. តើអ្នកធ្លាប់ប្រព្រឹត្តិជួញដូរគ្រឿងញៀន ឬ ញៀនថ្នាំ ដែរឬទេ ?<br>Have you ever had a drug addiction ? | បាទ ☐<br>Yes | ទេ ☐<br>No |
| ឃ. តើអ្នកធ្លាប់ត្រូវបានកាត់ទោសពីបទល្មើសដាក់គុកលើសពី ៥ឆ្នាំ ដែរឬទេ ?<br>Have you ever been sentenced to 5 years or more of imprisonment convicted and for any offense ? | បាទ ☐<br>Yes | ទេ ☐<br>No |
| ង. តើអ្នកធ្លាប់ប្រកបរបរពេស្យាចារ នាំពេស្យាចារអោយគេ ឬជំនួញជួញដូរមនុស្សដែរឬទេ ?<br>Have you ever been a prostitute, procurer or trafficker ? | បាទ ☐<br>Yes | ទេ ☐<br>No |
| ច. តើអ្នករិះរកវិធីចូលមកព្រះរាជាណាចក្រកម្ពុជាដើម្បីធ្វើចារកម្ម វិទ្ធង្សនកម្ម បង្ករអំពើហឹង្សា ផ្តួលរំលំរាជរដ្ឋាភិបាល សំលាប់មេដឹកនាំរបស់កម្ពុជា និង ប្រព្រឹត្តិអំពើខុសច្បាប់ផ្សេងៗទៀតមែនដែរឬទេ ?<br>Do you seek to enter the Kingdom of Cambodia to engage in espionage, terrorism, sabotage, violation of the law, overthrow the Royal Government, assassination of Cambodian leaders or commit any other activities ? | បាទ ☐<br>Yes | ទេ ☐<br>No |
| ឆ. តើអ្នកមានលទ្ធភាពអាចចិញ្ចឹមខ្លួនឯងបានដែរឬទេ ?<br>Do you have the capacity to support yourself ? | បាទ ☐<br>Yes | ទេ ☐<br>No |
| ជ. តើអ្នកធ្លាប់ត្រូវបានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាដែរឬទេ ?<br>Have you ever been deported from the Kingdom of Cambodia ?<br>Yes No | បាទ ☐ | ទេ ☐ |

| | | |
|---|---|---|
| រៀបការ Married | ☐ | -អាស័យដ្ឋាននៅកម្ពុជា: ........ Address in Cambodia |
| នៅលីវ Single | ☐ | -មុខរបរនៅកម្ពុជា: ........ Occupation in Cambodia |

). បញ្ជីរាយនាមកូនអាយុក្រោម ១៨ឆ្នាំ
List of children under 18 years old

| នាម គោត្តនាម Full name | ភេទ Sex | ថ្ងៃ ខែ ឆ្នាំ កំណើត Date of birth | ទីកន្លែងកំណើត Place of birth |
|---|---|---|---|
| )........ | ........ | ........ | ........ |
| )........ | ........ | ........ | ........ |
| )........ | ........ | ........ | ........ |
| )........ | ........ | ........ | ........ |

. ប្រកាសទទួលស្គាល់ជនបរទេសអន្តោប្រវេសន្ត
Certificate of recognition as immigrant alien

លេខ : ........ ចុះថ្ងៃទី........
N° Date

ហត្ថលេខាអ្នកស្នើសុំ
Signature of Applicant

កាលបរិច្ឆេទ
Date

## សំរាប់មន្ត្រីប្រើប្រាស់
## FOR OFFICIAL USE

| | | |
|---|---|---|
| 13. លេខ : ........ | លេខ : ........ | លេខ : ........ |
| បានឃើញ និង គោរពជូន | បានឃើញ និង បញ្ជូនមក | បានពិនិត្យ និង ឃើញថា |
| ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការ | នាយកដ្ឋានអន្តោប្រវេសន៍ដើម្បីពិនិត្យផ្តល់ជូន | សាមីខ្លួនពិតជាបានចូលមកស្នាក់នៅអាស័យដ្ឋាន |
| នគរបាលជាតិ មេត្តាពិនិត្យ និង សំរេច | ថ្ងៃទី........ ខែ........ ឆ្នាំ២០០........ | ដូចមានក្នុងសេចក្តីថ្លែងប្រកាសមែន ។ |
| ថ្ងៃទី :........ ខែ........ ឆ្នាំ ២០០........ | នាយស្នងការដ្ឋាន ន.ប ខេត្ត/ក្រុង | ថ្ងៃទី........ ខែ........ ឆ្នាំ២០០........ |
| ប្រធាននាយកដ្ឋានអន្តោប្រវេសន៍ | | នាយការិយាល័យជនបរទេស |

## សេចក្តីណែនាំ
## INSTRUCTION

រំពេញពាក្យស្នើសុំនេះចំនួន ០១ ច្បាប់ ដោយមានបិទរូបថតរបស់សាមីខ្លួន និងភ្ជាប់ជាមួយនូវរូបថតសហព័ន្ធ និងកូនអាយុក្រោម១៨ឆ្នាំម្នាក់ពីរសន្លឹក ។
ase fill 1 page of this form and attach your spouse, your children and your own photographs ( 2 photographs each person )

ភ្ជាប់ជាមួយនូវ : -ប្រកាសទទួលស្គាល់ជនបរទេសអន្តោប្រវេសន្ត
u must attach : - Your certificate of recognition as immigrant alien
-សេចក្តីចំលងលិខិតបញ្ជាក់ ស្តីអំពីការតំកល់ប្រាក់សំរាប់មាតុភូមិនិវត្តន៍ជាយថាហេតុ
A copy of Certificate of money deposit for the eventual repatriation
-បង្កាន់ដៃបង់អាករប័ណ្ណស្នាក់នៅ
Receipt of Permanent Resident-Card

# គំរូប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍
# សំរាប់ជនបរទេសអន្តោប្រវេសន្ត
# (ចេញឱ្យលើកដំបូង)

~~~~~

- មើលពីខាងមុខ

បណ្តោយ ៨.៥០ សម

ទទឹង ៥.៤០ សម

រូបព្រះសិង្ហា
ពណ៌ទឹកមាស




អក្សរពណ៌ខ្មៅ

ផ្ទៃខាងមុខទាំងមូលពណ៌ស

- មើលពីខាងក្រោយ

អក្សរពណ៌ខ្មៅ

ផ្ទៃផ្នែកខាងក្រោយ
ទាំងមូលពណ៌
ផ្ទៃមេឃ និងមាន
ស្រមោលរូបសិង្ហ


~~~~~

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ:...............

រូបថតទំហំ
៤ គុណ ៦
Photograph
4 X 6

# ប្រកាស

## ស្តីពីការទទួលស្គាល់ជនបរទេសអន្តោប្រវេសន្ត

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២.ន.ស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រមលេខ ០៥.ន.ស.៩៤ ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីអន្តោប្រវេសន៍ ។
- បានឃើញអនុក្រឹត្យលេខ ៣០អនក្រ/បក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីបែបបទអនុវត្ត ចំពោះការអនុញ្ញាតអោយជនបរទេសអន្តោប្រវេសន្ត ចេញ-ចូល និងស្នាក់នៅ ក្នុងព្រះរាជាណាចក្រកម្ពុជា ។
- បានពិនិត្យសំណុំឯកសារ នៃពាក្យស្នើសុំការទទួលស្គាល់ជាជនបរទេសអន្តោប្រវេសន្ត របស់លោក-លោកស្រី

................................................................................ ចុះថ្ងៃទី ............../............../.................. ។

## ស ំ រ េ ច

ប្រការ១ : ទទួលស្គាល់ឈ្មោះ......................................................ភេទ............ថ្ងៃខែឆ្នាំកំណើត............/............/..............
លេខលិខិតបញ្ជាក់ :........................................................................................................................
សញ្ជាតិ..............................ចុះថ្ងៃទី............/............/............និង មានកូនឈ្មោះ ( អាយុក្រោម១៨ឆ្នាំចុះ ) រួមមាន :
១ ..........................................................................ភេទ............ថ្ងៃខែឆ្នាំកំណើត.........../.........../..................
២...........................................................................ភេទ............ថ្ងៃខែឆ្នាំកំណើត.........../.........../..................
៣...........................................................................ភេទ............ថ្ងៃខែឆ្នាំកំណើត.........../.........../..................
៤...........................................................................ភេទ............ថ្ងៃខែឆ្នាំកំណើត.........../.........../..................
ជាជនបរទេសអន្តោប្រវេសន្ត។

ប្រការ២ : ជនបរទេសអន្តោប្រវេសន្ត ដូចមានក្នុងប្រការ១ មានកាតព្វកិច្ចគោរព និងអនុវត្តច្បាប់ស្តីពីអន្តោប្រវេសន៍ នៃព្រះរាជាណាចក្រកម្ពុជាអោយបានម៉ឺងម៉ាត់ ។

ប្រការ៣ : អគ្គលេខាធិការ អគ្គស្នងការនគរបាលជាតិ អគ្គនាយករដ្ឋបាលមូលដ្ឋាន អាជ្ញាធរខេត្ត-ក្រុង ស្ថាប័នក្រោមឱវាទ ក្រសួងមហាផ្ទៃដែលមានការពាក់ព័ន្ធ និងសាម៉ីខ្លួន ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០......

រ ដ្ឋ ម ន្ត្រី

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាខេត្ត-ក្រុងពាក់ព័ន្ធ
- ដូចប្រការ ៣
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

---

# ពាក្យសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍សំរាប់ជនបរទេសអន្តោប្រវេសន្ត
# APPLICATION OF PERMANENT RESIDENT-CARD FOR IMMIGRANT ALIEN

យោងតាមច្បាប់ស្តីពីអន្តោប្រវេសន៍ដែលបានអនុម័តកាលពីថ្ងៃទី២៦ ខែ សីហា ឆ្នាំ ១៩៩៤
Reference to Immigration Law adopted on 26 August 1994

រូបថត
Photograph
4X6

---

នាម-គោត្តនាម: ........................................................................
ull name

ឈ្មោះហៅក្រៅ: .................... ថ្ងៃ ខែ ឆ្នាំកំណើត: .................... ទីកន្លែងកំណើត ....................
lias (If any) Date of birth Place of birth

ស្រុក .................... ខេត្ត / ក្រុង .................... ប្រទេស ....................
istrict (Town) Province/City Country

| ភេទ ប្រុស ☐ ស្រី ☐<br>Male Female | 3. ជនជាតិដើម<br>Race<br>.................... | 4. សញ្ជាតិ<br>Nationality<br>.................... |
|---|---|---|

នភាគបុគ្គល
ersonal Particulars

ក់ពណ៌: .................... -ភ្នែកពណ៌: .................... -កំពស់: .................... -ស្លាកស្នាមសំគាល់: ....................
lor of hair Color of eyes Height Identifying or distinguishing marks

ាស័យដ្ឋាននៅកម្ពុជា
ddress in Cambodia

ះលេខ .................... ផ្លូវលេខ .................... សង្កាត់ .................... ខណ្ឌ-ស្រុក .................... ខេត្ត-ក្រុង ....................
ouse N° Street N° Commune District Province. City

ទូរស័ព្ទ .................... ទូរសារ .................... Email ....................
one number Fax

មុខរបរនៅកម្ពុជា: ........................................................................
cupation in Cambodia

| នភាពគ្រួសារ<br>larital status | 9. នាម គោត្តនាម ប្តី / ប្រពន្ធ: ....................<br>Full name of spouse<br>-ថ្ងៃ ខែ ឆ្នាំកំណើត .................... ទីកន្លែងកំណើត: ....................<br>Date of birth Place of birth |
|---|---|

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

# ពាក្យសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ទុតិយតា
# APPLICATION FOR PERMANENT RESIDENT-CARD ( DUPLICATE )

យោងតាមច្បាប់ស្តីពីអន្តោប្រវេសន៍ដែលបានអនុម័តកាលពីថ្ងៃទី២៦ ខែ សីហា ឆ្នាំ ១៩៩៤
Reference to Immigration Law adopted on 26 August 1994

រូបថត
Photograph
4X6

ាម-គោត្តនាម:.................................................. ឈ្មោះហៅក្រៅ ..............................
ull name Alias

ខែ.ឆ្នាំកំណើត:.............................. ទីកន្លែងកំណើត: ស្រុក .......................... ខេត្ត.......................... ប្រទេស...............................
te of birth Place of birth: District Province Country

ភេទ ប្រុស ☐ ស្រី ☐
Sex Male Female

3. ជនជាតិដើម
Race
..............................

4. សញ្ជាតិ
Nationality
..............................

ទីលំនៅបច្ចុប្បន្ន : ផ្ទះលេខ............ផ្លូវលេខ..............សង្កាត់...........................ខ័ណ្ឌ/ស្រុក.............................ខេត្ត...........................
Present address # Street N° Commune District Province

ទូរស័ព្ទលេខ:....................................... ទូរសារ................................................. អ៊ីម៉ែល.....................................................
Phone number Fax E-mail

មុខរបរនៅកម្ពុជា:.................................................................. 7. កាន់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍លេខ:..........................................
Occupation in Cambodia Holding Permanent Resident-Card N°

មូលហេតុនៃការស្នើសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ( ទុតិយតា ).....................................................................................
The reason of applying for Permanent Resident-Card (Duplicate) of Immigrant Alien

ហត្ថលេខាអ្នកស្នើសុំ កាលបរិច្ឆេទ
Signature of Applicant Date

## សំរាប់មន្ត្រីប្រើប្រាស់
## FOR OFFICIAL USE

| | | |
|---|---|---|
| លេខ :................................<br>បានឃើញ និង គោរពជូន<br>ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការ<br>នគរបាលជាតិ មេត្តាពិនិត្យ និង សំរេច<br>ថ្ងៃទី :..............ខែ...............ឆ្នាំ ២០០........<br>ប្រធាននាយកដ្ឋានអន្តោប្រវេសន៍ | លេខ:..........................<br>បានឃើញ និង បញ្ជូនមក<br>នាយកដ្ឋានអន្តោប្រវេសន៍ដើម្បីពិនិត្យផ្តល់ជូន ។<br>ថ្ងៃទី........... ខែ............. ឆ្នាំ២០០.......<br>នាយស្នងការដ្ឋាន ន.ប.ខេត្ត ក្រុង | លេខ:........................<br>បានពិនិត្យសេចក្តីក្នុងពាក្យស្នើសុំនិងបញ្ជាក់ថា :<br>................................................<br>................................................<br>ថ្ងៃទី:.......... ខែ............. ឆ្នាំ២០០.........<br>នាយការិយាល័យជនបរទេស |

សំគាល់ : - ត្រូវបំពេញពាក្យស្នើសុំនេះចំនួន ១ច្បាប់ ដោយភ្ជាប់មកជាមួយនូវរូបថតរបស់សាមីជនចំនួន ២សន្លឹក ។
ction Please fill 1 of this form, attach with 2 of your own photographs
- ត្រូវភ្ជាប់មកជាមួយនូវបង្កាន់ដៃបង់អាករ សុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ( ទុតិយតា)
Please attach receipt of the fee paid for the Permanent Resident-Card (Duplicate)

[illegible] Immigration Department Address [illegible]

# គំរូប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ (ទុតិយភាគ)
# សំរាប់ជនបរទេសអន្តោប្រវេសន្ត

----------

- មើលពីខាងមុខ

បណ្តោយ ៨.៥០ សម

រូបព្រះសិង្ហា
ពណ៌ទឹកមាស




ទទឹង ៥.៤០ សម

អក្សរពណ៌ខ្មៅ

ផ្ទៃខាងមុខទាំងមូលពណ៌ស

- មើលពីខាងក្រោយ

ផ្ទៃផ្នែកខាងក្រោយ
ទាំងមូលពណ៌
ទឹកក្រូច និងមាន
ស្រមោលរូបសិង្ហ




អក្សរពណ៌ខ្មៅ

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

---

# ពាក្យស្នើសុំលិខិតបើកផ្លូវ
## APPLICATION FOR LAISSEZ-PASSER

យោងតាមច្បាប់ស្តីពីអន្តោប្រវេសន៍ដែលបានអនុម័តកាលពីថ្ងៃទី២៦ ខែ សីហា ឆ្នាំ ១៩៩៤
Reference to Immigration Law adopted on 26 August 1994

| រូបថត 4 x 6 |
|---|

| | |
|---|---|
| ...ាម-គោត្តនាម: ........ (...ull name) | ឈ្មោះហៅក្រៅ ........ (Alias (If any)) |
| ...ខែ.ឆ្នាំកំណើត: ........ (...ate of birth) ទីកន្លែងកំណើត : ស្រុក: ........ (Place of birth District) ខេត្ត: ........ (Province) ប្រទេស: ........ (Country) | |
| ...ភេទ (...ex) ប្រុស ☐ (Male) ស្រី ☐ (Female) | 3. សញ្ជាតិ ........ (Nationality) |
| ...លំនៅបច្ចុប្បន្ន : ផ្ទះលេខ........ (...resent address #) ផ្លូវលេខ........ (Street) សង្កាត់........ (Commune) ខណ្ឌ/ស្រុក........ (District) ខេត្ត........ (Province) | |
| ...ទូរស័ព្ទលេខ: ........ (...hone number) ទូរសារ........ (Fax) E-mail........ | |
| ...មុខរបរ: ........ (...ccupation) | 8. ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍លេខ: ........ (Permanent Resident Card N°) ចុះថ្ងៃទី........ (Date issued) មានតំលៃដល់........ (Valid until) |
| ...ប្រទេសដែលធ្វើដំណើរ: ........ (...estination countries) | 10. គោលបំណងធ្វើដំណើរ: ........ (Purpose of journey) |
| ...ច្រកចេញ-ចូល ........ (...ort of Exit-Entry) | 12. មធ្យោបាយធ្វើដំណើរ........ (Means of transportation) |
| ...ស្នើសុំចេញ-ចូល: ........ (...umber of Journeys applied for) | 14. អ្នករួមដំណើរ: ........ (Accompanying persons (Names)) |
| ...ហត្ថលេខាអ្នកសុំ (...ature of applicant) | កាលបរិច្ឆេទ: (Date) |

...ណែនាំ : (...ction)

១. សូមបំពេញតំរូវនេះ ១ ច្បាប់អោយបានច្បាស់ៗដោយភ្ជាប់មកជាមួយនូវរូបថត ៤ X ៦ ចំនួន២សន្លឹក ។
Please fill in legibly and provide 2 full face 4 x 6 cm. photographs.

២. ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ។
Attached 1 copy of permanent Resident Card.

៣. លិខិតអនុញ្ញាតិពីឪពុកម្តាយ ប្រសិនបើជាអនីតិជន ។
Attach Permission from parents, if minor (up to 17 years old).

៤. ត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនប័ត្រជនបរទេសអន្តោប្រវេសន្ត ។
Attach a copy of Certificate of Immigrant Alien's status

៥. ត្រូវភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតិអោយចាកចេញពីព្រះរាជាណាចក្រកម្ពុជាមួយរយៈពេល ។
Attached permission to leave the Kingdom of Cambodia for a period of time.

៦. បង្កាន់ដៃអាករលិខិតបើកផ្លូវ ។
Receipt of fee paid for Laissez-Passer .

[illegible] Immigration Department Address: Russian Federation Blvd. opposite of Phnom Penh International Airport. Tel: 023 [illegible] Fax: 023 [illegible]

ក្រសួងមហាផ្ទៃ

MINISTRY OF INTERRIOR

នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

DEPARTMENT OF PLANNING ECONOMY AND FINANCE

បង្កាន់ដៃទទួលអាករប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍សំរាប់ជនបរទេសអន្តោប្រវេសន្ត

Receipt of Permanent resident's fee for immigrant alien

លេខ............................ N° ............................

ទទួលពីលោក.................................................................. សញ្ជាតិ..................................
Received from Nationality

ចំនួនទឹកប្រាក់.................................................. សរសេរជាអក្សរ..................................................
Amount in writing

ប្រភេទចំណូល..............................................................................................................
Type of income

ថ្ងៃទី..................................
Date ..................................

| | | |
|---|---|---|
| ប្រធានអង្គភាព<br>Director | អ្នកបង់ប្រាក់<br>Payer | អ្នកទទួលប្រាក់<br>Receiver |

ក្រសួងមហាផ្ទៃ

MINISTRY OF INTERRIOR

នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

DEPARTMENT OF PLANNING ECONOMY AND FINANCE

បង្កាន់ដៃទទួលអាករប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍សំរាប់ជនបរទេសអន្តោប្រវេសន្ត

Receipt of Permanent resident's fee for immigrant alien

លេខ............................ N° ............................

ទទួលពីលោក.................................................................. សញ្ជាតិ..................................
Received from Nationality

ចំនួនទឹកប្រាក់.................................................. សរសេរជាអក្សរ..................................................
Amount in writing

ប្រភេទចំណូល..............................................................................................................
Type of income

ថ្ងៃទី..................................
Date ..................................

| | | |
|---|---|---|
| ប្រធានអង្គភាព<br>Director | អ្នកបង់ប្រាក់<br>Payer | អ្នកទទួលប្រាក់<br>Receiver |

ក្រសួងមហាផ្ទៃ

MINISTRY OF INTERRIOR

នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

DEPARTMENT OF PLANNING ECONOMY AND FINANCE

បង្កាន់ដៃទទួលអាករលិខិតបើកផ្លូវសំរាប់ជនបរទេសអន្តោប្រវេសន្ត

Receipt of Laissez-Passer's fee for immigrant alien

លេខ............................ N° ............................

ទទួលពីលោក.................................................................. សញ្ជាតិ..................................
Received from Nationality

ចំនួនទឹកប្រាក់.................................................. សរសេរជាអក្សរ..................................................
Amount in writing

ប្រភេទចំណូល..............................................................................................................
Type of income

ថ្ងៃទី..................................
Date ..................................

| | | |
|---|---|---|
| ប្រធានអង្គភាព<br>Director | អ្នកបង់ប្រាក់<br>Payer | អ្នកទទួលប្រាក់<br>Receiver |

ក្រសួងមហាផ្ទៃ

MINISTRY OF INTERRIOR

នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

DEPARTMENT OF PLANNING ECONOMY AND FINANCE

បង្កាន់ដៃទទួលអាករលិខិតបើកផ្លូវសំរាប់ជនបរទេសអន្តោប្រវេសន្ត

Receipt of Laissez-Passer's fee for immigrant alien

លេខ............................ N° ............................

ទទួលពីលោក.................................................................. សញ្ជាតិ..................................
Received from Nationality

ចំនួនទឹកប្រាក់.................................................. សរសេរជាអក្សរ..................................................
Amount in writing

ប្រភេទចំណូល..............................................................................................................
Type of income

ថ្ងៃទី..................................
Date ..................................

| | | |
|---|---|---|
| ប្រធានអង្គភាព<br>Director | អ្នកបង់ប្រាក់<br>Payer | អ្នកទទួលប្រាក់<br>Receiver |

# តារាងស្តីអំពីការលើកលែងទិដ្ឋាការរវាងកម្ពុជា និង ប្រទេសនានា

| ល.រ | ប្រទេស | លិខិតឆ្លងដែន | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ការទូត | ផ្លូវការ | [illegible] | |
| I - ប្រទេសសមាជិកអាស៊ាន | | | | | |
| 1. | Brunei Darus( Bru ) | ១៤ ថ្ងៃ | ១៤ ថ្ងៃ | | |
| 2. | Indonesia ( IDN) | ១៤ ថ្ងៃ | ១៤ ថ្ងៃ | | ដោយឡែកអ្នកបំពេញបេសកកម្ម ការទូតគឺត្រូវស្នើសុំទិដ្ឋាការជាមុនសិន |
| 3. | Lao P.D.R ( Lao ) | ៣០ ថ្ងៃ | ៣០ ថ្ងៃ | ៣០ ថ្ងៃ | |
| 4. | Malaysia ( Mys ) | ៣០ ថ្ងៃ | ៣០ ថ្ងៃ | ៣០ ថ្ងៃ | |
| 5. | Myanmar ( MMR ) | ៣០ ថ្ងៃ | ៣០ ថ្ងៃ | | |
| 6. | Philippines ( PHL ) | ៣០ ថ្ងៃ | ៣០ ថ្ងៃ | ២១ ថ្ងៃ | |
| 7. | Singapore ( SGP ) | ៣០ ថ្ងៃ | ៣០ ថ្ងៃ | ៣០ ថ្ងៃ | ចាប់អនុវត្ត ០១.០១.២០០៦ |
| 8. | Thailand ( THA ) | ៣០ ថ្ងៃ | ៣០ ថ្ងៃ | | |
| 9. | Viet Nam ( VN ) | ៩០ ថ្ងៃ | ៩០ ថ្ងៃ | | |
| II – ប្រទេសផ្សេងៗ | | | | | |
| 1. | Bulgaria ( BUL ) | ៩០ ថ្ងៃ | ៩០ ថ្ងៃ | | |
| 2. | Hungaria ( HUN ) | ៩០ ថ្ងៃ | ៩០ ថ្ងៃ | | |
| 3. | China ( CHN ) | ៣០ ថ្ងៃ | ៣០ ថ្ងៃ | | លេខ២០០០កបទ.សអ/ឡក១ ០៤.០៩.០៦ អនុវត្ត ១៤.០៩.០៦ |
| 4. | India ( IND ) | ៦០ ថ្ងៃ | ៦០ ថ្ងៃ | | |
| 5. | Korea,South( KOR ) | ៦០ ថ្ងៃ | ៦០ ថ្ងៃ | | លេខ៣៩៩៥កបទ.សអ/ឡក១ ០១.១២.០៦ អនុវត្ត ២១.១២.០៦ |
| 6. | Cuba ( CUB ) | [illegible] | | | |
| 7. | Russia ( RUS ) | [illegible] | | | |
| 8. | Slovakia ( SVK ) | [illegible] | | | |

<u>សំគាល់</u>: បើគំរោងស្នាក់នៅក្នុងប្រទេសណាមួយលើសពីកាអនុញ្ញាតខាងលើនេះ គឺត្រូវស្នើសុំទិដ្ឋាការជាមុនសិន។

* គួរស្នើសុំលិខិតបញ្ជាក់ពីស្ថានទូតខាងលើជាមុនសិន ដើម្បីជៀសវាងការលំបាកផ្សេងៗជាមួយក្រុមហ៊ុនអាកាសចរណ៍។

បានចម្លងត្រឹមត្រូវតាមច្បាប់ដើមនៃនាយកដ្ឋានច្បាប់និងកុងស៊ុល

និងលិខិតរបស់ការិយាល័យច្រកទ្វារព្រំដែននាយកដ្ឋានអន្តោប្រវេសន៍

ព្រះរាជាណាចក្រកម្ពុជា

# ពាក្យសុំទិដ្ឋាការ

# VISA APPLICATION FORM

ម និង គោត្តនាម
ll name........................................................................................

-ខែ-ឆ្នាំកំណើត ទីកន្លែងកំណើត
ate of birth.......................................Place of birth.......................................

ជាតិ ភេទ Male ☐
ationality.......................................Sex Female ☐

ខលិខិតឆ្លងដែន កន្លែងផ្តល់
ssport number.......................................Issued at.......................................

ល់នៅថ្ងៃទី ផុតកំណត់នៅថ្ងៃទី
ate of issued.......................................Expiry date.......................................

សយដ្ឋានបច្ចុប្បន្ន
rmanent address.......................................................................................

.......................................................................................................

ដល់កម្ពុជានៅថ្ងៃទី តាមច្រក
ate of arrival.......................................Port of entry.......................................

ជើងយន្តហោះ មកពី
ight number.......................................From.......................................

គោលបំណងនៃទស្សនកិច្ច
urpose of visit.......................................................................................

.......................................................................................................

.......................................................................................................

កុមារក្រោមអាយុ ១២ ឆ្នាំដែលប្រើប្រាស់លិខិតឆ្លងដែនជាមួយឪពុក-ម្តាយ
Children under 12 years old travelling with their parents and using the same passport.
*( Include full name, sex and date of birth )*

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

អាសយដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា
Address during your trip in Cambodia.......................................................................

.......................................................................................................

.......................................................................................................

I hereby declare that the information on this form is complete and correct.

ធ្វើនៅថ្ងៃទី
Date.......................................

Signature

**Photograph**
Please attach a recent passport photograph of yourself
4 X 6

Official use only

ប្រភេទទិដ្ឋាការ :.......................................
លេខទិដ្ឋាការ :.......................................
ថ្ងៃ-ខែ-ផ្តល់ :.......................................
រយៈពេលស្នាក់នៅ :.......................................
អ្នកពិនិត្យ :.......................................
អ្នកផ្តល់ :.......................................

<u>កំណត់សំគាល់</u>

.......................................

.......................................

.......................................

.......................................

.......................................

.......................................

.......................................

.......................................

.......................................

.......................................

.......................................

.......................................

សលាកប័ត្រចូល
ARRIVAL CARD Nº 566674

Family name ____________________

Given name ____________________ Sex M / F

Place of birth ____________________

Date of birth __________ Nationality __________

Passport Nº ____________________

Type of transportation: Flight Nº ____ Ship ____ Car ____ Train ____

Arriving from ____________________

Type Visa Nº __________ Place of issue __________

Purpose of visit __________ Length of stay __________

Address in Cambodia ____________________

Signature ____________________

For official use

---

សលាកប័ត្រចេញ
DEPARTURE CARD Nº 566674

Family name ____________________

Given name ____________________ Sex M / F

Place of birth ____________________

Date of birth __________ Nationality __________

Passport Nº ____________________

Type of transportation: Flight Nº ____ Ship ____ Car ____ Train ____

Destination ____________________

FOR CAMBODIAN ONLY

Signature ____________________

For official use

---

## NOTICE

1. THIS CARD MUST BE WITH YOUR PASSPORT AT ALL TIMES DURING YOUR STAY IN CAMBODIA
2. THIS CARD MUST BE HANDED BACK TO THE IMMIGRATION POLICE UPON DEPARTURE
3. IF YOU WISH TO STAY LONGER THAN PERMITTED PLEASE APPLY FOR VISA EXTENSION FROM THE IMMIGRATION AUTHORITY
4. THIS CARD MUST BE CLEARLY COMPLETED BY EVERY PASSENGER

Printed by Cambodian Immigration
Reproduction prohibited

---

ព្រះរាជាណាចក្រកម្ពុជា
# KINGDOM OF CAMBODIA





សលាកប័ត្រ ចូល-ចេញ
## ARRIVAL/DEPARTURE CARD




☞កំណត់ការស្នាក់នៅរយៈពេល បីខែចូលមកព្រះរាជាណាចក្រកម្ពុជា ដំបូងសំរាប់ប្រភេទទិដ្ឋាការ *A, B, C* ប្រភេទមួយដង ឬ *Single* អាចពន្យាពេលមួយដង ឬច្រើនដង ។




☞កំណត់ការស្នាក់នៅមួយខែ ពេលចូលមកដល់ព្រះរាជាណាចក្រកម្ពុជា សំរាប់ប្រភេទទិដ្ឋាការ *T* និង *E* និងពន្យាពេលស្នាក់នៅ

- ប្រភេទ *T* មួយដង សំរាប់ការចេញចូលបានមួយដង
- ប្រភេទ *E* មួយដង ឬច្រើនដងសំរាប់ការចេញចូល




☞កំណត់ការស្នាក់នៅមួយខែ ចូលមកដល់ព្រះរាជាណាចក្រកម្ពុជា សំរាប់ប្រភេទទិដ្ឋាការ *T* អេឡិចត្រូនិច *T-evisa* អាចពន្យាពេលបានតែមួយដង ការចេញមួយដង ។



☞សំរាប់ប្រភេទទិដ្ឋាការ *A, B, C* ចេញចូលច្រើនដង

☞សំរាប់ប្រភេទទិដ្ឋាការ *E* ចេញចូលច្រើនដង

☞សំរាប់ប្រភេទទិដ្ឋាការ *K* ចេញចូលគ្មានការកំណត់

☞សំរាប់លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា




☞សំរាប់ការចេញដំណើររបស់ប្រជាពលរដ្ឋខ្មែរក៏ដូចជាជនបរទេសគ្រប់ប្រភេទ ដែលមានបំណងចាកចេញពីព្រះរាជាណាចក្រកម្ពុជាតាមផ្លូវច្បាប់ ។

## Kingdom of Cambodia e-Visa



Visa No
200705000079[illegible]

NEVILLE

CHRISTOPHER JOHN

CANADA

| | | |
|---|---|---|
| 18JUL1961 | [illegible]873487 | M |
| TOURIST | 30DAYS | 0 |
| 14MAY2007 | 14AUG2007 | |

Note: Length of stay not more than 30 days from visa entry date, Employment Prohibited.
This electronic visa is officially issued by Ministry of Foreign Affairs and International Cooperation, Kingdom of Cambodia. All Rights Reserved.

Hor Monirath

Reminder

1. Your credit card will be charged under the name of "PAYPAL*EVISA".
2. Your e-Visa is only valid for one(1) entry only.
3. Please print out 2 copies of this e-Visa certificate.
   Pass one(1) copy to immigration as your Travel Visa at entry
   and one(1) upon departure.
4. e-Visa printout in black and white is acceptable.
5. No sticker will be issued to you for e-Visa. You may need
   to cut your printed e-Visa and stapled to your passport.
6. All your information will be checked on arrival at the Immigration Online System.
7. At the checkpoint, please go directly to the e-Visa immigration counter for processing.
   Look for e-Visa signboard. If you are not sure, please approach the officer
   for instructions to avoid unnecessary delay.
8. Entry to invalid e-Visa ports is prohibited.
9. e-Visa fee is non-refundable.
10. If you have any question, please contact us at http://evisa.mfaic.gov.kh.
11. You are required to fill out departure and arrival cards at the entry and exit point.

USED

Issuing Post: Phnom Penh I.A. ... Fee: 25 USD

Surname: PARK

Given Name: SANG KYOO ... Sex: F

Passport Number: 0836986

I 0531822 Entries: 01 ... 25.10.03 ... 25.11.03

Remarks:

Holder permitted to remain in Cambodia for 01 months from ...

Maj. Chhe ...
Chief of Visa Service

# KINGDOM OF CAMBODIA

Extension of stay

Issuing Post: ... Fee: ...

Surname: PARK SANG-KYOO

Given Name:

Passport Number: DG0836986

EI 00002535 Entry: SINGL ... Issue Date: 03 JUN 2007

Expiry Date: 03 JUL 2007

Remarks: T02C00234

Hok-Tundy


# KINGDOM OF CAMBODIA

Extension of stay

Issuing Post: ... Fee: ...

Surname: PARK SANG-KYOO

Given Name:

Passport Number: DG0836986

EI 00002535 Entry: Multiple ... Issue Date: 03 JAN 2007

Expiry Date: 03 JUL 2007

Remarks: T02C00234

Hok-Tundy

KINGDOM OF CAMBODIA - VISA

HEA Pheak Gratis
CONGELO
PHILIPPE A
EE 292 168
F042603 M 19060? 300608
EMBASY

KER Vicseth
Deputy Director
Legal and Consular Department

KINGDOM OF CAMBODIA - VISA

HEA Pheak Gratis
CONGELO
PHILIPPE B
EE 292 168
F042603 M 19060? 300608

KER Vicseth
Deputy Director
Legal and Consular Department

KINGDOM OF CAMBODIA - VISA

HEA Pheak Gratis
CONGELO
PHILIPPE C
EE 292 168
F042603 M 19060? 300608

KER Vicseth
Deputy Director
Legal and Consular Department

# លទ្ធផល
# ស្តីពី
# យុទ្ធនាការធ្វើជំរឿនស្ថិតិជនបរទេស
(ពី ១៥ ឧសភា ដល់ ១៥ វិច្ឆិកា ២០០២)

~~~~~~~~

១. របាយការណ៍ របស់គណៈកម្មការជំរឿននិងគ្រប់គ្រងជនបរទេស ក្រសួងមហាផ្ទៃ ចុះថ្ងៃទី១៥ ធ្នូ ឆ្នាំ២០០៤ ស្តីពី យុទ្ធនាការធ្វើជំរឿនស្ថិតិជនបរទេស.
~~~~~~~~

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល

ក្រសួងមហាផ្ទៃ

គណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេស

លេខៈ ............

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ ២០០៤

## <u>គោរពជូន និង ទូលថ្វាយ</u>

ឯកឧត្តម និង សម្តេច ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

<u>កម្មវត្ថុ</u> : របាយការណ៍ ស្តីពី យុទ្ធនាការធ្វើជំរឿនស្ថិតិជនបរទេស

<u>យោង</u> : ច្បាប់ស្តីពីអន្តោប្រវេសន៍ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០៥.នស.៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០២ ។

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ គណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេស មានកិត្តិយសសូមគោរពរាយការណ៍ជូន និង ទូលថ្វាយ ឯកឧត្តម សម្តេច មេត្តាជ្រាប ទ្រង់ជ្រាបថា : ក្នុងគោលបំណងដើម្បីពង្រឹងការអនុវត្តន៍ច្បាប់អន្តោប្រវេសន៍ អោយបានពេញលេញ និង មានប្រសិទ្ធិភាព ទប់ស្កាត់ការជ្រៀតចូល ដោយខុសច្បាប់របស់ជនបរទេស រក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម និង ការពារសុវត្ថិភាព ជូនជនបរទេសគ្រប់រូបដែលស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

កាលពីថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០០០ ក្រសួងមហាផ្ទៃបានចេញផែនការលេខ០១១៩.ក ស្តីពីយុទ្ធនាការជំរឿនស្ថិតិជនបរទេស ដើម្បីរាប់ចំនួនជនបរទេសដែលបានចូលមកតាំងទីលំនៅ ជារបៀបអន្តោប្រវេសន្ត និង ពិនិត្យសិក្សាបញ្ហាជាក់ស្តែង បំរើអោយការត្រិះរិះពិចារណាការដោះស្រាយ ស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ។

ផែនការនេះត្រូវបានចាត់តាំងអនុវត្តជាក់ស្តែងក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដោយមានឯកឧត្តមអភិបាល ឬអភិបាលរង និង ស្នងការនគរបាលខេត្ត-ក្រុង ចូលរួមដឹកនាំលើភូមិសាស្ត្រទទួលខុសត្រូវរបស់ខ្លួន ចាប់ពីថ្ងៃទី ១៥ ខែ ឧសភា ដល់ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០២ ហើយបានបញ្ចប់ទៅដោយលទ្ធផលល្អប្រសើរ ។

គណៈកម្មការ សូមរាយការណ៍ជូន ឯកឧត្តម និង ទូលថ្វាយ សម្តេច ដូចខាងក្រោម :

<u>I-អំពីលទ្ធផលនៃការស្រង់ស្ថិតិ</u> :

តាមរបាយការណ៍ទទួលបានពីបណ្តាខេត្ត-ក្រុង ទាំងអស់ដែលបានផ្ញើមក មានជនបរទេសដែលស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានស្រង់ស្ថិតិចំនួនៈ <u>១៩.៤៣៧គ្រួសារ មានចំនួនមនុស្ស ៧០.០១២នាក់</u> ក្នុងនោះ

មានប្រុស ៣៥.៣៧៨នាក់ មានអាយុពី១៦-១៧ឆ្នាំ ៣.៥៩៩នាក់ ( ប្រុស១.៨៩៧នាក់ ) និងអាយុពី១៨ឆ្នាំឡើងទៅ ៤២.៣២២នាក់ ( ប្រុស ២១.២៦៣នាក់ ) ។

ជាមួយនឹងតួរលេខរួមខាងលើនេះ គណៈកម្មការបានធ្វើការវិភាគទិន្នន័យដូចតទៅ :

ក.ភូមិសាស្ត្រតាំងលំនៅ

យើងសង្កេតឃើញថា ជនបរទេសទាំងនេះភាគច្រើនប្រមូលផ្ដុំរស់នៅរាជធានីភ្នំពេញ និង បណ្ដាខេត្តជាប់ដងទន្លេមេគង្គ និង ទន្លេសាប :

| | | | | | |
|---|---|---|---|---|---|
| ១. | រាជធានីភ្នំពេញ | មាន | ៦.៣៩៤ | គ្រួសារ | មនុស្ស ២០.៩៦០នាក់ |
| ២. | កំពង់ឆ្នាំង | មាន | ២.៨៤០ | គ្រួសារ | មនុស្ស ១២.៥៣០នាក់ |
| ៣. | កណ្ដាល | មាន | ២.២៧៩ | គ្រួសារ | មនុស្ស ១០.៤៨៩នាក់ |
| ៤. | ព្រៃវែង | មាន | ១.៨៥៩ | គ្រួសារ | មនុស្ស ៧.២៥៥នាក់ |
| ៥. | សៀមរាប | មាន | ៩៩៧ | គ្រួសារ | មនុស្ស ២.៣៨២នាក់ |
| ៦. | ពោធិសាត់ | មាន | ៦៩៩ | គ្រួសារ | មនុស្ស ២.៦៥៤នាក់ |
| ៧ | ក្រចេះ | មាន | ៦២៨ | គ្រួសារ | មនុស្ស ២.៧២៤នាក់ |
| ៨. | ក្រុងព្រះសីហនុ | មាន | ៥៥០ | គ្រួសារ | មនុស្ស ១.៦៦៤នាក់ |
| ៩. | បន្ទាយមានជ័យ | មាន | ៤៦៧ | គ្រួសារ | មនុស្ស ៩៨៣នាក់ |
| ១០. | កោះកុង | មាន | ៣៩៦ | គ្រួសារ | មនុស្ស ១.១៩១នាក់ |
| ១១. | កំពង់ចាម | មាន | ៣៨៦ | គ្រួសារ | មនុស្ស ១.៣៦៥នាក់ |
| ១២. | រតនៈគិរី | មាន | ៣០០ | គ្រួសារ | មនុស្ស ៨៩១នាក់ |
| ១៣. | កំពង់ធំ | មាន | ២៩៣ | គ្រួសារ | មនុស្ស ១.១០៦នាក់ |
| ១៤. | តាកែវ | មាន | ២៧០ | គ្រួសារ | មនុស្ស ១.០៥៩នាក់ |
| ១៥. | បាត់ដំបង | មាន | ២៣៦ | គ្រួសារ | មនុស្ស ៥១០នាក់ |
| ១៦. | ស្ទឹងត្រែង | មាន | ២៣៦ | គ្រួសារ | មនុស្ស ៩២៩នាក់ |
| ១៧. | កំពង់ស្ពឺ | មាន | ១៤៧ | គ្រួសារ | មនុស្ស ៤៩១នាក់ |
| ១៨. | កំពត | មាន | ១១៥ | គ្រួសារ | មនុស្ស ២៥៥នាក់ |
| ១៩. | ស្វាយរៀង | មាន | ១០១ | គ្រួសារ | មនុស្ស ១៨៤នាក់ |
| ២០. | ក្រុងប៉ៃលិន | មាន | ៨៧ | គ្រួសារ | មនុស្ស ១១០នាក់ |
| ២១. | ឧត្ដរមានជ័យ | មាន | ៥៨ | គ្រួសារ | មនុស្ស ៧៤នាក់ |
| ២២. | ព្រះវិហារ | មាន | ៥៤ | គ្រួសារ | មនុស្ស ១១៦នាក់ |
| ២៣. | មណ្ឌលគិរី | មាន | ៤៣ | គ្រួសារ | មនុស្ស ៨៥នាក់ |

២៤. ក្រុងកែប មាន ០២ គ្រួសារ មនុស្ស ០៥នាក់

ខ.ជនជាតិ ឬសញ្ជាតិដើម

សរុបរួមមាន ២០ ក្នុងនោះច្រើនជាងគេគឺជនជាតិ :

| | | | |
|---|---|---|---|
| -វៀតណាម | ១៩.១៥៩ គ្រួសារ | មនុស្ស ៦៩.៤១៣នាក់ | ស្មើនឹង ៩៩.១៤ ភាគរយ |
| -ថៃ | ១៣៧ គ្រួសារ | មនុស្ស ១៧៩នាក់ | ស្មើនឹង ០.២៥ ភាគរយ |
| -ឡាវ | ៧៤ គ្រួសារ | មនុស្ស ២៨២នាក់ | ស្មើនឹង ០.៤០ ភាគរយ |
| -ចិន | ៤៦ គ្រួសារ | មនុស្ស ៩៨នាក់ | ស្មើនឹង ០.១៤ ភាគរយ |

ក្រៅពីនោះមាន: បង់ក្លាដេស ភូមា ឥណ្ឌា ០៣ ១ គ្រួសារ អង់គ្លេស បារាំង សិង្ហបុរី ០២ ១ គ្រួសារ និងសាធារណរដ្ឋកូរ៉េ តៃវ៉ាន់ ស្វីស អូស្ត្រាលី ឥណ្ឌូនេស៊ី អាល្លឺម៉ង់ ស្រីលង្កា ម៉ាឡេស៊ី តង់ហ្សានី ហ្វីលីពីន ០១ ១ គ្រួសារ ។

គ.កាលបរិច្ឆេទចូលមកតាំងលំនៅ

ពួកគេបានចូលមកស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមដំណាក់កាលខុសៗគ្នា តាំងពីមុនឆ្នាំ ១៩៧៩ រហូតដល់ឆ្នាំចុងក្រោយនេះ ប៉ុន្តែចំនួនដែលចូលច្រើនជាងគេនោះគឺនៅចន្លោះដើមទសវត្សទី ៨០ :

| | | | | |
|---|---|---|---|---|
| - មុនឆ្នាំ ១៩៧៩ | មាន | ៣៦ គ្រួសារ | មនុស្ស | ៨៤ នាក់ |
| - ១៩៧៩ | មាន | ៥៩៦ គ្រួសារ | មនុស្ស | ២.៣៣៥នាក់ |
| - ១៩៨០ | មាន | ២.១៧៦ គ្រួសារ | មនុស្ស | ៩.១៣៥នាក់ |
| - ១៩៨១ | មាន | ២.៥៩៤ គ្រួសារ | មនុស្ស | ១៣.១៦៣នាក់ |
| - ១៩៨២ | មាន | ៣.៣២២ គ្រួសារ | មនុស្ស | ១៤.១១៥នាក់ |
| - ១៩៨៣ | មាន | ១.៣១៧ គ្រួសារ | មនុស្ស | ៥.២៣៣នាក់ |
| - ១៩៨៤ | មាន | ៦៣៧ គ្រួសារ | មនុស្ស | ២.៣២០ នាក់ |
| - ១៩៨៥ | មាន | ៨០០ គ្រួសារ | មនុស្ស | ២.៧៩៧នាក់ |
| - ១៩៨៦ | មាន | ៤០៤ គ្រួសារ | មនុស្ស | ១.២៨០ នាក់ |
| - ១៩៨៧ | មាន | ២៦០ គ្រួសារ | មនុស្ស | ៨២៨ នាក់ |
| - ១៩៨៨ | មាន | ៣២១ គ្រួសារ | មនុស្ស | ១.០០៧នាក់ |
| - ១៩៨៩ | មាន | ៥០៦ គ្រួសារ | មនុស្ស | ១.៦៧៩នាក់ |
| - ១៩៩០ | មាន | ១.១៥៦ គ្រួសារ | មនុស្ស | ៣.២៩៧នាក់ |
| - ១៩៩១ | មាន | ៤០៥ គ្រួសារ | មនុស្ស | ១.១៧៦នាក់ |
| - ១៩៩២ | មាន | ៦០៧ គ្រួសារ | មនុស្ស | ១.៧៧៩នាក់ |
| - ១៩៩៣ | មាន | ៥៤៦ គ្រួសារ | មនុស្ស | ១.៥០១នាក់ |

- ១៩៩៤ មាន ៣១០ គ្រួសារ មនុស្ស ៨៧៨នាក់
- ១៩៩៥ មាន ៥២៩ គ្រួសារ មនុស្ស ១.៣៥៧នាក់
- ១៩៩៦ មាន ៣២៣ គ្រួសារ មនុស្ស ៧៧៦នាក់
- ១៩៩៧ មាន ៣២៨ គ្រួសារ មនុស្ស ៨៤៣នាក់
- ១៩៩៨ មាន ៤០២ គ្រួសារ មនុស្ស ១.០០៩នាក់
- ១៩៩៩ មាន ៤៤៤ គ្រួសារ មនុស្ស ៩៧៩នាក់
- ២០០០ មាន ៤៦៨ គ្រួសារ មនុស្ស ១.០០៤នាក់
- ២០០១ មាន ៣៣៣ គ្រួសារ មនុស្ស ៧៤២នាក់
- ២០០២ មាន ៣១៧ គ្រួសារ មនុស្ស ៦៩៥នាក់

ឃ.ប្រភេទលំនៅស្ថាន

បើពិនិត្យអំពីស្ថានភាពស្នាក់នៅ ជនបរទេសទាំងនេះភាគច្រើនមានជីវភាពមធ្យមនិងក្រីក្រ:

-៥.១៣៧គ្រួសារ មានមនុស្ស ២០.៣៤១នាក់ ស្មើនិង ២៦.៤៣ភាគរយ មានផ្ទះសំបែងកម្មសិទ្ធផ្ទាល់ខ្លួន

-៤.៤៩២ គ្រួសារ មានមនុស្ស ២០.៣៣៤នាក់ ស្មើនិង ២៣.១១ភាគរយ រស់នៅចល័តលើទឹក

-៨.៥៨៧គ្រួសារ មានមនុស្ស ២៦.៥៩១នាក់ ស្មើនិង ៤៤.១៧ភាគរយ ជួលផ្ទះគេស្នាក់នៅ

-១.២២១គ្រួសារ មានមនុស្ស ២.៧៤៧នាក់ ស្មើនិង ៦.២៨ភាគរយ ស្នាក់នៅដោយសារញាតិមិត្ត

ង.មុខរបរ

ពួកគេប្រកបមុខរបរច្រើនយ៉ាងខុសៗ គ្នា ប៉ុន្តែយើងបានប្រមូលផ្តុំចែកជាប្រភេទ មានចំនួន ១២ ក្នុងនោះច្រើនជាងគេគឺប្រកបមុខរបរជា:

- អ្នកនេសាទ ៥.៣៦៥គ្រួសារ មនុស្ស ២៤.៧៣៣នាក់
- អ្នកលក់ដូរចំរុះ ៥.១១៤គ្រួសារ មនុស្ស ១៧.៣៩៣នាក់
- ជាងគ្រប់ប្រភេទ ៣.៨៦៨គ្រួសារ មនុស្ស ១១.៤៥៨នាក់
- កម្មករ ២.៧២៣គ្រួសារ មនុស្ស ៨.៧៨៨នាក់
- កសិករ ៩២៩គ្រួសារ មនុស្ស ៣.១៧៤នាក់
- មេផ្ទះ ៩១៧គ្រួសារ មនុស្ស ៣.០៧៨នាក់
- ម៉ាស្សា ៣១៥គ្រួសារ មនុស្ស ៧១៥នាក់

ក្រៅពីនោះមានធ្វើការក្នុងអង្គការនានា អង្គការសាសនា គ្រូពេទ្យ និង គ្រូបង្រៀន ចំនួន ១៥០ គ្រួសារ មនុស្ស ៤៤៩នាក់ ៦ ៥៦គ្រួសារ មនុស្ស ២៧២នាក់ទៀត ពុំមានមុខរបរច្បាស់លាស់ ។

ច.ឯកសារសំគាល់

ក្នុងចំណោមជនបរទេសដែលបានធ្វើស្ថិតិ មានជនបរទេសមួយចំនួនមានឯកសារកម្ពុជា ដែលខ្លះចេញមុន

ឆ្នាំ ១៩៧៥ និងខ្លះចេញក្រោយឆ្នាំ ១៩៧៥ មួយចំនួនមានឯកសារចេញអោយដោយអាជ្ញាធរបរទេស និង មួយចំនួនទៀតពុំមានឯកសារអ្វីទាំងអស់ ។

-អ្នកមានឯកសារចេញដោយអាជ្ញាធរខ្មែរមុនឆ្នាំ១៩៧៥មានចំនួន ១.៧៥៩គ្រួសារ មនុស្ស៧.០៥១នាក់ ស្មើនឹង ១០.០៧ ភាគរយ ។

-អ្នកមានឯកសារចេញដោយអាជ្ញាធរខ្មែរក្រោយឆ្នាំ១៩៧៥ មានចំនួន ៣.១៩៥ គ្រួសារ មនុស្ស ១២.៩៧៩នាក់ ស្មើនឹង ១៨.៥៣ ភាគរយ ។

ឯកសារទាំងនោះមានច្រើនប្រភេទ ដូចជា:

+ លិខិតបើកផ្លូវបណ្តោះអាសន្នមុនឆ្នាំ ១៩៧៥

+ លិខិតអាពាហ៍ពិពាហ៍មុនឆ្នាំ ១៩៧៥

+ ប័ណ្ណពលរដ្ឋសង្គមរាស្ត្រនិយម

+ លិខិតបញ្ជាក់ទីលំនៅមុនឆ្នាំ ១៩៧៥

+ សេចក្តីស្រង់សំបុត្រកំណើតមុនឆ្នាំ ១៩៧៥

+ អត្តសញ្ញាណប័ណ្ណជនបរទេសមុនឆ្នាំ ១៩៧៥

+ អត្តសញ្ញាណប័ណ្ណក្រោយ ឆ្នាំ ១៩៧៩

+ សៀវភៅស្នាក់នៅក្រោយ ឆ្នាំ ១៩៧៩

+ ប័ណ្ណស្ថិតិក្នុងបន្ទុកគ្រួសារ

+ បញ្ជីរាយនាមក្នុងបន្ទុកគ្រួសារ

+ ទិដ្ឋាការ និង ទិដ្ឋាការពន្យាពេល

- មានចំនួន ៨៩២គ្រួសារ មនុស្ស ២.៨៦៧នាក់ ស្មើនឹង ៤.០៩ ភាគរយ ដែលកាន់ឯកសារចេញដោយអាជ្ញាធរ ឬ សមាគមបរទេស ដូចជា:

+ អត្តសញ្ញាណប័ណ្ណ

+ លិខិតឆ្លងដែន

+ លិ ខិតសមាគម

+ លិខិតអនិកជន

- មានចំនួន ១៣.៥៥១គ្រួសារ មនុស្ស ៤៧.១១៥នាក់ ស្មើនឹង ៦៧.២៩ ភាគរយ ដែលពុំមានឯកសារអ្វីទាំងអស់ ។

II .ការខាតបង់ចំនួនបាន និង កំពង់ឆ្នាំ :

ដើម្បីបំពេញអោយការដោះស្រាយចំពោះមុខមានលក្ខណៈល្អប្រសើ គណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេស ថ្នាក់ក្រសួង បានជំរុញអោយក្រុមលេខាធិការដ្ឋាន និង គណៈកម្មការថ្នាក់ខេត្ត-ក្រុងដែលទើបនឹង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

## ស្តីពី

# ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារ
# សហកម្មសិទ្ធិដល់ជនបរទេស

# LAW
## ON
# PROVIDING FOREIGNERS WITH OWNERSHIP RIGHTS IN PRIVATE UNITS OF CO-OWNED BUILDINGS

ព្រះរាជក្រមលេខ : នស.រកម/០៥១០/០០៦

កាលបរិច្ឆេទ : ២៤ ឧសភា ២០១០

- ឡូត៍ សំដៅដល់ចំណែកឯកជនដែលភ្ជាប់ទៅនឹងចំណែករួមនៃអគារសហកម្មសិទ្ធិ ។ ឡូត៍នីមួយៗ មានតម្លៃខុសៗគ្នាទៅតាមទំហំតូច ឬ ធំនៃចំណែកឯកជន ហើយការគណនាត្រូវគិតទៅតាមផ្ទៃក្រឡានៃចំណែកឯកជនរបស់សហកម្មសិទ្ធិករនីមួយៗ ។

## ជំពូកទី ២

## គោលការណ៍ទូទៅ

**មាត្រា ៥.-**

ជនបរទេសដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ មានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ និង សិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើចំណែករួម និងមានកាតព្វកិច្ចគោរពតាមបញ្ញត្តិទាំងឡាយនៃច្បាប់នេះ និង បទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន ។

**មាត្រា ៦.-**

ជនបរទេសមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ចាប់ពីជាន់ទី ១ ( មួយ ) ឡើងទៅ ។ ជាន់ផ្ទាល់ដី និង ជាន់ក្រោមដី មិនត្រូវបានអនុញ្ញាតឱ្យជនបរទេសមានសិទ្ធិកម្មសិទ្ធិឡើយ ។

ចំពោះអគារសហកម្មសិទ្ធិមួយកន្លែង សមាមាត្រនិងរបៀបគិតគូរនៃចំណែកឯកជនដែលអាចជាកម្មសិទ្ធិរបស់ជនបរទេសត្រូវកំណត់ដោយអនុក្រឹត្យ ។

ការផ្តល់កម្មសិទ្ធិនេះ គឺផ្តល់តែលើចំណែកឯកជននៃអគារសហកម្មសិទ្ធិតែប៉ុណ្ណោះ ។ ចំពោះចំណែករួមនៃអគារសហកម្មសិទ្ធិ ត្រូវរក្សាទុកសម្រាប់សហកម្មសិទ្ធិករទាំងអស់ នៅក្នុងអគារសហកម្មសិទ្ធិប្រើប្រាស់ជារួម ។

ក្នុងករណីណាក៏ដោយ ក៏ក្បាលដីដែលអគារសហកម្មសិទ្ធិតាំងនៅ មិនអាចជាកម្មវត្ថុនៃកម្មសិទ្ធិរបស់សហកម្មសិទ្ធិករពិសេសបានឡើយ ។

ជនបរទេស មិនត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលស្ថិតនៅក្នុងចំងាយ ៣០ ( សាមសិប ) គីឡូម៉ែត្រ ពីព្រំដែនគោកឡើយ និង

ROYAUME DU CAMBODGE
SECRÉTARIAT DU PALAIS ROYAL
ព្រះបរមរាជវាំង

Ksl

តំបន់មួយចំនួនទៀត ដែលកំណត់ដោយរាជរដ្ឋាភិបាល លើកលែងតែអគារសហកម្មសិទ្ធិស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទីប្រជុំជនសំខាន់ៗ និង តំបន់ផ្សេងទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល ។

ក្នុងករណីដែលអគារសហកម្មសិទ្ធិសាងសង់នៅលើដីជួលពីបុគ្គលទី ៣ ជនបរទេសមានសិទ្ធិជួលអចិន្ត្រៃយ៍លើចំណែកឯកជនដូចពលរដ្ឋខ្មែរដែរ ។

## ជំពូកទី ៣
## លទ្ធកម្មនៃសហកម្មសិទ្ធិពិសេស

**មាត្រា ៧.–**

សហកម្មសិទ្ធិពិសេស ត្រូវបានបង្កើត ផ្ទេរ កែប្រែដោយ :

- ការព្រមព្រៀងរវាងភាគីដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត
- សន្តតិកម្ម ។

**មាត្រា ៨.–**

ការផ្ទេរសហកម្មសិទ្ធិពិសេសដោយការព្រមព្រៀងមិនមានអានុភាពទេ ប្រសិនបើមិនបានចុះបញ្ជីដោយយោងតាមបញ្ញត្តិនៃច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ស្តីពីការចុះបញ្ជី ។

**មាត្រា ៩.–**

នៅពេលដែលសហកម្មសិទ្ធិករលើចំណែកឯកជនដែលជាពលរដ្ឋខ្មែរ បានផ្ទេរកម្មសិទ្ធិលើចំណែកឯកជនរបស់ខ្លួនទៅជនបរទេស សហកម្មសិទ្ធិករពិសេសទទួលបានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន និង ទទួលបានត្រឹមតែសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើចំណែករួមតែប៉ុណ្ណោះ ។ ក្នុងករណីនេះ អតីតសហកម្មសិទ្ធិករលើចំណែកឯកជនជាពលរដ្ឋខ្មែរ ត្រូវបាត់បង់នូវកម្មសិទ្ធិអវិភាគរបស់ខ្លួនលើចំណែករួម ។

# ច្បាប់

ស្តីពី

# លក្ខន្តិកៈមេធាវី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

នស/រកម/០៨៩៥/០៦

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១និងនាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរនិងអំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឲ្យប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីលក្ខន្តិកៈមេធាវី ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្តីពី

# លក្ខន្តិកៈមេធាវី

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

មាត្រា ១.-

វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបំរើវិស័យយុត្តិធម៌ ។

វិជ្ជាជីវៈមេធាវីប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវី ។

មាត្រា ២.-

មេធាវីអាចតំណាងកូនក្តីតាមការយល់ព្រមពីកូនក្តី ឬជួយការពារកូនក្តីនៅគ្រប់ សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធីលើកលែងតែមានបទបញ្ញត្តិច្បាប់ចែងផ្ទុយពីនេះ ជាពិសេសក្នុងរឿង រដ្ឋប្បវេណី ពាណិជ្ជកម្ម រដ្ឋបាល ការងារ សង្គមកិច្ច ។

ក្នុងរឿងព្រហ្មទណ្ឌ មេធាវីជួយការពារជនជាប់ចោទ ហើយមិនអាចតំណាងជន ជាប់ចោទបានឡើយ លើកលែងតែក្នុងករណីអនុវត្តបទបញ្ញត្តិពិសេសនៃច្បាប់ ។ មេធាវីអាចតំណាងអ្នកទទួលខុសត្រូវក្នុងបទរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីបាន ។

មេធាវីអាចជួយការពារកូនក្តីបានដែរនៅចំពោះមុខក្រុមប្រឹក្សាវិន័យ ។

មាត្រា ៣.-

មេធាវីផ្តល់យោបល់ និងតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យគតិយុត្ត ។

មេធាវីអាចត្រូវបានចាត់តាំងដោយតុលាការ ឬចៅក្រមឲ្យបំពេញមុខងារជាអ្នក

ផ្សះផ្សា ឬជាអ្នកសម្រុះសម្រួល ។ មេធាវីនឹងអាចត្រូវបានចាត់តាំងជាអាជ្ញាកណ្តាល បាន លុះត្រាតែមាន ច្បាប់អនុញ្ញាត ។

មាត្រា ៤.-

ក្រៅពីមេធាវីដែលជាសមាជិកនៃគណៈមេធាវី គ្មានជនណាម្នាក់អាចប្រកបមុខរបរយកកម្រៃក្នុងការពិគ្រោះច្បាប់ ឬតាក់តែងលិខិតស្នាមគតិយុត្តបានឡើយ លើកលែងតែការ ពិគ្រោះច្បាប់ ឬការតាក់តែងលិខិតស្នាមនោះជាការងារបន្ទាប់បន្សំនៃមុខរបររបស់ខ្លួន ឬជាមុខងារដែលច្បាប់បានអនុញ្ញាត ។

មាត្រា ៥.-

មេធាវីបរទេសដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីប្រទេសក្រៅ ឬដែលប្រទេសដើមរបស់ខ្លួនទទួលស្គាល់ឲ្យប្រកបវិជ្ជាជីវៈមេធាវី មានសិទ្ធិចូលរួមប្រកបវិជ្ជាជីវៈជាមួយមេធាវីខ្មែរហើយអមមេធាវីខ្មែរនៅចំពោះមុខតុលាការ ឬស្ថាប័នដទៃទៀតនៃព្រះរាជាណាចក្រ-កម្ពុជា ។ មេធាវីទាំងនោះពុំអាចតំណាងកូនក្តីបានឡើយ ។

មាត្រា ៦.-

មេធាវីបរទេសអាចប្រកបវិជ្ជាជីវៈនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាបានលុះត្រាតែមានការយល់ព្រមពីក្រុមប្រឹក្សាគណៈមេធាវីខ្មែរ ផ្អែកលើលក្ខណៈសម្បត្តិគ្រប់គ្រាន់ របស់មេធាវីនោះ ហើយលុះត្រាតែប្រទេសដើមរបស់មេធាវីបរទេសនោះ ផ្តល់លទ្ធភាពដូចគ្នាដល់មេធាវីខ្មែរផងដែរ ។ ការយល់ព្រមអាចត្រូវដកហូតវិញបាន បើមានការប្រព្រឹត្តិខុសក្នុងការ ប្រកបវិជ្ជាជីវៈលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីសម្រេចមិនអនុញ្ញាត ឬដកហូតការអនុញ្ញាតរបស់ក្រុមប្រឹក្សាគណៈមេធាវី មិនឲ្យប្រកបវិជ្ជាជីវៈ ត្រូវជូនដំណឹងក្នុងរយៈពេល ១៥ ថ្ងៃ ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងទៅសាមីខ្លួន ។ សេចក្តីសម្រេចនេះអាចប្តឹងឧទ្ធរណ៍បាន ក្នុងរយៈពេល ២ ខែ ក្រោយពីបានទទួលដំណឹង ។

មាត្រា ៧.-

មេធាវីបរទេសដែលត្រូវបានអនុញ្ញាតឲ្យប្រកបវិជ្ជាជីវៈនេះ ពុំអាចធ្វើសកម្មភាព ទាក់ទាញកូនក្តី ឬផ្សព្វផ្សាយពាណិជ្ជកម្មបានឡើយ ។

# ជំពូកទី ២
# ការរៀបចំវិជ្ជាជីវៈមេធាវី
## ផ្នែកទី ១
## គណៈមេធាវី

មាត្រា ៨.-

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការប្រមូលផ្តុំមេធាវីទាំងអស់ដែលតាំងការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ មេធាវីម្នាក់ៗត្រូវជាសមាជិកពេញសិទ្ធិនៃគណៈមេធាវី ក្រោយពីចុះឈ្មោះក្នុងបញ្ជី គណៈមេធាវី ។

មាត្រា ៩.-

គណៈមេធាវីត្រូវបានដឹកនាំដោយប្រធានមួយរូប និងគ្រប់គ្រងដោយក្រុមប្រឹក្សាគណៈមេធាវី ។ ប្រធានគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងសំរាប់អាណត្តិ ២ ឆ្នាំ ។ អាណត្តិនេះអាចត្រូវបានបន្តតែមួយអាណត្តិទៀតដោយវិធីបោះឆ្នោត ។

មាត្រា ១០.-

សមាជិកនៃក្រុមប្រឹក្សាគណៈមេធាវីមាន :

- ចំនួន ៥ នាក់ ក្នុងករណីគណៈមេធាវី មានសមាជិកមិនលើសពី ៣០ នាក់
- ចំនួន ៩ នាក់ បើមានសមាជិកពី ៣១ នាក់ ទៅ ៥០ នាក់
- ចំនួន ១៣ នាក់បើមានសមាជិកពី ៥១ នាក់ទៅ ២០០ នាក់
- ចំនួន ១៩ នាក់ បើមាន សមាជិកពី ២០១ នាក់ ទៅដល់ ៥០០ នាក់
- ចំនួន ២៧ នាក់ បើមានសមាជិកពី ៥០១ នាក់ទៅ ១.០០០ នាក់
- ចំនួន ៣៣ នាក់ បើមានសមាជិកលើសពី ១០០១ នាក់ ។

មាត្រា ១១.-

សមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងសំរាប់អាណត្តិ ៣ ឆ្នាំ ។ អាណត្តិនេះអាចបន្តម្តងទៀតបាន ប៉ុន្តែមិនអាចបន្តភ្ជាប់ពីចប់អាណត្តក្លាមនោះទេ ។ ផុតរយៈពេល ៣ ឆ្នាំ ក្រោយពីចប់អាណត្តិ ទើបអតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាចឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងជាថ្មីបាន ។ ប្រធានគណៈមេធាវី អាចត្រូវបានបោះឆ្នោតជ្រើសតាំងឲ្យធ្វើជាសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវីបានក្រោយបានចប់អាណត្តិរបស់ខ្លួន ដោយមិន បាច់រង់ចាំផុតរយៈពេល ៣ ឆ្នាំទេ ។

មាត្រា ១២.-

បើប្រធានគណៈមេធាវី ឬសមាជិកណាម្នាក់នៃក្រុមប្រឹក្សាគណៈមេធាវីទទួលមរណភាពឬឈប់ពីមុខងារក្នុងអាណត្តិរបស់ខ្លួន នោះត្រូវរៀបចំការបោះឆ្នោតជ្រើសតាំងអ្នកជំនួស ដើម្បីបញ្ចប់អាណត្តិនោះ ។

មាត្រា ១៣.-

គណៈមេធាវីមិនស្ថិតនៅក្រោមគណៈបក្សនយោបាយណាមួយ ឬអង្គការសាសនាណាមួយ ឬអង្គការនានាផ្សេងទៀតឡើយ ។

ការសម្តែងមនោគមវិជ្ជា សាសនា ឬនយោបាយ ត្រូវហាមឃាត់ ។

គណៈមេធាវីមានថវិកាស្វយ័ត ប៉ុន្តែមិនអាចធ្វើសកម្មភាពយកផលចំណេញបានឡើយ ។

## ផ្នែកទី ២

## ការបោះឆ្នោត

មាត្រា ១៤.-

ប្រធានគណៈមេធាវី និងសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងដាច់ដោយឡែកពីគ្នា ក្នុងមហាសន្និបាតនៃគណៈមេធាវី ។ អ្នកដែលមានសិទ្ធិបោះឆ្នោត គឺមេធាវីទាំងអស់ដែលបានចុះឈ្មោះក្នុងបញ្ជីនៃ

គណៈមេធាវី ហើយដែលឥតបានបាត់បង់សិទ្ធិបោះឆ្នោតដោយទណ្ឌកម្ម វិន័យណាមួយឡើយ ។

មាត្រា ១៥.-

អ្នកដែលអាចឈរឈ្មោះឲ្យគេបោះឆ្នោត ជ្រើសតាំងជាប្រធានគណៈមេធាវីបានគឺមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីបានរយៈពេល ៣ ឆ្នាំ យ៉ាងតិច ហើយដែលឥត បានបាត់បង់សិទ្ធិបោះឆ្នោតដោយទណ្ឌកម្មវិន័យណាមួយឡើយ ។

អ្នកដែលអាចឈរឈ្មោះបោះឆ្នោត ជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាគណៈមេធាវីបាន គឺមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីបានរយៈពេល ២ ឆ្នាំយ៉ាងតិចហើយដែលឥតបានបាត់បង់សិទ្ធិបោះឆ្នោតទាំងនោះ ។

មាត្រា ១៦.-

ការបោះឆ្នោតត្រូវបានរៀបចំឡើងដោយមហាសន្និបាតនៃគណៈមេធាវី ២ ឆ្នាំម្តង ចំពោះប្រធានគណៈមេធាវី និង ៣ ឆ្នាំម្តង ចំពោះសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ។

ការបោះឆ្នោតនេះ ត្រូវប្រព្រឹត្តជាសម្ងាត់ និងជាឯកនាមហើយអាចធ្វើជាពីរលើកបាន ។ ការបោះឆ្នោតលើកទី១ប្រព្រឹត្តទៅដោយយកតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិក គណៈមេធាវីទាំងមូល និងលើកទី ២ ដោយយកតាមសម្លេងភាគច្រើននៃសមាជិកវត្តមាន ។ ក្នុងករណីមានសម្លេងស្មើគ្នា មេធាវីដែលមានវ័យចាស់ជាងគេ ត្រូវបានជ្រើសតាំង ។

មាត្រា ១៧.-

បែបបទនៃការបោះឆ្នោត ការកោះអញ្ជើញមករួមប្រជុំ និងកូរ៉ុមត្រូវបានកំណត់ ដោយបទបញ្ជាផ្ទៃក្នុង ។ មេធាវីដែលមានសិទ្ធិបោះឆ្នោត ឬ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចប្តឹងតវ៉ាអំពីការបោះឆ្នោតនេះ ទៅសាលាឧទ្ធរណ៍បាន ។

ពាក្យបណ្តឹងនេះ ត្រូវធ្វើឡើងដោយមេធាវីក្នុងរយៈពេល ១៥ ថ្ងៃក្រោយការបោះឆ្នោត ឬដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងរយៈពេល ១៥ ថ្ងៃ

គិតពីថ្ងៃទទួល ដំណឹងស្តីពីលទ្ធផលនៃការបោះឆ្នោតនោះ ។

## ផ្នែកទី ៣
## មហាសន្និបាត

មាត្រា ១៨.-

មហាសន្និបាតសាមញ្ញនៃគណៈមេធាវីប្រព្រឹត្តទៅមួយឆ្នាំម្តង ដែលផ្តើមធ្វើឡើងដោយប្រធានគណៈមេធាវីតាមរបៀបវារៈដែល ត្រូវបានសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី ។

មហាសន្និបាតអាចធ្វើសំណូមពរ ឬញត្តិទៅក្រុមប្រឹក្សាគណៈមេធាវី ដែលត្រូវដោះស្រាយក្នុងរយៈពេល ៣ ខែ ។

មហាសន្និបាតវិសាមញ្ញអាចប្រជុំបាន បើមានមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជី ចំនួន ៣០% បានស្នើសុំដោយមានភ្ជាប់របៀបវារៈជាមួយផង យ៉ាងតិច ១៥ ថ្ងៃ មុនថ្ងៃប្រជុំ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃមហាសន្និបាតគណៈមេធាវី ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី ។

## ផ្នែកទី ៤
## ក្រុមប្រឹក្សាគណៈមេធាវី

មាត្រា ១៩.-

ក្រុមប្រឹក្សាគណៈមេធាវីពិនិត្យដោះស្រាយគ្រប់បញ្ហា ដែលពាក់ព័ន្ធទៅការអនុវត្តន៍វិជ្ជាជីវៈមេធាវី ។ ក្រុមប្រឹក្សាគណៈមេធាវីធានាការបំពេញភារកិច្ច និងការពារសិទ្ធិរបស់មេធាវី ។ ក្រុមប្រឹក្សាគណៈមេធាវីមានភារកិច្ចជាអាទិ៍ ដូចតទៅ ៖

- ធ្វើបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌
- សំរេចឲ្យចុះឈ្មោះធ្វើកម្មសិក្សា និងចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី

- សំរេចលើការស្នើសុំអនុញ្ញាតទាំងឡាយដែលធ្វើឡើងដោយមេធាវី
- ពិនិត្យកិច្ចព្រមព្រៀងនិងឯកសារទាំងឡាយដែលមេធាវីមានកាតព្វកិច្ចត្រូវដាក់ឲ្យពិនិត្យហើយបញ្ចេញមតិណែនាំលើកិច្ចព្រមព្រៀង និងឯកសារ ទាំងនោះ
- ត្រួតពិនិត្យការកាន់កាប់ទៀងទាត់នៃបញ្ជីគណៈនេយ្យរបស់មេធាវី
- ធានាការគោរពវិន័យ និងការដាក់វិន័យ
- ធានារ៉ាប់រងការរៀបចំ និងការគ្រប់គ្រងសេវាទូទៅរបស់គណៈមេធាវី
- គ្រប់គ្រងទ្រព្យសម្បត្តិ និងថវិការរបស់គណៈមេធាវី កំណត់ចំនួនទឹកប្រាក់ភាគទានរបស់មេធាវីម្នាក់ៗ និងបង់ប្រាក់ធានារួមសំរាប់វិជ្ជាជីវៈមេធាវី
- គ្រប់គ្រងបេឡានៃមូលនិធិរបស់គណៈមេធាវី
- បញ្ចេញមតិលើបញ្ហាទាំងឡាយដែលទាក់ទងវិស័យយុត្តិធម៌ និងសិទ្ធិរបស់មេធាវី ក្នុងវិស័យការពារ ជាអាទិ៍នៅពេលដែលមានការអញ្ជើញពីអាជ្ញាធរសាធារណៈ ។

មាត្រា ២០.-

ក្រុមប្រឹក្សាគណៈមេធាវីអាចរួមប្រជុំបាន លុះត្រាតែមានសមាជិករបស់ខ្លួនចូលរួម លើសពីពាក់កណ្ដាល ។ ក្រុមប្រឹក្សាគណៈមេធាវីសំរេចសេចក្ដីតាមមតិភាគច្រើន ។

មាត្រា ២១.-

សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីដែលមានលក្ខណៈជាបទបញ្ជាត្រូវជូនដំណឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយ មានចុះសេចក្ដីថាបានទទួល ។ ចំពោះសេចក្ដីសំរេចដាក់វិន័យក៏ដូចជាសេចក្ដីសំរេចលើការចុះឈ្មោះ ឬការសុំឲ្យនៅក្រៅបញ្ជីរបស់មេធាវី ក៏ត្រូវធ្វើដូច្នេះដែរ ។ សេចក្ដីសំរេចចែងក្នុងវាក្យខ័ណ្ឌខាងលើត្រូវផ្ដល់ជាពត៌មានដល់សមាជិកនៃគណៈមេធាវី តាមមធ្យោបាយសមស្រប ។

មាត្រា ២២.-

រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីលើមេធាវីណាម្នាក់ ត្រូវជូនដំណឹងទៅមេធាវីនោះតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួល ។

មាត្រា ២៣.-

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ដែលមិនមែនជាមុខនាទីរបស់ខ្លួនឬផ្ទុយនឹងបទបញ្ញត្តិច្បាប់ជាធរមានឬបទបញ្ជាអាចត្រូវបដិសេធចោល ដោយសាលាឧទ្ធរណ៍ក្រោយពីមានការប្តឹងពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

មាត្រា ២៤.-

មេធាវីអាចប្តឹងអំពីសេចក្តីសំរេចណាមួយរបស់ក្រុមប្រឹក្សាគណៈមេធាវីដែលធ្វើឲ្យ ខាតប្រយោជន៍ដល់វិជ្ជាជីវៈរបស់ខ្លួនបាន ។ បើសេចក្តីសំរេចឥតត្រូវបានឲ្យដំណឹងដល់មេធាវី មេធាវីនោះត្រូវសុំឲ្យក្រុមប្រឹក្សាគណៈមេធាវីពិនិត្យសេចក្តីសំរេចនោះសាជាថ្មីម្តងទៀតមុននឹងប្តឹង ។ ក្រុមប្រឹក្សាគណៈមេធាវីត្រូវសំរេចលើសេចក្តីស្នើសុំនោះក្នុងរយៈពេល ២ ខែ ក្រោយពីបានអញ្ជើញមេធាវីនោះឲ្យបញ្ចេញយោបល់របស់ខ្លួន ។ សេចក្តីសំរេចថ្មីត្រូវបានជូនដំណឹងទៅសាមីខ្លួន ។ បើគ្មានការសំរេចសាជាថ្មីក្នុងរយៈពេលដូចកំណត់ខាងលើនេះទេ ត្រូវចាត់ទុកសេចក្តីសំរេចមុននោះជាអសាបង់ ។

មាត្រា ២៥.-

ពាក្យបណ្តឹងទាំងឡាយមិនសុខចិត្តនឹងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍ ។ គេអាចដាក់ពាក្យបណ្តឹងទៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ឬតាមលិខិតអនុសិដ្ឋមានចុះសេចក្តីថាបានទទួល ។ រយៈពេលប្តឹងឧទ្ធរណ៍គឺ ២ ខែ ចាប់ពីថ្ងៃទទួលដំណឹង ។

មាត្រា ២៦.-

ក្រុមប្រឹក្សាគណៈមេធាវីត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ

និងផ្សព្វផ្សាយជាសាធារណៈជារៀងរាល់ឆ្នាំ នូវរបាយការណ៍សំអិតស្ដីពីសកម្មភាពការងាររបស់គណៈមេធាវី ។ ក្រុមប្រឹក្សាគណៈមេធាវីត្រូវបង្ហាញស្ថានភាពហិរញ្ញវត្ថុនិងផ្ដល់ព័ត៌មានផ្សេងៗជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បើមានសំណូមពរពីក្រសួងនេះ ។

## ផ្នែកទី ៥
## ប្រធានគណៈមេធាវី

មាត្រា ២៧.-

ប្រធានគណៈមេធាវីមានតួនាទី ៖

- ជាអ្នកដឹកនាំគណៈមេធាវី
- ជាអធិបតីនៃមហាសន្និបាតគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី
- ជាអ្នកធានាផលប្រយោជន៍វិជ្ជាជីវៈ និងផលប្រយោជន៍របស់សមាជិកទាំងអស់
- ជាអ្នកផ្សះផ្សា ហើយបើមានការចាំបាច់និងតាមសំណើរបស់គូក្ដី ធ្វើអាជ្ញាកណ្ដាល ក្នុងវិវាទដែលកើតឡើងរវាងមេធាវីនិងមេធាវី រវាងមេធាវីនិងអតិថិជន
- ជាតំណាងវិជ្ជាជីវៈមេធាវីចំពោះមុខតតិយជននិងអាជ្ញាធរសាធារណៈ
- ជាតំណាងគណៈមេធាវីក្នុងរឿងក្ដីដែលទាក់ទងគណៈមេធាវីក្រោយពីមានការអនុញ្ញាតពីក្រុមប្រឹក្សាគណៈមេធាវី ។

ក្នុងការបោះឆ្នោត សំឡេងរបស់ប្រធានគណៈមេធាវីឥតមានឧត្ដមានុភាពទេ ។

មាត្រា ២៨.-

ប្រធានគណៈមេធាវីអាចផ្ទេរអំណាចណាមួយ ឬអំណាចទាំងអស់ទៅឲ្យសមាជិកណាម្នាក់ ឬច្រើននាក់នៃក្រុមប្រឹក្សាគណៈមេធាវីបាន ក្នុងរយៈពេលមានកំណត់ ។

ក្នុងករណីមានធុរៈ ប្រធានគណៈមេធាវីត្រូវជំនួសដោយសមាជិកនៃ

ក្រុមប្រឹក្សា គណៈមេធាវី ដែលមានវ័យចាស់ជាងគេ ។

## ជំពូកទី ៦
## មូលនិធិនៃគណៈមេធាវី

មាត្រា ២៩.-

មូលនិធិនៃគណៈមេធាវីបានមកពីការបង់ភាគទាននៃសមាជិកទាំងអស់ និង វិភាគទានផ្សេងៗ ។ នៅក្នុងមូលនិធិនេះត្រូវបង្កើតឲ្យមានបេឡាពិសេសមួយ សំរាប់ផ្តល់ប្រាក់កំរៃ ដល់មេធាវីដែលការពារជនក្រីក្រ ។

បេឡាពិសេសនេះអាចទទួលអំណោយ ឬប្រាក់ជំនួយដែលឯកជន អង្គការ អន្តរជាតិ ឬរដ្ឋាភិបាលនៃប្រទេសផ្សេងៗ ផ្តល់មកឲ្យដើម្បីការពារជនក្រីក្រ ។

មេធាវីទាំងអស់មានកាតព្វកិច្ចជួយការពារជនក្រីក្រ តាមបែបបទនៃបទបញ្ជាផ្ទៃក្នុង ហើយឲ្យដូចជាជួយការពារអតិថិជនរបស់ខ្លួន ។

មាត្រា ៣០.-

ដែលហៅថាជនក្រីក្រ គឺជនដែលគ្មានទ្រព្យសម្បត្តិ គ្មានប្រាក់ចំណូល ឬដែលមានប្រាក់ចំណូលមិនគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ជីវភាព ។

ការកំណត់អំពីភាពក្រីក្រ ត្រូវធ្វើឡើងដោយប្រធានតុលាការ និងក្រឡាបញ្ជីនាយកក្រោយពីបានធ្វើការស៊ើបអង្កេតដល់មូលដ្ឋាន ។

# ជំពូកទី ៣
# ការទទួលឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី បញ្ជីគណៈមេធាវី

## ផ្នែកទី ១
## លក្ខខណ្ឌ

មាត្រា ៣១.-

ជនដែលអាចចូលប្រកបវិជ្ជាជីវៈជាមេធាវីបាន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមនេះ ៖

១- ត្រូវមានសញ្ជាតិជាខ្មែរ

២- ត្រូវមានបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល ។

៣- ត្រូវមានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ។ វិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវីនេះត្រូវចេញឲ្យដោយមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

៤- មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬ ផ្តន្ទាទោសជាបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ ។ មិនត្រូវមានធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

មាត្រា ៣២.-

មិនចាំបាច់មានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់មានបរិញ្ញាប័ត្រច្បាប់ ៖

- ចៅក្រម ដែលបានបំរើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ៥ ឆ្នាំ និងអតីតចៅក្រម ដែលមានសញ្ញាប័ត្រមធ្យមសិក្សាច្បាប់ហើយដែលបានបំរើក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ២ ឆ្នាំ ។

មិនចាំបាច់មានវិញ្ញាបនប័ត្រខាងវិជ្ជាជីវៈមេធាវី ៖

- អ្នកមានបរិញ្ញាប័ត្រច្បាប់ ហើយដែលបានបំពេញការងារក្នុងវិស័យច្បាប់ ឬតុលាការលើសពី ២ ឆ្នាំ
- មេធាវីដែលមានសញ្ជាតិដើមជាខ្មែរ ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេស ក្រៅ
- អ្នកមានសញ្ញាប័ត្របណ្ឌិតច្បាប់ ។

## ផ្នែកទី ២
## ការឧទ្ទួលឱ្យប្រកបវិជ្ជាជីវៈមេធាវី

មាត្រា ៣៣.-

ការយល់ព្រមឲ្យប្រកបវិជ្ជាជីវៈមេធាវីត្រូវសំរេចដោយក្រុមប្រឹក្សាគណៈមេធាវី ក្រោយពីបានត្រួតពិនិត្យលើការបំពេញល័ក្ខខ័ណ្ឌសព្វគ្រប់ដែលមានកំណត់ក្នុងច្បាប់នេះនិងក្រោយពីមានយោបល់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

សេចក្តីសំរេចត្រូវឲ្យដំណឹងដល់សាមីខ្លួន និងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

ក្រុមប្រឹក្សាគណៈមេធាវីមិនអាចសំរេចមិនយល់ព្រមដោយគ្មានការកោះអញ្ជើញសាមីខ្លួនឲ្យចូលមកបញ្ចេញយោបល់ជាមុនយ៉ាងតិច១០ថ្ងៃបានឡើយ ។ ការកោះអញ្ជើញនេះ ត្រូវធ្វើតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានសេចក្តីបញ្ជាក់ថាបានទទួល ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី អាចត្រូវបានប្តឹងតវ៉ាតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងមាត្រា ២៥ ខាងលើ ។

មាត្រា ៣៤.-

មេធាវីដែលត្រូវបានទទួលឲ្យប្រកបវិជ្ជាជីវៈ ត្រូវធ្វើសច្ចាប្រណិធានជាមុននៅចំពោះមុខសាលាឧទ្ធរណ៍ ដោយមានវត្តមានប្រធានគណៈមេធាវី ហើយដែលមានសេចក្តីដូច តទៅ ៖

"ខ្ញុំសូមសច្ចាប្រណិធានថា នឹងអនុវត្តវិជ្ជាជីវៈរបស់ខ្ញុំ ដោយសេចក្តីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយសេចក្តីទៀងត្រង់ ដោយមនុស្សធម៌

ដោយស្មារតីឯករាជ្យ និងដោយគោរពវិជ្ជាជីវៈ និងច្បាប់ទាំងឡាយនៃ
ព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី ៣
## កម្មសិក្សា

មាត្រា ៣៥.-

មេធាវីដែលទើបបានចុះឈ្មោះ ត្រូវធ្វើកម្មសិក្សារយៈពេល ១ ឆ្នាំ តាមបែបបទ ដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវី លើកលែងតែមេធាវីណាដែលមានការអនុញ្ញាតឲ្យរួចផុតពីកម្មសិក្សា ។ បែបបទនៃកម្មសិក្សាមានជាអាទិ៍ដូចតទៅ ៖

- ត្រូវទទួលការបំពាក់បំប៉នជាបន្ថែម ដែលរៀបចំឡើងដោយគណៈមេធាវី
- ត្រូវចូលរួមបំពេញការងារឲ្យពិតប្រាកដជាសហការីក្នុងការិយាល័យមេធាវីណាមួយ ។

មាត្រា ៣៦.-

កម្មសិក្សាប្រព្រឹត្តទៅក្រោមការត្រួតពិនិត្យរបស់មេធាវីម្នាក់ដែលក្រុមប្រឹក្សាគណៈមេធាវីចាត់តាំងជាប្រធានទទួលខុសត្រូវលើកម្មសិក្សានោះ ។

មាត្រា ៣៧.-

ក្រោយបញ្ចប់កម្មសិក្សា ក្រុមប្រឹក្សាគណៈមេធាវីសំរេចពីការចុះឈ្មោះក្នុងបញ្ជី គណៈមេធាវីដោយផ្អែកលើរបាយការណ៍របស់ប្រធានទទួលខុសត្រូវលើកម្មសិក្សា ។ ក្រុមប្រឹក្សាគណៈមេធាវី អាចសំរេចឲ្យធ្វើកម្មសិក្សាបន្តទៀតបានតែមិនឲ្យលើសពី ១ ឆ្នាំ ឡើយ ចំពោះកម្មសិក្សាការីណាដែលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ ។ ការសំរេចមិនចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាត់ទុកជាការលុបឈ្មោះមេធាវីនោះចោល ។ ការសំរេចមិនចុះឈ្មោះក្នុងបញ្ជី ឬការ បន្តកម្មសិក្សា ពុំអាចធ្វើទៅបានឡើយបើគ្មានការកោះអញ្ជើញសាមីខ្លួនឲ្យមកបញ្ចេញយោបល់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៣៣

សេចក្ដីសំរេចនេះអាចនឹងប្ដឹងតវ៉ាបានតាមលក្ខខ័ណ្ឌ និងនីតិវិធីដែលមានចែង ក្នុងមាត្រា ២៤ និង ២៥ ។

មាត្រា ៣៨.-

រៀលរាល់ឆ្នាំ ក្រុមប្រឹក្សាគណៈមេធាវីបញ្ចប់បញ្ជីគណៈមេធាវី និងបញ្ជីមេធាវីកម្មសិក្សា ហើយផ្ញើបញ្ជីនោះជូនអគ្គព្រះរាជអាជ្ញា និងសាលាជម្រះក្ដីទាំងអស់ ។

បញ្ជីនោះមានដូចតទៅ ៖

- ឈ្មោះមេធាវីដែលបានចុះក្នុងបញ្ជីគណៈមេធាវី និងអាស័យដ្ឋានរបស់មេធាវីនោះ
- ឈ្មោះ និងអាស័យដ្ឋានរបស់មេធាវីកម្មសិក្សា ។

មាត្រា ៣៩.-

លេខរៀងនៃការចុះឈ្មោះរបស់មេធាវី ត្រូវកំណត់តាមកាលបរិច្ឆេទដែលបានធ្វើសច្ចាប្រណិធានហើយត្រូវបានកំណត់ដោយ ក្រុមប្រឹក្សាគណៈមេធាវីដែលបានសំរេចឲ្យចុះឈ្មោះ ។

## ផ្នែកទី ៤
## ការដាក់នៅក្រៅបញ្ជី

មាត្រា ៤០.-

ដោយមានមូលហេតុសមស្រប មេធាវីអាចសុំនៅក្រៅបញ្ជីនៃគណៈមេធាវីបាន សំរាប់រយៈពេលពីរឆ្នាំម្ដងៗជាអតិបរមា ។

មាត្រា ៤១.-

ក្រុមប្រឹក្សាគណៈមេធាវីអាចសំរេចដាក់មេធាវីណាម្នាក់នៅក្រៅបញ្ជី បើមេធាវីនោះ ស្ថិតនៅក្នុងស្ថានភាពវិសមិតភាព ឬបើមេធាវីនោះពុំអាចប្រកបវិជ្ជាជីវៈ របស់ខ្លួនបាន ។

ក្នុងករណីមានបណ្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចខាងលើនោះ ត្រូវអនុវត្តនីតិវិធី ដែលមានចែងក្នុងមាត្រា ៣៣ ។

មាត្រា ៤២.-

មេធាវីដែលត្រូវបានដាក់ឲ្យនៅក្រៅបញ្ជី ពុំអាចប្រកបវិជ្ជាជីវៈរបស់ខ្លួន ហើយក៏ពុំអាចប្រើប្រាស់ឋានៈជាមេធាវីបានឡើយ និងត្រូវបានរួចពីកាតព្វកិច្ចទាំងឡាយដែលទាក់ទងទៅ នឹងវិជ្ជាជីវៈនេះ ក៏ប៉ុន្តែត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមេធាវី ។

ការដាក់ឲ្យនៅក្រៅបញ្ជីពុំអាចរារាំងការចោទប្រកាន់ខាងវិន័យឡើយ ។

## ផ្នែកទី ៥
## ឋានៈជាមេធាវីកិត្តិយស

មាត្រា ៤៣.-

ក្រុមប្រឹក្សាគណៈមេធាវីអាចផ្តល់ងារជាមេធាវីកិត្តិយសជូនមេធាវីដែលឈប់ប្រកបវិជ្ជាជីវៈមេធាវី ក្រោយពីបានប្រកបវិជ្ជាជីវៈរយៈពេល ១៥ ឆ្នាំយ៉ាងតិច ។

មាត្រា ៤៤.-

មេធាវីកិត្តិយសនៅតែជាសមាជិកនៃគណៈមេធាវីដដែល ហើយអាចចូលរួមក្នុងមហាសន្និបាតមេធាវី មានសិទ្ធិផ្តល់យោបល់ ព្រមទាំងចូលរួមក្នុងពិធីផ្សេងៗ ។

ដោយឡែក មេធាវីកិត្តិយសអាចផ្តល់យោបល់ដល់អតិថិជន ហើយអាចត្រូវបានចាត់តាំងជាអ្នកផ្សះផ្សា ជាអ្នកសម្រុះសម្រួល ឬជាអ្នកអាជ្ញាកណ្តាល ។

មាត្រា ៤៥.-

ក្រុមប្រឹក្សាគណៈមេធាវី អាចដកហូតងារជាមេធាវីកិត្តិយសនេះបាន បើមានហេតុដែលធ្វើឲ្យប៉ះពាល់ដល់កិត្តិយស ឬសេចក្តីថ្លៃថ្នូររបស់មេធាវីនោះ ។ ក្នុងករណីនេះត្រូវអនុវត្តនីតិ វិធី ដែលមានចែងក្នុងមាត្រា ៣៣ ។

# ជំពូកទី ៤
## បែបបទនៃការប្រកបវិជ្ជាជីវៈ

### ផ្នែកទី ១
### ការប្រកបវិជ្ជាជីវៈមេធាវីជាឯកត្តជន ឬជាសមូហភាព

**មាត្រា ៤៦.-**

មេធាវីអាចប្រកបវិជ្ជាជីវៈជាឯកត្តជនបាន ឬនៅក្នុងក្របខ័ណ្ឌជាក្រុម ឬក្រុមហ៊ុនមេធាវីណាមួយដែលបង្កើតឡើងត្រឹមត្រូវតាមច្បាប់ ។

ក្រុមហ៊ុននេះត្រូវមានលក្ខណៈជាក្រុមហ៊ុនស៊ីវិល ហើយមានសុទ្ធតែមេធាវីជាសមាជិក ។ មេធាវីកិត្តិយសអាចនៅជាសមាជិកនៃក្រុមហ៊ុនដើមរបស់ខ្លួនបាន ។

សិទ្ធិវន្ត គឺអ្នកដែលមានសិទ្ធិទទួលមរតកពីមេធាវី ដែលបានទទួលមរណភាពអាចបន្តកាន់កាប់ភាគហ៊ុននោះបានក្នុងរយៈពេល ៣ឆ្នាំជាអតិបរមា ។ ផុតរយៈពេល ៣ ឆ្នាំ នោះ ត្រូវលក់ភាគហ៊ុននោះទៅឲ្យមេធាវីណាម្នាក់ឬទៅឲ្យក្រុមហ៊ុននោះវិញ ។

**មាត្រា ៤៧.-**

ក្រុម និងក្រុមហ៊ុនមេធាវីទាំងឡាយ ត្រូវបានគ្រប់គ្រងដោយច្បាប់គ្រប់គ្រងក្រុមនិងក្រុមហ៊ុន លើកលែងតែបទបញ្ញត្តិនៃបទបញ្ញានោះប៉ះពាល់ដល់គោលការណ៍គ្រប់គ្រងវិជ្ជាជីវៈមេធាវី ។

**មាត្រា ៤៨.-**

មេធាវីទាំងឡាយត្រូវបានអនុញ្ញាតឲ្យចុះកិច្ចព្រមព្រៀងជាមួយសមាជិកនៃវិជ្ជាជីវៈសេរីដទៃទៀត ដើម្បីប្រមូលផ្តុំមធ្យោបាយជាមួយគ្នា ។ ការធ្វើកិច្ចព្រមព្រៀងនេះមិនត្រូវឲ្យប៉ះពាល់ដល់វិធាននៃវិជ្ជាជីវៈមេធាវី ជាអាទិ៍ប៉ះពាល់ដល់ការគោរពការសម្ងាត់នៃវិជ្ជាជីវៈនេះ ។

មាត្រា ៤៩.-

រាល់កិច្ចព្រមព្រៀងដែលមេធាវីខ្មែរណាម្នាក់បានចុះជាមួយមេធាវីខ្មែរណាម្នាក់ទៀត ឬជាមួយមេធាវីបរទេស ឬក៏ជាមួយសមាជិកនៃវិជ្ជាជីវៈសេរីណាមួយ ត្រូវតែដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងយល់ព្រម ហើយជូនពត៌មានដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ ក្នុងករណីនេះត្រូវអនុវត្តនីតិវិធីដែលមានចែងក្នុងមាត្រា ៣៣ ។

## ផ្នែកទី ២
## កិច្ចសហការ

មាត្រា ៥០.-

មេធាវីអាចប្រកបវិជ្ជាជីវៈក្នុងលក្ខណៈជាសហការីរបស់មេធាវីម្នាក់ទៀត ។

មាត្រា ៥១.-

មេធាវីជាសហការីបំពេញកិច្ចការផ្សេងៗក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់សហភាគា ។ គេពុំអាចបំពេញកិច្ចការបានទេ បើគ្មានការយល់ព្រមពីសហភាគា ប៉ុន្តែគេមានសិទ្ធិពេញទីក្នុងការជ្រើសរើសមធ្យោបាយធ្វើការងាររបស់គេ។គេអាចសុំមិនទទួលបំពេញ បេសកកម្មណាមួយ ដែលគេយល់ថាផ្ទុយនឹងសម្បជញ្ញៈរបស់គេ ។

មាត្រា ៥២.-

ក្នុងករណីណាក៏ដោយ កិច្ចសហការមិនអាចរាំងមិនឲ្យសហការីមេធាវីបង្កើតការិយាល័យផ្ទាល់របស់គេ ឬរាំងមិនឲ្យគោរពកាតព្វកិច្ចនិងវិធាននៃវិជ្ជាជីវៈមេធាវីបានឡើយ ។ គេធ្វើការក្នុងនាមគេផ្ទាល់ កាលណាគេការពារកូនក្តីគេផ្ទាល់ខ្លួន ។

កិច្ចសន្យានៃកិច្ចសហការត្រូវរៀបចំឡើង ហើយផ្ញើជូនក្រុមប្រឹក្សាគណៈមេធាវី ។

## ជំពូកទី ៥
## វិធានវិជ្ជាជីវៈ បទវិន័យ

### ផ្នែកទី ១
### វិសមិតភាព

មាត្រា ៥៣.-

វិជ្ជាជីវៈមេធាវីមានវិសមិតភាពជាមួយនឹងមុខងារសាធារណៈ និងការប្រកបមុខរបរពាណិជ្ជកម្ម ទោះការប្រកបនោះដោយប្រយោលក្ដី ឬដោយផ្ទាល់ក្ដី ។

មាត្រា ៥៤.-

មេធាវីដែលបានទទួលតួនាទីក្នុងរាជរដ្ឋាភិបាល ឬទទួលអាណត្តិជាអ្នកតំណាងរាស្ត្រនៃរដ្ឋសភា អាចនៅជាសមាជិកនៃគណៈមេធាវីបាន ប៉ុន្តែត្រូវឈប់ប្រកបវិជ្ជាជីវៈនេះរហូតដល់ចប់តួនាទី ឬអាណត្តិនោះ ។

មាត្រា ៥៥.-

មេធាវីដែលជាអតីតមន្ត្រីរាជការ អាចធ្វើបទអន្តរាគមន៍ការពារកូនក្ដីប្រឆាំងនឹងក្រសួងមន្ទីររដ្ឋបាលដែលខ្លួនស្ថិតនៅក្រោមឱវាទពីមុនបាន លុះត្រាតែផុតរយៈពេល ៥ ឆ្នាំ គិតពីថ្ងៃឈប់ពីមុខងាររបស់ខ្លួន ។

### ផ្នែកទី ២
### បទវិន័យ

មាត្រា ៥៦.-

វិធាននៃវិជ្ជាជីវៈមេធាវីត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈ-មេធាវី ។ វិធាននេះធានាការគោរពដោយមេធាវីនូវគោលការណ៍ទាំងឡាយនៃសច្ចាប្រណិធានរបស់ខ្លួន ។

មាត្រា ៥៧.-

គ្រប់អំពើទាក់ទាញ ប្រកាសផ្សាយជាឯកត្តជន ឬទទូចសុំការពាររបស់មេធាវី ចំពោះអតិថិជនត្រូវហាមឃាត់ ។

មានតែការប្រកាសផ្សាយវិជ្ជាជីវៈជាសមូហភាពទេ ដែលអនុញ្ញាតឲ្យធ្វើបាន ។ ការប្រកាសផ្សាយនេះ ត្រូវធ្វើឲ្យបានត្រឹមត្រូវ ហើយមិនត្រូវឲ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មេធាវី ឡើយ ។

មាត្រា ៥៨.-

មេធាវីត្រូវតែរក្សាការសម្ងាត់ជាដាច់ខាត ។ មេធាវីកំណត់តាមសតិសម្បជញ្ញៈរបស់ខ្លួន និងដោយមានការយល់ព្រមពីអតិថិជនផងនូវអ្វីដែលខ្លួនត្រូវលើកឡើង ដើម្បីការពារ ផលប្រយោជន៍របស់អតិថិជនដែលខ្លួនទទួលបន្ទុក ។

មេធាវីពុំអាចបំពារបំពានលើការសម្ងាត់នៃវិជ្ជាជីវៈបានឡើយ ហើយក៏មិនអាច ត្រូវបានបង្ខំឲ្យបំពារបំពានលើការសម្ងាត់នៃវិជ្ជាជីវៈរបស់ខ្លួនទោះបីនៅមុខតុលាការក៏ដោយ ។

ត្រូវទុកជាការសម្ងាត់នៃវិជ្ជាជីវៈ ការពិគ្រោះយោបល់ និងការផ្ដល់យោបល់ ឯកសារក្រៅផ្លូវការទាំងឡាយ ដែលមេធាវីតាក់តែងឡើងសំរាប់អតិថិជន របស់ខ្លួន លិខិតស្នាមទាំងឡាយដែលមេធាវី និងអតិថិជនរបស់ខ្លួន លិខិតស្នាមទាំងឡាយដែលមេធាវី និងអតិថិជន ផ្ញើទាក់ទងគ្នា ។

## ផ្នែកទី ៣
## ទណ្ឌកម្មជាបទវិន័យ

មាត្រា ៥៩.-

ត្រូវទទួលទណ្ឌកម្មជាបទវិន័យ ចំពោះមេធាវីណាដែលប្រព្រឹត្តល្មើសនឹងវិធាននៃវិជ្ជាជីវៈ ឬប្រព្រឹត្តអំពើណាមួយដែលប៉ះពាល់ដល់សីលធម៌ ឬកិត្តិយសមេធាវី ទោះបីប្រព្រឹត្តក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ ។

មាត្រា ៦០.-

ការចោទប្រកាន់ត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាគណៈមេធាវីខ្លួនឯងផ្ទាល់ ឬដោយមានពាក្យបណ្តឹងពីតតិយជន ឬដោយមានពាក្យបណ្តឹងពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ ក្រុមប្រឹក្សាគណៈមេធាវីចាត់មេធាវីម្នាក់ឲ្យធ្វើជាអ្នករាយការណ៍ ។ ការប្តឹងត្រូវជូនដំណឹងជាមុនទៅសាមីខ្លួនដែលត្រូវដឹងពីសំណុំរឿងនៃការប្តឹងនោះ និងអាចបញ្ចេញយោបល់ការពារខ្លួនបាន ។ បើមានការស៊ើបអង្កេត ក៏ត្រូវផ្តល់ពត៌មាននោះទៅសាមីខ្លួនដែរ ។ របាយការណ៍ត្រូវផ្ញើជូនសាមីខ្លួនជាមួយនឹងលិខិតកោះអញ្ជើញ ហើយសំណុំរឿងក៏ត្រូវដាក់ឲ្យ សាមីខ្លួនពិនិត្យដែរ ។ លិខិតកោះអញ្ជើញត្រូវតែផ្ញើតាមលិខិតអនុសិដ្ឋដោយមានចុះសេចក្តីថា បានទទួល ឬជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងតិចមុនថ្ងៃប្រជុំ ។ សាមីខ្លួនអាចជ្រើសរើសយកមេធាវីម្នាក់ឲ្យការពារខ្លួនបាន ។ ប៉ុន្តែសាមីខ្លួនពុំអាចអវត្តមានដោយ ឲ្យជនណាម្នាក់ធ្វើជាតំណាងជួសខ្លួនបានឡើយ បើគ្មានការអនុគ្រោះយល់ព្រមជាពិសេស ជាមុនដោយមានមូលហេតុសមស្របទេ ។

បើគ្មានការឆ្លើយតបទៅនឹងបណ្តឹងរបស់អគ្គព្រះរាជអាជ្ញា ឬរបស់តតិយជនក្នុង រយៈពេល ២ ខែទេ ការមិនឆ្លើយតបពីក្រុមប្រឹក្សាគណៈមេធាវីត្រូវចាត់ទុកជាការបដិសេធបណ្តឹងនោះ ។ ការបដិសេធនេះអាចត្រូវបានប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ២ ខែ ចាប់ពីថ្ងៃផុតរយៈ ពេល ២ ខែខាងលើ ។

មាត្រា ៦១.-

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីដែលមានមូលហេតុច្បាស់លាស់ត្រូវបានជូនដំណឹងទៅសាមីខ្លួន និងអគ្គព្រះរាជអាជ្ញាក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសំរេចតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួល ។

មាត្រា ៦២.-

ការប្តឹងឧទ្ធរណ៍អាចធ្វើឡើងដោយសាមីខ្លួន ឬដោយអគ្គព្រះរាជអាជ្ញាទៅសាលាឧទ្ធរណ៍ក្នុងថិរៈវេលា និងតាមទម្រង់ដែលមានចែងក្នុងមាត្រា ២៥ ។ បណ្តឹងឧទ្ធរណ៍ត្រូវជំនុំជំរះជាសម្ងាត់ លើកលែងតែមានសេចក្តីសំរេចផ្ទុយ

ពីនេះរបស់សមេធាវី តាមការស្នើសុំច្បាស់លាស់ពីមេធាវីដែលត្រូវចោទ ។ គណៈមេធាវីមិនមែនជាភាគីក្នុងរឿងក្តីនេះទេ ប៉ុន្តែប្រធានគណៈមេធាវីត្រូវតែបញ្ចេញយោបល់កត់សំគាល់របស់ខ្លួន ហើយអគ្គព្រះរាជអាជ្ញាត្រូវធ្វើការសន្និដ្ឋាននៅពេលនោះ ។

មាត្រា ៦៣.-

ទណ្ឌកម្មជាបទវិន័យ មានដូចតទៅ ៖

- ការព្រមាន
- ការស្តីបន្ទោស
- ការហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈពេលដែលពុំអាចលើសពី ២ ឆ្នាំ
- ការលុបឈ្មោះចោលពីបញ្ជីនៃគណៈមេធាវី ឬពីបញ្ជីនៃមេធាវីកម្មសិក្សា ឬការ ហូតងារកិត្តិយស ។

មាត្រា ៦៤.-

ទោសហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈពេលអាចព្យួរបាន ។ ប៉ុន្តែបើក្នុងរយៈពេល ៥ ឆ្នាំ ក្រោយពីបានប្រកាសទោសព្យួរនេះ មេធាវីនោះត្រូវបានផ្តន្ទាទោសវិន័យថ្មីមួយទៀត ក្នុងករណីនេះត្រូវអនុវត្តទោសហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈដោយយកទោសថ្មីទៅបូកជាមួយ ទោសចាស់ដែលបានព្យួរ ។

មាត្រា ៦៥.-

គ្រប់ទណ្ឌកម្ម អាចត្រូវបានបន្ថែមទណ្ឌកម្មហាមឃាត់មិនឲ្យបំពេញជាប្រធានគណៈមេធាវី ឬជាសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ក្នុងរយៈពេលមិនលើសពី ៥ ឆ្នាំ ។ សេចក្តីសំរេចដាក់ទណ្ឌកម្មនេះត្រូវកំណត់ផងដែរ អំពីការផ្សាយជាសាធារណៈ បើជាការចាំបាច់ត្រូវផ្សាយ ។

មាត្រា ៦៦.-

ក្រុមប្រឹក្សាគណៈមេធាវីអាចផ្អាកពីមុខងារជាបណ្តោះអាសន្ន ចំពោះមេធាវីណា ដែលបានត្រូវចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ឬពីបទវិន័យណាមួយដោយបញ្ញត្តិ ឬតាមបណ្តឹងរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ បើគ្មាន

សេចក្ដីសម្រេចពីក្រុមប្រឹក្សាគណៈមេធាវីឆ្លើយ តបទៅនឹងការការប្ដឹងរបស់អគ្គព្រះរាជអាជ្ញាក្នុងរយៈពេល ២០ ថ្ងៃ នោះនឹងត្រូវចាត់ទុកជាការបដិសេធបណ្ដឹងនោះ ។

មាត្រា ៦៧.-

ការផ្អាកពីមុខងារជាបណ្ដោះអាសន្នពុំអាចសម្រេចបានឡើយ បើគ្មានការកោះអញ្ជើញសាមីខ្លួនឲ្យចូលមកបញ្ចេញយោបល់របស់ខ្លួន ។ ការកោះអញ្ជើញត្រូវធ្វើឡើងតាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្ដីថាបានទទួលហើយដែលត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងតិច ៥ ថ្ងៃ មុនថ្ងៃប្រជុំ ។ ការផ្អាកពីមុខងារជាបណ្ដោះអាសន្នអាច ត្រូវប្ដឹងឧទ្ធរណ៍បានក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦២ ។ ការប្ដឹងឧទ្ធរណ៍ពុំអាចផ្អាកការអនុវត្តន៍សេចក្ដីសម្រេចខាងលើបានឡើយ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធានា និងឃ្លាំមើលការអនុវត្តន៍ទណ្ឌកម្មខាងវិន័យ និងការផ្អាកពីមុខងារជាបណ្ដោះអាសន្ន ។

## ជំពូកទី ៤
## កំរៃ

មាត្រា ៦៨.-

មេធាវីទទួលកំរៃទៅតាមការឯកភាពគ្នាជាមួយអតិថិជន តាមទំហំការងារ តាមទំហំ សមត្ថភាពដែលបានបញ្ចេញក្នុងការងារនោះ តាមការលំបាកនៃការងារ តាមលទ្ធផលដែលសម្រេចបាន ឬតម្រេតារាងប្រាក់ម៉ោងកំណត់ដោយ គណៈមេធាវីរៀងរាល់ឆ្នាំ ។ មេធាវីត្រូវចេញបង្កាន់ដៃ ឲ្យអតិថិជននៅពេលបានប្រាក់កំរៃ ។

មាត្រា ៦៩.-

ការតវ៉ាអំពីកំរៃ ក្រៅពីប្ដឹងទៅតាមនីតិវិធីរដ្ឋប្បវេណី អាចប្ដឹងទៅប្រធានគណៈមេធាវីជាអាជ្ញាកណ្ដាលសម្រេចបាន បើមានការយល់ព្រមពីភាគីទំនាស់ ។ សេចក្ដីសម្រេចត្រូវឲ្យដំណឹងទៅសាមីខ្លួន តាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់

ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួល ។ បណ្តឹងឧទ្ធរណ៍ត្រូវធ្វើក្នុងរយៈពេល ២ ខែ ក្រោយថ្ងៃទទួលបណ្តឹង ។ ពាក្យបណ្តឹងត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ឬផ្ញើតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួល ។ បណ្តឹងឧទ្ធរណ៍នេះត្រូវជំនុំជំរះដោយប្រធានសាលាឧទ្ធរណ៍ ឬដោយអ្នកទទួលសិទ្ធិពីប្រធានសាលាឧទ្ធរណ៍ ។

## ជំពូកទី ៦

## គណនេយ្យ-ការប្រើប្រាស់មូលនិធិ

## ការធានា-ប្រាក់ធានារ៉ាប់រង

មាត្រា ៨០.-

មេធាវីដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈមេធាវី មិនអាចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់មូលនិធិរបស់អតិថិជន ឬមូលនិធិទុកសំរាប់អតិថិជនក្នុងពេលដែលខ្លួនបំពេញបេសកកម្មឲ្យអតិថិជនទេ ។ មូលនិធិនេះបានមកពីប្រាក់ធានាក្តី និងបានមកពីប្រាក់សំណងដែលឈ្នះក្តី ។ មេធាវីត្រូវដាក់មូលនិធិនេះក្នុងគណនីពិសេសមួយដែលបើកឡើងដោយគណៈមេធាវី ហើយមាន ឈ្មោះថា «បេឡាទូទាត់របស់គណៈមេធាវី» ។

មេធាវីពុំអាចរក្សាទុកមូលនិធិនេះនៅក្នុងបេឡានោះឲ្យលើសពីថិរៈវេលាចាំបាច់ ដើម្បីសំរេចកិច្ចការដែលអតិថិជនប្រគល់ឲ្យនោះទេ ។ គេពុំអាចកាត់យកកំរៃដែលគេត្រូវទទួល ក្នុងការសំរេចលទ្ធផលការងារពីមូលនិធិខាងលើនេះឡើយ លើកលែងតែមានការយល់ព្រមជា លាយលក្ខណ៍អក្សរពីអតិថិជន ។

មេធាវីអាចយកមូលនិធិដែលអតិថិជនបានតម្កល់ទុកសំរាប់បង់ប្រដាប់ក្តី និងកំរៃ អ្នកជំនួយការយុត្តិធម៌ទៅបង់ជំនួសអតិថិជនបាន ។

មាត្រា ៨១.-

មេធាវីអាចត្រូវបានតែងតាំងជាអ្នកទទួលទុកបញ្ញើ តាមការព្រមព្រៀងពីភាគីឬពីចៅក្រម ។ កិច្ចព្រមព្រៀង ឬសេចក្តីសំរេចអំពីការទទួលទុកបញ្ញើត្រូវកំណត់បែបបទ ជាពិសេស បែបបទនៃការប្រាក់ ព្រមទាំងបែបបទបញ្ចប់ទទួល

ទុកបញ្ជី ។ មូលនីធិ ឬវត្ថុទាំងឡាយ ត្រូវរក្សាទុកក្នុងបេឡាទូទាត់របស់គណៈមេធាវី ។

មាត្រា ៧២.-

មេធាវីត្រូវមានគណនេយ្យវិជ្ជាជីវៈមួយដោយឡែកស្របតាមច្បាប់ និងបទបញ្ជាផ្ទៃក្នុង ។ ការទូទាត់ប្រើមូលនីធិ ឬវត្ថុបញ្ញើត្រូវធ្វើឡើងក្នុងគណនេយ្យមួយដោយឡែក ។

មេធាវីត្រូវបង្ហាញបញ្ជីគណនេយ្យវិជ្ជាជីវៈរបស់ខ្លួន និងត្រូវបង្ហាញបញ្ជីគណនេយ្យផ្ទាល់ខ្លួនប្រសិនបើមាន ដល់អ្នកត្រួតពិនិត្យ ចាត់តាំងឡើងដោយក្រុមប្រឹក្សាគណៈមេធាវី។

មាត្រា ៧៣.-

មេធាវីត្រូវបង្ហាញថាខ្លួនបានបង់ប្រាក់ធានារ៉ាប់រងតាមរយៈគណៈមេធាវី សំរាប់ ធានារ៉ាប់រងការទទួលខុសត្រូវរបស់ខ្លួនក្នុងវិជ្ជាជីវៈ និងធានារ៉ាប់រងការសងមូលនីធិ និងរបស់មានតម្លៃទាំងឡាយដែលខ្លួនបានទទួលទុក ។ ប្រាក់ធានានោះត្រូវគិតបញ្ចូលក្នុងប្រាក់បង់វិភាគ-ទាន ដែលកំណត់ដោយគណៈមេធាវី ។

## ជំពូកទី ៧
## ការជំនួស ការទារដ្ឋបាល

មាត្រា ៧៤.-

មេធាវីដែលអាក់ខានប្រកបវិជ្ជាជីវៈរបស់ខ្លួនជាបណ្តោះអាសន្ន អាចចាត់តាំងអ្នកជំនួសម្នាក់ដោយមានការយល់ព្រមពីប្រធានគណៈមេធាវី ។ បើគ្មានការចាត់តាំងជំនួសទេនោះ ប្រធានគណៈមេធាវីចាត់តាំងអ្នកជំនួសដោយបញ្ញត្តិ ។

មាត្រា ៧៥ -

សេចក្តីសំរេចហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈកាល ឬផ្អាកការប្រកប

វិជ្ជាជីវៈជាបណ្តោះអាសន្ន ឬដាក់នៅក្រៅបញ្ជីគណៈមេធាវី ត្រូវចាត់តាំងមេធាវីម្នាក់ឲ្យគ្រប់គ្រងការិយាល័យមេធាវីជំនួស ។ បើអ្នកគ្រប់គ្រងការិយាល័យនោះមានធុរៈ ប្រធានគណៈមេធាវីត្រូវចេញសេចក្តីសំរេចចាត់តាំងអ្នកជំនួស ។

មាត្រា ៧៦ -

បើមេធាវីម្នាក់ទទួលមរណភាព ឬឈប់ប្រកបវិជ្ជាជីវៈរបស់ខ្លួន ប្រធានគណៈមេធាវីចាត់តាំងមេធាវីម្នាក់ឲ្យទទួលបន្ទុកចាត់ការលើសំណុំរឿង ដែលនៅសល់ និងជម្រះបញ្ជីគណនេយ្យ រួចបិទការិយាល័យ ។

## ជំពូកទី ៨

## ទោសប្បញ្ញត្តិ

មាត្រា ៧៧.-

ជនណាប្រព្រឹត្តល្មើសនិងមាត្រា ១ ២ ៣ ៤ ៥ ៦ ៧ ១៣ និង ៥៧ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ រៀលទៅដល់ ៥.០០០.០០០ រៀល ។ បើបទល្មើសនោះ ប្រព្រឹត្តឡើងដោយជនបរទេស ជននោះអាចត្រូវបណ្តេញចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាថែមទៀត ។

ក្នុងករណីមិនរាងចាល ត្រូវគុណ័យទ្វេមួយជាពីរ និងអាចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ ដល់ ៦ ខែ ។

បើមានបទល្មើសខាងលើនេះ ក្រុមប្រឹក្សាគណៈមេធាវីអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន ។

មាត្រា ៧៨.

ជនណាប្រព្រឹត្តល្មើសនិងមាត្រា ៥៨ ត្រូវផ្តន្ទាទោសតាមបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ ។

# ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

មាត្រា ៧៩.-

តួនាទីការពារកូនក្តីរបស់មេធាវីក្នុងរឿងព្រហ្មទណ្ឌអាចត្រូវបំពេញបានដោយអ្នកការពារក្តី ដែលមិនមែនជាមេធាវី តាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

មាត្រា ៨០.-

អាចត្រូវបានជ្រើសរើសឲ្យប្រឡងចូលរៀនក្នុងវគ្គបណ្តុះបណ្តាលមេធាវី ៖

- អ្នកការពារកូនក្តីដែលមានលទ្ធភាពបំពេញមុខងារនេះ ហើយដែលបំពេញមុខងារនេះពិតប្រាកដ និងជាប់រហូត ២ ឆ្នាំមក នៅតាមតុលាការខេត្ត ក្រុង ។ អ្នកការពារកូនក្តីទាំងនេះ ត្រូវមានកម្រិតចេះដឹងឧត្តមសិក្សាពី ២ ឆ្នាំឡើងទៅ ។
- មន្ត្រីរាជការដែលបានបម្រើការងាររដ្ឋ ២ ឆ្នាំ យ៉ាងតិច ហើយដែលមានសញ្ញាប័ត្រមធ្យមសិក្សានីតិសាស្ត្រ ។

អ្នកដែលមានបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល មិនចាំបាច់ប្រឡងទេ ។

មាត្រា ៨១.-

អាចទទួលឲ្យចុះឈ្មោះ ក្នុងបញ្ជីសំរាប់ឲ្យប្រឡងចូលរៀនក្នុងវគ្គបណ្តុះបណ្តាលមេធាវីបាន ស្របតាមមាត្រាខាងលើ អ្នកដែលមិនដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទល្មើសព្រហ្មទណ្ឌណាមួយ

មាត្រា ៨២.-

វគ្គបណ្តុះបណ្តាលមានរយៈពេលយ៉ាងតិច ៨ ខែ ។ កម្មវិធី និងបែបបទនៃវគ្គបណ្តុះបណ្តាលព្រមទាំងកម្មវិធី និងបែបបទនៃការប្រឡង ដើម្បីត្រួតពិនិត្យ លទ្ធផលនៃការបណ្តុះ បណ្តាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងករណីដែលមិនទាន់មានក្រុមប្រឹក្សាគណៈមេធាវី ។

អ្នកដែលប្រឡងជាប់ នឹងត្រូវទទួលវិញ្ញាបនប័ត្រសម្បទា សំរាប់ប្រកបវិជ្ជាជីវៈមេធាវី ។

មាត្រា ៨៣.-

មិនចាំបាច់មានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់ធ្វើកម្មសិក្សា ចំពោះ ៖

- អ្នកមានបរិញ្ញាប័ត្រច្បាប់ ឬអ្នកមានសញ្ញាប័ត្រច្បាប់ ដែលបានប្រកាសថាមានតម្លៃសមមូល ហើយបានបំរើការងារក្នុងវិស័យច្បាប់ ឬតុលាការ រយៈពេល ២ ឆ្នាំ យ៉ាងតិច
- អ្នកមានសញ្ញាប័ត្របណ្ឌិតច្បាប់
- ចៅក្រម ឬអតីតចៅក្រមដែលបានបំរើការងារក្នុងវិជ្ជាជីវៈរយៈពេល យ៉ាងតិច ២ ឆ្នាំ ។

មាត្រា ៨៤.-

មុនពេលបង្កើតបានគណៈមេធាវី អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានភារកិច្ចទទួលនិងពិនិត្យពាក្យសុំប្រកបវិជ្ជាជីវៈមេធាវី ហើយកោះអញ្ជើញអ្នកដែលបានបំពេញល័ក្ខខ័ណ្ឌសព្វគ្រប់ ឲ្យមកធ្វើសច្ចាប្រណិធានចំពោះមុខសាលាឧទ្ធរណ៍ដើម្បីបំពេញឋានៈជាមេធាវី និងចូលរួមមហាសន្និបាតបង្កើតគណៈមេធាវី ។

មាត្រា ៨៥.-

មហាសន្និបាតត្រូវរៀបចំបោះឆ្នោត ក្រោមការទទួលខុសត្រូវរបស់មេធាវីដែលមានវ័យចាស់ជាងគេ ដើម្បីជ្រើសរើសប្រធានគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី

មាត្រា ៨៦.

មួយឆ្នាំក្រោយមកទៀត ត្រូវរៀបចំការបោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវីថ្មីម្នាក់ និងក្រុមប្រឹក្សាគណៈមេធាវីថ្មីមួយ ដោយមេធាវីទាំងអស់ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី ។

មាត្រា ៨៧.-

ក្នុងករណីចាំបាច់ អាណត្តិនៃក្រុមប្រឹក្សាគណៈមេធាវី និងប្រធានគណៈមេធាវី ដែល ជាប់ឆ្នោតលើកដំបូង ត្រូវបន្តរហូតដល់ការប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវីថ្មី និងក្រុមប្រឹក្សាគណៈមេធាវីថ្មី ។

មាត្រា ៨៨.-

ដោយមិនទាន់គិតដល់មាត្រា ១៤ និងមាត្រា ១៥ អ្នកដែលមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោតដូចមានចែងក្នុងមាត្រា ៨៤ គឺមេធាវីទាំងឡាយដែលបានចុះឈ្មោះក្នុងបញ្ជីនៃគណៈមេធាវី និងក្នុងបញ្ជីកម្មសិក្សាដោយមិនគិតពីអតីតភាព ។

មាត្រា ៨៩.-

អន្តរប្បញ្ញត្តិនេះ មានអានុភាពអនុវត្តរហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ។

# ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា ៩០.-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១

ព្រះហស្តលេខា

នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា

ហ៊ុន សែន

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី២

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

ចែម ស្នួន

លេខ ..៤.ក.. ច.ល.

[illegible]

រាជធានីភ្នំពេញ ថ្ងៃទី ..[illegible].. ខែ សីហា ឆ្នាំ ១៩៩៥

[illegible]

[illegible] តាន់

# ច្បាប់
# ស្តីពី
# អន្តោប្រវេសន៍

# ច្បាប់

## ស្តីពី

## អន្តោប្រវេសន៍

### ជំពូកទី ១

### បទបញ្ញត្តិទូទៅ

មាត្រា ១ ._

ច្បាប់នេះមានគោលដៅគ្រប់គ្រងជនបរទេសគ្រប់រូប ដែលមកស្នាក់នៅលើទឹកដីនៃព្រះ_រាជាណាចក្រកម្ពុជា ។

មាត្រា ២ ._

ត្រូវចាត់ទុកជាជនបរទេស ជនណាដែលគ្មានសញ្ជាតិជាខ្មែរ ដោយគ្មានរើសអើង ទោះបីជននោះមានសញ្ជាតិ ជំនឿ សាសនា ឬមានដើមកំណើតណាមួយក៏ដោយ ។

មាត្រា ៣ ._

ច្បាប់នេះត្រូវអនុវត្តចំពោះជនបរទេសគ្រប់រូប លើកលែងតែក្នុងករណីដែលត្រូវអនុវត្តតាមវិធាននៃច្បាប់អន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ទោះបីជាជននោះបានចូលមកតាំងលំនៅមុនពេលដែលច្បាប់នេះចូលជាធរមានហើយក៏ដោយ ។

មាត្រា ៤ ._

អនុលោមតាមល័ក្ខខ័ណ្ឌនៃប្រវេសន៍ និងការស្នាក់អាស្រ័យនៅប្រទេសកម្ពុជា ជនបរ_ទេស ត្រូវចែកជាបីប្រភេទគឺ ៖

១_ ជនបរទេសមិនមែនអន្តោប្រវេសន្ត

២_ ជនបរទេសអន្តោប្រវេសន្ត

៣_ ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន ។

មាត្រា ៥ .-

ការគ្រប់គ្រងជនបរទេសជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។ ក្រសួងនេះត្រូវមានស្ថាប័នមួយដើម្បីទទួលខុសត្រូវកិច្ចការអន្តោប្រវេសន៍ ។

មាត្រា ៦ .-

ក្រសួងមហាផ្ទៃត្រូវកំណត់អំពីបែបបទនៃការចុះបញ្ជី ការផ្តល់ ការត្រួតពិនិត្យបំណ្ណ-ស្នាក់នៅ ទិដ្ឋាការចេញ ទិដ្ឋាការចូល លិខិតបើកផ្លូវ និងលិខិតឆ្លងដែន ឬឯកសារដែលមានតម្លៃស្មើគ្នាសំរាប់ជនបរទេស ។

## ជំពូកទី ២
## ជនបរទេសមិនមែនអន្តោប្រវេសន្ត

មាត្រា ៧ .-

ជនបរទេសមិនមែនអន្តោប្រវេសន្តគឺ ៖

១- ភ្នាក់ងារដែលបំពីការនៅស្ថានទូតបរទេស ឬស្ថានកុងស៊ុលបរទេស ឬស្ថានតំណាងបេសកកម្មបរទេស អ្នកជំនាញការអន្តរជាតិនិងជនផ្សេងៗទៀតដែលចូលមកព្រះរាជាណាចក្រកម្ពុជា តាមការស្នើសុំ ឬតាមកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយរាប់ទាំងក្រុមគ្រួសារ និងបុគ្គលិករបស់គេក្នុងរយៈពេលដែលគេស្នាក់អាស្រ័យនៅ ។

២- ទាហាន មន្ត្រី អ្នករដ្ឋការ និយោជិត និងភ្នាក់ងារបរទេស និស្សិត ព្រមទាំងគ្រួសារដែលចូលមកព្រះរាជាណាចក្រកម្ពុជា ដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ។

៣- អ្នកធ្វើដំណើរឆ្លងកាត់ ជាអ្នករង់ចាំមធ្យោបាយធ្វើដំណើរមុនពេលចេញដំណើរឆ្ពោះទៅកាន់ទីដៅចុងក្រោយរបស់ខ្លួន ។ ក្នុងករណីនេះ ការស្នាក់អាស្រ័យនៅមិនត្រូវលើសពីមួយសប្តាហ៍ លើកលែងតែក្នុងករណីប្រធានសក្តិ ។

៤- អ្នកទេសចរដែលមានសំបុត្រត្រឡប់ទៅវិញ ហើយរយៈពេលស្នាក់អាស្រ័យត្រូវកំណត់ដោយអនុក្រឹត្យ ។

៥- អ្នកតំណាងពាណិជ្ជកម្ម ធនាគារ អ្នកប្រកបមុខរបរផ្សេងៗទៀត ដែលចូលមកព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងបង្កើតទំនាក់ទំនងអំពីកិច្ចការខាងលើ ។ ក្នុងករណីនេះ ការស្នាក់អាស្រ័យមិនអាចលើសពី ៣ ខែ ។ ក្នុងករណីមានហេតុផលចាំបាច់ ការស្នាក់អាស្រ័យនៅនេះ អាចបន្តទៀតបានរយៈពេល ៣ ខែ ជាអតិបរមា តាមការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ។

៦_ ជនបរទេសរស់នៅតាមព្រំប្រទល់ជាប់នឹងខេត្តនានានៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការអនុញ្ញាតឱ្យឆ្លងកាត់ព្រំប្រទល់ច្រើនដង ឬមួយដងមួយកាល ។ លក្ខខណ្ឌផ្សេងៗក្នុងការអនុវត្តចំណុចទី ៦ មាត្រា ៧ នៃច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

៧_ អ្នកធ្វើដំណើរ កងនាវិក និងយានិក ដែលមកសំចតយកស្បៀងនៅតាមកំពង់ផែសមុទ្រ និងតាមព្រលានយន្តហោះ ។

៨_ ជនបរទេសដែលមកធ្វើការនេសាទនៅតាមឈ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ៨ ._

ជនបរទេសមិនមែនអន្តោប្រវេសន្តអាចស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន :

១_ ត្រូវមានការអនុញ្ញាតចូលជាមុនពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈអាជ្ញាធរទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ឬតាមរយៈអាជ្ញាធរបរទេសណាមួយដែលតំណាងឱ្យផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ។ ចំពោះអ្នកដំណើរឆ្លងកាត់ កងនាវិក យានិក ការអនុញ្ញាតនេះនឹងត្រូវផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជានៅពេលដែលគេចេញពីនាវា ឬព្រលានយន្តហោះ ។

២_ ត្រូវនាំមកជាមួយនូវលិខិតឆ្លងដែនរបស់ខ្លួន ឬឯកសារណាមួយដែលមានតម្លៃស្មើ ដែលមានចុះទិដ្ឋាការចូលដោយអាជ្ញាធរ ដូចមានកំណត់នៅវាក្យខណ្ឌទីមួយខាងលើ ។

៣_ ត្រូវបង់ថ្លៃទិដ្ឋាការ អាករព្រលានយន្តហោះឬកំពង់ផែ ។ លក្ខខណ្ឌនៃការបង់ថ្លៃនិងអាករនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៩ ._.

ជនបរទេសមិនមែនអន្តោប្រវេសន្តណាដែលមិនបានបំពេញតាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ៨ នៃច្បាប់នេះ មិនត្រូវអនុញ្ញាតឱ្យចូលមកព្រះរាជាណាចក្រកម្ពុជា លើកលែងតែក្នុងករណីដែលមានការអនុញ្ញាតផ្សេងពីនេះរបស់រាជរដ្ឋាភិបាល ។

ក្នុងករណីប៉ះពាល់ដល់សន្តិសុខជាតិ អាជ្ញាធរមានសមត្ថកិច្ចអាចហាមឃាត់មិនឱ្យចូលបាន ទោះបីជនបរទេសមិនមែនអន្តោប្រវេសន្តនោះបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៨ ហើយក៏ដោយ ។

# ជំពូកទី ៣

## ជនបរទេសអន្តោប្រវេសន្ត

មាត្រា ១០ .-

ជនបរទេសដែលចាត់ទុកជាអន្តោប្រវេសន្តគឺ :

១- ជនបរទេសដែលមកដល់ព្រះរាជាណាចក្រកម្ពុជាដោយស្របច្បាប់ ដើម្បីស្នាក់នៅរយៈពេលយូរ ឬដើម្បីប្រកបវិជ្ជាជីវៈ ឬធ្វើសកម្មភាពផ្សេងៗដែលទាក់ទងនឹងឧស្សាហកម្ម ពាណិជ្ជកម្ម សេវា ឬកសិកម្ម ។

២- ជនបរទេសដែលគ្មានរាប់ចូលក្នុងប្រភេទណាមួយ ដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ។

មាត្រា ១១ .-

អាចទទួលឱ្យស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជាចំពោះជនបរទេសអន្តោប្រវេសន្តណាដែលបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៨នៃច្បាប់នេះ ហើយលើសពីនេះត្រូវបំពេញកាតព្វកិច្ចដូចតទៅ :

១- បង្ហាញនូវសម្បទាមានផលប្រយោជន៍ដល់សេដ្ឋកិច្ច ឬសង្គមកិច្ច ឬវិទ្យាសាស្ត្របច្ចេកទេស ឬវប្បធម៌ សំរាប់ព្រះរាជាណាចក្រកម្ពុជា ។

២- តំកល់ប្រាក់ធានាតាមចំនួនសមស្រប សំរាប់បង់ថ្លៃសោហ៊ុយធ្វើដំណើរត្រឡប់ទៅវិញឬមាតុភូមិនិវត្តន៍ដោយថាហេតុនិងមានប្រាក់ធានាថាអាចរស់នៅបានដោយសារទ្រព្យសម្បត្តិផ្ទាល់ខ្លួន ។

ចំនួនទឹកប្រាក់ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

៣- មានកាយសម្បទាបំពេញវិជ្ជាជីវៈខ្លួនបាន ដោយមានការបញ្ជាក់ពីគ្រូពេទ្យនៃប្រទេសដែលអន្តោប្រវេសន្តចេញមក និងមានកិច្ចសន្យាការងារជាលាយលក្សណ៍អក្សរ ។

៤- មានលិខិតថ្កោលទោសដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើមរបស់ខ្លួន ។

៥- ទោះបីជនបរទេសអន្តោប្រវេសន្ត បានបំពេញលក្ខខណ្ឌដូចមានចែងក្នុងវាក្យខណ្ឌខាងលើនេះហើយក៏ដោយ ក៏ជនគ្រប់រូបទាំងនោះត្រូវបំពេញឱ្យបាននូវលក្ខខណ្ឌផ្នែកសន្តិសុខដែលព្រះរាជាណាចក្រកម្ពុជាតម្រូវឱ្យមាន ។

មាត្រា ១២ :-

ការទទួលស្គាល់ជនបរទេសណាម្នាក់ជាជនបរទេសអន្តោប្រវេសន្ត ត្រូវសំរេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ១៣ :-

ជនបរទេសអន្តោប្រវេសន្ត ឬមិនមែនអន្តោប្រវេសន្តដែលត្រូវបានទទួលឱ្យចូលក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបង្ហាញខ្លួននៅប៉ុស្តិ៍ត្រួតពិនិត្យអន្តោប្រវេសន្ត ទាំងពេលមកដល់ និងពេលចេញដំណើរទៅវិញ ។ ច្រកចេញចូល ឬចំណុចចេញចូលរបស់ជនបរទេសត្រូវកំណត់ និងគ្រប់គ្រងដោយក្រសួងមហាផ្ទៃ ។

មាត្រា ១៤ :-

ជនបរទេសអន្តោប្រវេសន្តត្រូវទៅបង្ហាញខ្លួនក្នុងរយៈពេល ៤៨ ម៉ោង ក្រោយពេលមកដល់ នៅការិយាល័យជនបរទេសនៃស្នងការដ្ឋាននគរបាល ខេត្ត ក្រុង ដែលខ្លួនមានបំណងស្នាក់នៅដើម្បីធ្វើពាក្យសុំប័ណ្ណស្នាក់នៅ ។ បង្កាន់ដៃសំគាល់នឹងត្រូវផ្តល់ភ្លាមជូនសាមីខ្លួនក្រោយពីបានទទួលពាក្យសុំនេះ ។

មាត្រា ១៥ :-

ក្នុងករណីដែលមានការផ្លាស់ប្តូរលំនៅដ្ឋាន ជនបរទេសអន្តោប្រវេសន្តត្រូវសុំការបញ្ជាក់នៅលើប័ណ្ណស្នាក់នៅរបស់ខ្លួន នៅការិយាល័យជនបរទេសនៃស្នងការដ្ឋាននគរបាលខេត្ត ក្រុងដែលខ្លួនមានលំនៅដ្ឋានមុនពេលខ្លួនចេញដំណើរ ។ ជនបរទេសអន្តោប្រវេសន្តត្រូវបំពេញបែបបទដូចខាងលើនេះ ក្នុងរយៈពេល ៤៨ ម៉ោង បន្ទាប់ពីបានទៅដល់លំនៅដ្ឋានថ្មី ។

មាត្រា ១៦ :-

ប័ណ្ណស្នាក់នៅនេះត្រូវបង្ហាញនៅពេលដែលមានការឆែកឆេរពីអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ។ ប័ណ្ណស្នាក់នៅនេះអាចដកហូតបានពីសាមីជនណាដែលមិនបានគោរពតាមបទបញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីដកហូតប័ណ្ណស្នាក់នៅ ជនបរទេសអន្តោប្រវេសន្តត្រូវចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេលប្រាំពីរថ្ងៃ ។ ក៏ប៉ុន្តែតាមកាលៈទេសៈជាក់ស្តែង រយៈពេលនេះអាចកែប្រែបានដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃតាមសំណើរបស់ស្នងការដ្ឋាននគរបាលខេត្ត ក្រុង ហើយរយៈពេលបន្ថែមនិងត្រូវលើសពី ៣ ខែ ។

ការឈប់ទទួលស្គាល់ជនបរទេសណាម្នាក់ជាជនបរទេសអន្តោប្រវេសន្ត ត្រូវសំរេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ១៧ ._

ជាគោលការណ៍ ជនបរទេសអាចធ្វើចរាចរបានដោយសេរីនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ក៏ប៉ុន្តែក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចដាក់បញ្ញត្តិហាមឃាត់ចរាចរជនបរទេស និងហាមឃាត់ជនបរទេសអន្តោប្រវេសន្ត ឬមិនមែនអន្តោប្រវេសន្តទាំងអស់មិនឱ្យចូល ឬស្នាក់អាស្រ័យនៅក្នុងតំបន់ ឬចាកចេញឆ្ងាយពីតំបន់ ឬកន្លែងណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៨ ._

ម្ចាស់ ឬអ្នកកាន់កាប់លំនៅដ្ឋានគ្រប់ប្រភេទ ត្រូវជូនដំណឹងក្នុងរយៈពេល ២៤ ម៉ោង ដល់ស្ថាប័ននគរបាលមានសមត្ថកិច្ចពីវត្តមាននៃជនបរទេសអន្តោប្រវេសន្ត ឬមិនមែនអន្តោប្រវេសន្តដែលបានមកស្នាក់នៅ ។

មាត្រា ១៩ ._

ការទទួលជនបរទេសឱ្យធ្វើការត្រូវអនុវត្តតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា ។ ក្រសួងមហាផ្ទៃមានសិទ្ធិត្រួតពិនិត្យប័ណ្ណការងាររបស់ជនបរទេសនៅតាមរោងចក្រ សហគ្រាស ក្រុមហ៊ុន គ្រឹះស្ថាននានា ដោយសហការជាមួយក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

មាត្រា ២០ ._

ស្នងការដ្ឋាននគរបាលខេត្ត ក្រុង ត្រូវជូនដំណឹងទៅក្រសួងមហាផ្ទៃអំពីមរណភាពនិងការបាត់ខ្លួនរបស់ជនបរទេសអន្តោប្រវេសន្ត ដែលស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន ។

មាត្រា ២១ ._

ប័ណ្ណស្នាក់នៅចេញឱ្យលើកដំបូងមានសុពលភាពសំរាប់រយៈពេលពីរឆ្នាំ ។ ប័ណ្ណស្នាក់នៅនេះអាចសុំបន្តការប្រើប្រាស់បានរាល់ពីរឆ្នាំម្តង ។ ពាក្យសុំប័ណ្ណស្នាក់នៅថ្មី ឬសុំបន្តរយៈពេលប្រើប្រាស់ត្រូវធ្វើនៅចំពោះមុខអាជ្ញាធរដូចបានកំណត់ត្រង់មាត្រា ១៥ នៃច្បាប់នេះ ។ ហួសកំណត់ខាងលើនេះ ម្ចាស់ប័ណ្ណស្នាក់នៅដែលមិនបានសុំប័ណ្ណស្នាក់នៅថ្មី ឬសុំបន្តរយៈពេលប្រើប្រាស់ត្រូវចាត់ទុកថាស្ថិតនៅក្នុងស្ថានភាពមិនត្រឹមត្រូវតាមច្បាប់ ។ ក្រសួងមហាផ្ទៃត្រូវកំណត់ដោយប្រកាសរបស់ក្រសួង នូវវិធានការអនុវត្តទាក់ទងនឹងការគ្រប់គ្រង ការធ្វើប័ណ្ណស្នាក់នៅ ការសុំនិងលក្ខខណ្ឌនានា ដែលត្រូវអនុវត្តក្នុងវិស័យនេះ ។ ជនបរទេសអន្តោប្រវេសន្តត្រូវបង់អាករសំរាប់ការចេញប័ណ្ណស្នាក់នៅដើមឬទុតិយតា ឬឯកសារដែលមានតម្លៃស្មើគ្នា តាមការកំណត់របស់អនុក្រឹត្យ ។

មាត្រា ២២ .-

ស្នងការដ្ឋាននគរបាលខេត្ត ក្រុង ត្រូវទទួលខុសត្រូវត្រួតពិនិត្យជនបរទេសទាំងអស់ ដែលបានតាំងទីលំនៅ ឬទើបនឹងមកតាំងទីលំនៅក្នុងដែនដីក្រោមសមត្ថកិច្ចរបស់ខ្លួន ។

មាត្រា ២៣ .-

ជនបរទេសអន្តោប្រវេសន្តណាដែលមានបំណងចាកចេញពីព្រះរាជាណាចក្រកម្ពុជាមួយរយៈពេល ត្រូវសុំការអនុញ្ញាតចេញ និងវិលមកវិញពីក្រសួងមហាផ្ទៃ ។ ជាគោលការណ៍ រយៈពេលនៃការស្នាក់អាស្រ័យនៅបរទេសមិនត្រូវលើសពី បីខែឡើយ ។ ប៉ុន្តែរយៈពេលនេះអាចពន្យាបានរហូត ប្រាំមួយខែ ប្រសិនបើមានមូលហេតុសមហេតុសមផល ។ អាការលើការផ្តល់ការអនុញ្ញាតចេញ និងវិលមកវិញត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ២៤ .-

ក្នុងករណីត្រឡប់មកវិញលើសរយៈពេលអនុញ្ញាត សាមីខ្លួនត្រូវធ្វើពាក្យសុំទិដ្ឋាការចូល ហើយចាត់ទុកថា ជននោះជាជនបរទេសអន្តោប្រវេសន្តមកថ្មី ។

## ជំពូកទី ៤
## ជនបរទេសអន្តោប្រវេសន្ត
## ជាអ្នកវិនិយោគឯកជន

មាត្រា ២៥ .-

ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន គឺជនបរទេសដែលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើវិនិយោគក្នុងក្របខ័ណ្ឌនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២៦ .-

ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន ចែកចេញជាពីរប្រភេទគឺ ៖

១- ជនបរទេសដែលចូលមកកម្ពុជាដើម្បីពិនិត្យលទ្ធភាពធ្វើវិនិយោគ

២- ជនបរទេសដែលបានទទួល " លិខិតអនុញ្ញាតឱ្យវិនិយោគ " ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជារួចហើយ ។

មាត្រា ២៧ .-

ជនបរទេសដែលចូលមកព្រះរាជាណាចក្រកម្ពុជាដើម្បីពិនិត្យលទ្ធភាពធ្វើវិនិយោគ ត្រូវបំពេញល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងជំពូកទី ៣ ស្តីពីជនបរទេសអន្តោប្រវេសន្ត លើកលែងតែសុពលភាពសំរាប់រយៈពេលស្នាក់នៅបណ្តោះអាសន្ន គឺសំរាប់រយៈពេលមួយឆ្នាំ ។ ក្រោយរយៈពេលមួយឆ្នាំនៃការស្នាក់នៅ ក្នុងករណីដែលមិនអាចមានលទ្ធភាពធ្វើវិនិយោគបានលើវិស័យណាមួយទេ ជនបរទេសនោះអាចដកប្រាក់តម្កល់នានាវិញបាន ហើយមិនអាចបន្តឱ្យស្នាក់នៅបានទៀតឡើយ ។

មាត្រា ២៨ .-

ជនបរទេសដែលបានទទួល លិខិតអនុញ្ញាតឱ្យវិនិយោគ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជារួមទាំងគ្រួសារផ្ទាល់ខ្លួន នឹងបានទទួលការអនុញ្ញាតឱ្យស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាជាអចិន្ត្រៃយ៍ ឬតាមរយៈពេលដែលបានកំណត់ក្នុងលិខិតអនុញ្ញាតឱ្យវិនិយោគ និងមានសិទ្ធិសុំកាន់ឯកសារធ្វើដំណើររបស់ព្រះរាជាណាចក្រកម្ពុជា ។

បែបបទនៃការអនុវត្តមាត្រា ២៨ នេះ នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥
## ទោសបញ្ញត្តិ

មាត្រា ២៩ .-

ជនបរទេសរូបណាដែលគ្មានការអនុញ្ញាត ហើយចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាដោយលបលាក់ បន្លំ ឬ ដោយល្បិចផ្សេងទៀតដែលផ្ទុយនឹងបញ្ញត្តិនៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់គុកពី បីខែ ដល់ ប្រាំមួយខែ មុននឹងត្រូវបណ្តេញចេញ ។

ត្រូវផ្តន្ទាទោសដូចគ្នានឹងជនល្មើស ចំពោះជនណាដែលផ្តល់ជំនួយ ឬជួយលាក់បាំងក្នុងការបញ្ចូលជនបរទេសដែលគ្មានការអនុញ្ញាតមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

មន្ត្រី ឬភ្នាក់ងាររាជការមានសមត្ថកិច្ចរូបណា ដែលជាអ្នកសមគំនិត ឬជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើសខាងលើ ត្រូវផ្តន្ទាទោសដាក់គុកពី ប្រាំមួយខែ ដល់ មួយឆ្នាំ ។

មន្ត្រី ឬភ្នាក់ងាររាជការមានសមត្ថកិច្ចរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជា ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ។

មធ្យោបាយសម្ភារៈប្រើសំរាប់ប្រព្រឹត្តបទល្មើសត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋដោយតុលាការ។

មាត្រា ៣០ ._

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ៥០.០០០ រៀល ដល់ ១.០០០.០០០ រៀល ចំពោះជនបរទេសណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ១៤_១៥_១៦_១៧_២១ និង ២៣ នៃច្បាប់នេះ ។

ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០១ រៀល ដល់ ២.០០០.០០០ រៀល ។

មាត្រា ៣១ ._

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ១០.០០០ រៀល ដល់ ៣០.០០០ រៀល ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ១៨ នៃច្បាប់នេះ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ៣០.០០១ រៀល ដល់ ៦០.០០០ រៀល ។

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០០.០០០ រៀល ដល់ ៥០០.០០០ រៀល ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ១៩ នៃច្បាប់នេះ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់គុកពី មួយខែ ដល់បីខែ ។

មាត្រា ៣២ ._

ជនណាដែលធ្វើការកោស លុប សរសេរត្រួត ក្លែង ឬឱ្យគេខ្ចី ឬមួយក៏សរសេរឈ្មោះក្លែងក្លាយនៅក្នុងប័ណ្ណស្នាក់នៅ ប័ណ្ណការងារ កិច្ចសន្យាការងារ ឬមួយក៏ប្រើប្រាស់ឯកសារទាំងនោះដែលមានឈ្មោះផ្សេងពីឈ្មោះខ្លួន ឬធ្វើបណ្តឹងក្លែងបន្លំសុំឯកសារដូចខាងលើ ត្រូវផ្តន្ទាទោសដាក់គុកពី ប្រាំឆ្នាំ ដល់ដប់ប្រាំឆ្នាំ ។

អ្នកសមគំនិតត្រូវផ្តន្ទាទោសដូចគ្នា ។

មាត្រា ៣៣ ._

ការផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ដែលមានចែងក្នុងបញ្ញត្តិនៃច្បាប់នេះជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។

មាត្រា ៣៤ .

ក្រៅពីមូលទោសដែលមានចែងក្នុងច្បាប់នេះ ត្រូវមានអនុទោសបន្ថែមទៀតគឺការបណ្តេញចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

# ជំពូកទី ៦
## ការបណ្តេញចេញ

មាត្រា ៣៥

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា រាល់ជនបរទេសអន្តោប្រវេសន្តណាដែលរំលោភលើបញ្ញត្តិច្បាប់អន្តោប្រវេសន្ត ។

មាត្រា ៣៦ ._

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានសិទ្ធិបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា រាល់ជនបរទេសដែល ៖

១_ មានអាកប្បកិរិយានិងសកម្មភាពគ្រោះថ្នាក់ដល់សន្តិសុខជាតិនៃព្រះរាជាណាចក្រកម្ពុជា ឬ

២_ ក្រសួងមានសមត្ថកិច្ចមានភស្តុតាងជាក់លាក់ថាជននោះជាអ្នកប្រឆាំងនិងសន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា ឬ

៣_ មកធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានប័ណ្ណការងារ ។

មាត្រា ៣៧ ._

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា រាល់ជនបរទេសណាដែលចូលក្នុងព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ ។

មាត្រា ៣៨ ._

សេចក្តីសំរេចបណ្តេញចេញត្រូវអនុវត្តភ្លាម ចាប់ពីថ្ងៃចុះហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ សាមីខ្លួនមានសិទ្ធិប្តឹងទៅតុលាការក្នុងរយៈពេល ២ ខែ ។

មាត្រា ៣៩ ._

ការបណ្តេញចេញត្រូវអនុវត្តក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរ ក្រោយពីសេចក្តីសំរេចចេញជាផ្លូវការពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែមានសាលក្រមផ្អាកការអនុវត្តពីតុលាការ ។

## ជំពូកទី ៧
## អវសានបញ្ញត្តិ

**មាត្រា ៤០ .-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤១ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៤
នាសម័យប្រជុំវិសាមញ្ញនីតិកាលទី ១

ភ្នំពេញ, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៤
ប្រធានរដ្ឋសភាស្តីទី

គីន ស៊្រីវង្ស

# ច្បាប់

# ស្ដីពី

# សញ្ជាតិ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

នស/រកម/០៦១៨/០០៩

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសញ្ជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១០ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .–**

ច្បាប់នេះមានគោលបំណងជានាការអនុវត្តដែនយុត្តាធិការរបស់ព្រះរាជាណាចក្រកម្ពុជាទៅលើរូបវន្តបុគ្គល ដើម្បីកំណត់នូវសិទ្ធិទទួលបាន និងសិទ្ធិលះបង់សញ្ជាតិខ្មែរ ចំពោះជនដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស និងដែលបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ ។

**មាត្រា២ .–**

ច្បាប់នេះមានគោលដៅកំណត់អំពី ៖

- ការទទួលបានសញ្ជាតិខ្មែរពីកំណើត
- ការទទួលបានសញ្ជាតិខ្មែរដោយការសុំកូនពេញលេញ
- ការទទួលបានសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍
- ការទទួលបានសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម
- ការបាត់សញ្ជាតិខ្មែរ ។

**មាត្រា៣ .–**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរូបវន្តបុគ្គលដែលកើត ឬរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស ។

**មាត្រា៤ .–**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យដូចតទៅ ៖

១-សញ្ជាតិខ្មែរ សំដៅដល់ចំណងគតិយុត្ត និងនយោបាយដែលភ្ជាប់រូបវន្តបុគ្គលទៅនឹងព្រះរាជាណាចក្រកម្ពុជា ។

២- ការទាមទារសញ្ជាតិខ្មែរ សំដៅដល់សិទ្ធិក្នុងការស្នើសុំសញ្ជាតិខ្មែរ ដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍ស្របច្បាប់រវាងជនបរទេស និងប្រជាពលរដ្ឋខ្មែរ ។

៣- សញ្ជាតូបនីយកម្ម សំដៅដល់ការផ្តល់សញ្ជាតិខ្មែរតាមរយៈការស្នើសុំរបស់ជនបរទេស ដោយផ្អែកតាមលក្ខខណ្ឌនៃការស្នាក់នៅ ការវិនិយោគ អំណោយជាសាច់ប្រាក់ និងគុណសម្បត្តិពិសេស ឬថ្វីដៃពិសេស ។

# ជំពូកទី ២
# ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៥ .–**

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចដឹកនាំអនុវត្តច្បាប់ស្តីពីសញ្ជាតិ ។

# ជំពូកទី ៣
# គោលការណ៍ទូទៅ

**មាត្រា៦ .–**

ជនណាមានសញ្ជាតិខ្មែរជាប្រជាពលរដ្ឋខ្មែរ ។

មានតែប្រជាពលរដ្ឋខ្មែរទេ ទើបមានសិទ្ធិទទួលនិងកាន់កាប់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៧ .–**

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

**មាត្រា៨ .–**

ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅឯបរទេស៖

១. ត្រូវបានរដ្ឋគាំពារតាមគ្រប់មធ្យោបាយការទូត ។

២. មិនអាចបាត់សញ្ជាតិដោយឯកឯង ។

# ជំពូកទី ៤
# សញ្ជាតិខ្មែរពីកំណើត និងសញ្ជាតិខ្មែរពីការសុំកូនពេញលេញ
## ផ្នែកទី ១
## សញ្ជាតិខ្មែរពីកំណើត

**មាត្រា៩ .–**

១- ត្រូវបានសញ្ជាតិខ្មែរ ទោះបីកើតនៅទីណាក៏ដោយ ៖

- កូនដែលកើតពីឪពុកឬម្តាយមានសញ្ជាតិខ្មែរឬ

- កូនដែលឪពុកម្ដាយមិនទទួលស្គាល់ កាលបើតុលាការបានចេញសាលក្រមថា កូននោះពិតជាកើតពីឪពុក ឬម្ដាយដែលមានសញ្ជាតិខ្មែរ ។

២- ត្រូវបានសញ្ជាតិខ្មែរ ដោយកើតក្នុងព្រះរាជាណាចក្រកម្ពុជា ៖

- កូនដែលកើតពីឪពុកនិងម្ដាយជាជនបរទេស ដែលកើតនិងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា

- កូនដែលកើតពីឪពុកម្ដាយមិនស្គាល់ និងកូនទើបនឹងកើតដែលគេរើសបាននៅក្នុង ព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថា កើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ ។

## ផ្នែកទី ២
## សញ្ជាតិខ្មែរដោយការសុំកូនពេញលេញ

**មាត្រា១០ .-**

កូនជនបរទេសដែលត្រូវបានសុំជាកូនសុំពេញលេញដោយសហព័ទ្ធពលរដ្ឋខ្មែរ ត្រូវទទួលបានសញ្ជាតិខ្មែរ នៅពេលដែលសុំកូនពេញលេញត្រូវបានបង្កើតឡើងស្របតាមច្បាប់ជាធរមាន ។

## ជំពូកទី ៥
## សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍

**មាត្រា១១ .-**

ស្ត្រី ឬបុរសបរទេសដែលយកប្ដី ឬប្រពន្ធពលរដ្ឋខ្មែរដោយបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិខ្មែរបាន លុះណាតែស្ត្រី ឬបុរសនោះបានរស់នៅជាមួយគ្នារយៈពេលបីឆ្នាំ ក្រោយចុះបញ្ជីអាពាហ៍ពិពាហ៍ និងបានស្នាក់នៅយ៉ាងហោចរយៈពេល ១២ (ដប់ពីរ)ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ត្រូវបានអនុញ្ញាតឱ្យសុំទាមទារសញ្ជាតិខ្មែរជាចង្កោមគ្រួសារចំពោះជនបរទេសជាម្ដាយ ឬឪពុកដែលមានកូនជាអនីតិជន ។

**មាត្រា១២ .-**

ជនបរទេសដែលអាចសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍បាន ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

១- មានគំនិត មារយាទ និងសីលធម៌ល្អ ។

២- ពុំដែលមានទោសពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ ។

៣- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ។

៤-ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៥- មានបញ្ញា និងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ ។

**មាត្រា១៣ .–**

ជនបរទេសដែលសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍អាចសុំប្តូរឈ្មោះជាខ្មែរបាន ។ ក្នុងករណីនេះ ត្រូវសរសេរបញ្ជាក់ឈ្មោះថ្មីនោះ ក្នុងពាក្យសុំទាមទារសញ្ជាតិខ្មែររបស់ខ្លួន ។

**មាត្រា១៤ .–**

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចបដិសេធការទាមទារសញ្ជាតិខ្មែរ សាមីខ្លួនមានសិទ្ធិប្តឹងតវ៉ា ។

**មាត្រា១៥ .–**

បែបបទ និងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ ព្រមទាំងនីតិវិធីនៃការប្តឹងតវ៉ា ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការផ្តល់សញ្ជាតិខ្មែរ តាមករណីទាមទារសញ្ជាតិខ្មែរ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ ។

**មាត្រា១៦ .–**

ជនដែលបានអនុញ្ញាតឱ្យចូលសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល ។

ខ្លឹមសារនៃសម្បថនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា១៧ .–**

ប្រជាពលរដ្ឋខ្មែរមិនបាត់សញ្ជាតិខ្មែរ ដោយសារការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសទេ ។

## ជំពូកទី ៦
## សញ្ជាតូបនីយកម្ម

**មាត្រា១៨ .–**

ជនបរទេសអាចសុំចូលសញ្ជាតិខ្មែរបាន ដោយសញ្ជាតូបនីយកម្ម ។

សញ្ជាតូបនីយកម្មមិនមែនជាសិទ្ធិរបស់អ្នកស្នើសុំឡើយ គឺជាការអនុគ្រោះរបស់ ព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។ ទោះក្នុងប្រការណាក៏ដោយ ពាក្យសុំនោះអាចត្រូវបដិសេធចោលតាមអំណាចឆន្ទានុសិទ្ធិ ។

**មាត្រា១៩ .–**

ជនបរទេសដែលអាចសុំសញ្ជាតូបនីយកម្មបាន ត្រូវបំពេញលក្ខខណ្ឌដូចតទៅ ៖

១- មានគំនិត មារយាទ និងសីលធម៌ល្អ ។

២- ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

៣- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយស្នាក់នៅជាប់ចំនួន ៧ (ប្រាំពីរ)ឆ្នាំ ដោយគិតពីថ្ងៃដែលបានទទួលបណ្ណស្នាក់នៅ ដែលចេញឱ្យក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ចំពោះ

ជនបរទេសអន្តោប្រវេសន្ត ។

៤- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបណ្ណស្នាក់នៅដែលចេញឱ្យក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ចំពោះជនបរទេសដែលបានកំណត់នៅក្នុងមាត្រា២១ និងមាត្រា២២ នៃច្បាប់នេះ ។

៥- ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយបង្ហាញភស្តុតាងថាខ្លួនអាចរស់នៅក្នុងសង្គមខ្មែរបានដោយសុខដុម ព្រមទាំងទទួលបាននូវទំនៀមទម្លាប់និងប្រពៃណីល្អរបស់ខ្មែរ ។

៦- មានបញ្ញា និងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ ។

**មាត្រា២០ .-**

ចំពោះជនបរទេសអន្តោប្រវេសន្តណាដែលកើតក្នុងព្រះរាជាណាចក្រកម្ពុជា រយៈពេលស្នាក់នៅជាប់ចំនួន ៧ (ប្រាំពីរ)ឆ្នាំ ដូចមានចែងក្នុងចំណុចទី៣ មាត្រា១៩ នៃច្បាប់នេះ ត្រូវបន្ថយមកនៅ ៣(បី)ឆ្នាំវិញ ។

**មាត្រា២១ .-**

ជនបរទេសណាដែលបានទទួលការអនុញ្ញាតឱ្យវិនិយោគត្រឹមត្រូវតាមច្បាប់ ពីស្ថាប័នមានសមត្ថកិច្ច ហើយបានចំណាយទុនអនុវត្តគម្រោងវិនិយោគជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចដាក់ពាក្យសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មបាន ក្នុងករណីជនបរទេសនោះបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១ ទី២ ទី៤ ទី៥ និងទី៦ មាត្រា១៩ នៃច្បាប់នេះ និងបានស្នាក់នៅស្របច្បាប់យ៉ាងហោចរយៈពេល ១២ (ដប់ពីរ) ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ចំនួនទឹកប្រាក់ វិស័យអាទិភាព និងប្រភេទគម្រោងវិនិយោគ ព្រមទាំងលក្ខខណ្ឌផ្សេងទៀត ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា២២ .-**

ជនបរទេសណាដែលបានធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិ សម្រាប់ជាផលប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឬវិស័យមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចដាក់ពាក្យសុំចូលសញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១ ទី២ ទី៤ និងទី៦ មាត្រា១៩ នៃច្បាប់នេះ និងបានស្នាក់នៅស្របច្បាប់យ៉ាងហោចរយៈពេល ៦ (ប្រាំមួយ)ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ចំនួនទឹកប្រាក់អំណោយជាសាច់ប្រាក់ដល់ថវិកាជាតិ ឬវិស័យមនុស្សធម៌ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា២៣ .-**

ជនបរទេសដែលបានបង្ហាញនូវភស្តុតាងថា ខ្លួនបានផ្តល់គុណសម្បត្តិពិសេស ឬថ្វីដៃពិសេសអ្វីមួយជាប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា និងបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មបាន ក្នុងករណីដែលជននោះបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១ ទី២ និងទី៦ មាត្រា១៩ នៃច្បាប់នេះ ។

**មាត្រា២៤ ._**

ជនបរទេសដែលមានសហព័ទ្ធ ឬកូនជាអនីតិជន ដែលមានបំណងស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម អាចដាក់ពាក្យស្នើសុំជាចង្កោមគ្រួសារ ។

**មាត្រា២៥ ._**

ជនបរទេសអាចសុំប្តូរឈ្មោះជាខ្មែរបាន ។ ក្នុងករណីនេះត្រូវសរសេរបញ្ជាក់ឈ្មោះថ្មីនោះ ក្នុងពាក្យសុំសញ្ជាតូបនីយកម្មរបស់ខ្លួន ។

**មាត្រា២៦ ._**

បែបបទ និងនីតិវិធីនៃការសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការផ្តល់សញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មត្រូវសម្រេចដោយព្រះរាជក្រឹត្យ ។

**មាត្រា២៧ ._**

ជនដែលបានអនុញ្ញាតឱ្យចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល ។

ខ្លឹមសារនៃសម្បថនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧
## ការបាត់សញ្ជាតិខ្មែរ

**មាត្រា២៨ ._**

ជនណាដែលមានសញ្ជាតិខ្មែរហើយមានអាយុ ១៨ (ដប់ប្រាំបី)ឆ្នាំ យ៉ាងតិច អាចសុំលះបង់សញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀតនិងដោយគ្មានការបង្ខិតបង្ខំ ។

ត្រូវបានអនុញ្ញាតឱ្យមានការសុំលះបង់សញ្ជាតិខ្មែរជាចង្កោមគ្រួសាររបស់ពលរដ្ឋខ្មែរជាម្តាយ ឬឪពុកដែលមានកូនជាអនីតិជន ។

**មាត្រា២៩ ._**

បែបបទ និងនីតិវិធីនៃការសុំលះបង់សញ្ជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី ៨
# ទោសប្បញ្ញត្តិ

**មាត្រា៣០ .–**

ជនបរទេសណាដែលកាន់កាប់ និងប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំទៅ ១០ (ដប់) ឆ្នាំ ។

មន្ត្រី ភ្នាក់ងាររាជការ ឬជនណាធ្វើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជាឱ្យជនណាម្នាក់ ដែលមិនមានសញ្ជាតិខ្មែរត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខ័ណ្ឌទី១ ខាងលើនៃមាត្រានេះ ។

**មាត្រា៣១ .–**

ជនណាដែលក្លែងបន្លំអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ ។

ត្រូវចាត់ទុកជាការក្លែងបន្លំផងដែរនូវអំពើធ្វើការកោស លុប សរសេរបន្ថែម ឬធ្វើឱ្យខូចខាតការពិតនូវព័ត៌មាននៅក្នុងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣២ .–**

ជនណាដែលប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជាក្លែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០(បួនលាន) រៀលទៅ ១០ ០០០ ០០០(ដប់លាន)រៀល ។

**មាត្រា៣៣ .–**

អ្នកផ្តើមគំនិត និងអ្នកសមគំនិតត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៣០ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់នេះ ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ ។

**មាត្រា៣៤ .–**

ចំពោះរូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៣០ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា៥៤ (ប្រភេទទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា៣៥ .–**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៣០

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មាត្រា៣១ និងមាត្រា៣២ នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀលទៅ ១០០ ០០០ ០០០ (មួយរយលាន) រៀល ព្រមទាំងទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា៣៦ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ត្រូវមានអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា៣៧ .-**

ច្បាប់ស្តីពីសញ្ជាតិដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ត្រូវទុកជានិរាករណ៍ និងជំនួសដោយច្បាប់នេះ ។

**មាត្រា៣៨ .-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨

នស/រកម/០៦១៨/០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ហត្ថលេខា**
**សម្តេចក្រឡាហោម ស ខេង**

លេខៈ៦៦១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃសុក្រ ១០កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**